៤

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣៩ ខែ មេសា

ព.ស. ២៥០៩ គ.ស. ១៩៦៧

# សព្ទសាធុការពរ

ក្នុងឆ្នាំថ្មី, មមែ នព្វស័ក ព.ស. ២៥១០ នេះ ពុទ្ធសាសនបណ្ឌិត្យ សូមលំឱនកាយប្រសិទ្ធិពរជ័យថ្វាយដោយគោរពចំពោះ៖

– សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និង សម្ដេចព្រះប្រមុខរដ្ឋ សូមទ្រង់បានប្រកបដោយព្រះបរមសុខគ្រប់ប្រការ ព្រមទាំងមានព្រះជន្មាយុយឺនយូរ!

– សម្ដេចព្រះសង្ឃរាជ និង សម្ដេចព្រះសង្ឃនាយក សូមព្រះអង្គមានព្រះសុខភាពបរិបូណ៌រឹងប៉ឹងមុតមាំ មានព្រះជន្ម-វិស្សាវែង!

ព្រមទាំង

សូមប្រគេន-ជូនសព្ទសាធុការពរចំពោះពុទ្ធបរិស័ទទូទៅ ទាំងបព្វជិត ទាំងគ្រហស្ថ, សូមបានបម្រុងចំរើនកើនកប ដោយ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាត!

ÉCOLE F…
F.682
BIBLIOTHÈQUE
P.P.
DIRECTEMENT

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

*ផ្នែកសាសនា* — *ទំព័រ*

១– បញ្ហាព្យាករណ៍ពីពុទ្ធសាសនា លោក សម-ថាំង ប្រែ-រៀបរៀង (ត) . . ៣៤៧
២– ម៉េចក៏ចាំបួស ម៉េចក៏ចាំសឹក សហជីវិន ផល-ទិត រៀបរៀង . . . . . ៣៥៧

*ផ្នែកអក្សរសាស្ត្រ*

៣– ពិចារណាដើម្បីយល់តក្កវិជ្ជា លោក ហ៊ុន គីមសៀ រៀបរៀង (ត) . . . ៣៧៥
៤– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . . . ៣៨៥
៥– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឌ. ពាម ស្រាវជ្រាវ (ត) . . . . . . ៣៨៩
៦– ឯកសារ សាស្ត្រស្ទឹករីតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . ៣៩៧
៧– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . . . ៤០១
៨– ឯកសារកម្ពុជសុរិយា លោក ឌ.ពាម ប្រមូលរៀបរៀង (ត) . . . . . . ៤១៩
៩– ជីវប្រវត្តិរបស់ខ្ញុំ ឈ្មោះ អៀង-សាយ (ត) . . . . . . . . . . . ៤១៧
១០– សិរីនៃកបិលមហាព្រហ្ម សហជីវិន ផល-ទិត នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង . ៤២៥

*ផ្នែកកំណត់ និង ប្រវត្តិការណ៍*


១១– អនិច្ចធម្មនៃព្រះមហាវីរវង្សាចារ្យ វ៉ាន់-សាឌុម . . . . . . – ៤៣១

– សុន្ទរកថា ព្រះសមុហ៍ពុធាចារ្យ ពុធ-ប៊ុណ្ណ . . . . . . ៤៣៣

– សុន្ទរកថា សហជីវិន គុយ-ពៅ អនុរដ្ឋលេខាធិការក្រសួងធម្មការ. . . . ៤៣៧

១២ – សេចក្តីរាយការណ៍ អំពីសកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យ . . . . ៤៤៦

១៣– ពរសព្ទសាធុការ . : . . . . . . . . . . ៤៥១


មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០រ០០ ។

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ,
ឲ្យជ្រះខាតចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

# បញ្ហាព្យាករណ៍ពីពុទ្ធសាសនា

(ត)

លោក សម-ថាំង ប្រែ - រៀបរៀង

៨- គម្ពីរមហាវង្ស ដែលជារឿងបុរាណបានពណ៌នាបញ្ជាក់ដោយពិស្តារអំពីប្រវត្តិពង្សាវតារនៅលង្កាទ្វីប ក្នុងជំនាន់ពុទ្ធកាល រវាងរជ្យព្រះវិជយកជា មុនគ្រិស្តសករាជ ៥៤៣ ឆ្នាំ ក្នុងពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់គង់ព្រះជន្មមាននៅឡើយ ។ គម្ពីរនេះ មានសំដែងអំពីរឿងព្រះបរមគ្រូជាច្រើនអន្លើ និងអំពីព្រះបាទអសោក នូវអស់ព្រះចៅគ្រប់គ្រងផែនដីតាំងពួង ដែលមានរឿងពាក់ព័ន្ធក្នុងព្រះពុទ្ធសាសនា ។

ប្រ. តាមគេសំគាល់ថា ព្រះបរមគ្រូមានព្រះសរីរៈកាយ ដូចជាយក្ស កំពស់ ១៨ ហត្ថ, រឿងនេះមានក្នុងពង្សាវតារឬទេ ?

វិ. គ្មានអ្វីជាគ្រឿងសំគាល់ទេ យើងគ្រាន់តែដឹងតាមគម្ពីរថា ព្រះ

ព្រះកក្រព្រះអង្គ សឹងប្រកបដោយអនុព្យញ្ជនលក្ខណៈ ដែលគេឃើញ ហើយនិយាយតាមគ្នា ៗ មកថា ដូចព្រះពុទ្ធអំពីបុរាណ ។

បុ. អ្នកអាចនឹងពណ៌នាតាមលំអាន ដែលមានក្នុងគម្ពីរផ្សេង ៗ ថា ព្រះអង្គប្រកបដោយព្រះរូបលក្ខណៈដូចមនុស្សសាមញ្ញឬទេ ?

វិ. អាច, ព្រោះមានសំដែងក្នុងគម្ពីរអង្គុត្តរនិកាយស្រាប់ថា មានស្ត្រីម្នាក់ ដែលតែងតែធ្វើទានប្រគេនព្រះមហាកស្សបៈ ; មានកាលមួយនោះ នាងបានយកចង្ហាន់ ទៅបូជាព្រះបរមសម្មាសម្ពុទ្ធវិញ ដោយការភាន់ច្រឡំថាតែព្រះមហាកស្សបៈដែលជាសាវ័ករបស់ព្រះអង្គ ហើយប្រសិនបើព្រះអង្គមានព្រះកាយដូចជាយក្ស នឹងធ្វើដូច្នេះ ពុំបានឡើយ ព្រោះមហាកស្សបៈ មានសរីរៈកាយជាមនុស្សធម្មតាទេ ។

បុ. ព្រះកិត្តិនាមជាទីគោរពរបស់ព្រះពុទ្ធជាម្ចាស់មានដូចម្ដេចខ្លះ ?

វិ. ព្រះកិត្តិនាមព្រះសក្យមុនី មានច្រើនគឺ

សក្យ, សិង្ហ, សុគត, សត្ថា, ជិន, ភគវ័ត, លោកនាថ, សព្វជ្ញ, ធម្មជា, តថាគត ជាដើម ។

## វគ្គទី ២

## អំពីព្រះធម៌ឬច្បាប់ព្រះពុទ្ធសាសនា

បុ. ពាក្យថាពុទ្ធៈ បានសេចក្ដីដូចម្ដេច ?

វិ. បានសេចក្ដីថា អ្នកត្រាស់ដឹង ឬអ្នកដែលបានសម្រេចនូវព្រះអនុត្តរសម្មាសម្ពោធិញាណ ។

ប្រ. អ្នកបានពោលថា ក្នុងកាលមុននៃព្រះបរមគ្រូយើងនេះ មាន ព្រះពុទ្ធអំពីបុរាណមកដែរ តើមែនឬទេ ?

វិ. មែន, យើងស្តាប់តាមប្រពៃណីអំពីបុរាណមក, ព្រះពុទ្ធនឹងត្រាស់ដឹងម្តង ៗ ក្នុងពេលដែលមនុស្សសត្វដល់នូវសេចក្តីលំបាក ទីងងឹតអន្ធការ ដែលបណ្តាលមកអំពីអវិជ្ជាគ្របសង្កត់ ហើយត្រូវការរកផ្លូវខុសត្រូវ ដែលជាករណីយកិច្ចរបស់ព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់ត្រាស់ដឹង ហើយប្រៀនប្រដៅពន្យល់ប្រាប់ផ្លូវល្អផ្លូវត្រូវ ។

ប្រ. ព្រះពុទ្ធនីមួយ ៗ ទ្រង់បានកសាងបារមីធម៌ដូចម្តេច ?

វិ. ជនណាមួយដែលបានជួបប្រទះហើយ ស្តាប់ព្រះធម៌ទេសនាអំពីសំណាក់ព្រះពុទ្ធអង្គណាមួយក្នុងលោកនេះ បានតាំងចេតនាខ្លួនថា ឲ្យបានជាពុទ្ធភូមិក្នុងកាលជាអនាគត, បើជននោះ បានបំពេញបារមីល្មមគួរដល់ការត្រាស់ដឹងហើយ ក៏បានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ ដើម្បីយកយានដឹកនាំមនុស្សសត្វក្នុងត្រៃលោកឲ្យរួចផុតអំពីជាតិកំណើត ។

ប្រ. អ្នកដែលមានបំណងចង់បានត្រាស់ជាព្រះពុទ្ធ ត្រូវកសាងដូចម្តេច ?

វិ. ត្រូវខំកសាងក្នុងបច្ចុប្បន្នជាតិនិងអនាគតជាតិ ដើម្បីផ្តាច់បង់នូវតណ្ហា, ធ្វើចិត្តឲ្យបានសុចរិត ដោយហាត់ពត់ហ្មឹកហ្មឺន ហើយខំប្រឹងសិក្សាចំណេះវិជ្ជាជាន់ខ្ពស់ ឲ្យបានចំរើនកើនឡើងជាលំដាប់ ជា

មនុស្សស្រគត់ស្រគំ មានចរិយាធម៌ខ្ពង់ខ្ពស់ និងមានចិត្តស្ងប់ក្នុងវត្ត ប្រតិបត្តិដែលជាផ្លូវមគ្គញាណ, លុះដល់កំណត់ចុងបំផុតជាតិ ក៏នឹងបាន ជាមនុស្សវិសេស, ត្រាស់ដឹង ដល់នូវសម្ពោធិញ្ញាណ ជាសាស្តានៃ មនុស្សសត្វទាំងឡាយ ។

ប្ញ. ក្នុងពេលដែលព្រះអង្គកំពុងកសាងខ្លួនកាត់កល់វដ្តសង្សារទ្រង់ មានព្រះនាមជាដូចម្តេច ?

វិ. ទ្រង់មានព្រះនាមថា ព្រះពោធិសត្វ, ហេតុនេះហើយបាន ជាព្រះកដនុរសេសិទ្ធាថ គោតម ទ្រង់មានព្រះនាមថា ពោធិសត្វ ទៅ ទល់នឹងពេលដែលទ្រង់បានសំរេចសម្ពោធិញ្ញាណ ត្រាស់ដឹងជាព្រះពុទ្ធ នៅនាក្រោមដើមពោធិព្រឹក្ស ។

ប្ញ. គេអាចដឹងរឿងរ៉ាវនៃព្រះអង្គ ក្នុងកាលដែលទ្រង់នៅជាព្រះ ពោធិសត្វនៅឡើយឬទេ ?

វិ. ក្នុងគម្ពីរជាតកដ្ឋកថា មានសំដែងអំពីរឿងរ៉ាវដែលព្រះអង្គ អន្ទោលយកកំណើតជាច្រើនអនេ្ទ ។

ប្ញ. រឿងរ៉ាវទាំងនេះ បង្ហាញនូវដូចម្តេចខ្លះ ?

វិ. ថា មានបុរសម្នាក់ បានត្រាច់រង្គាត់ក្នុងវដ្តសង្សារជាច្រើនជាតិ កសាងបន្ទំបារមីដោយការកំចាត់បង់នូវកិលេសតណ្ហា និងការបំពេញនូវ គុណធម៌ទាំងពួង ។

ប្រ. គេអាចកំណត់ចំនួនជាតិកំណើត ដែលព្រះពោធិសត្វនីមួយៗ ត្រូវកសាងមុននឹងបានសំរេចជាព្រះពុទ្ធនោះ បានឬទេ ?

វិ. ទេ, រឿងនេះ ស្រេចហើយតែបុព្វចរិត និងភាពនៃការកសាង ដែលព្រះពោធិសត្វនីមួយ ៗ តាំងបេ្តជ្ញា ឲ្យបានជាពុទ្ធភូមិ ហើយនិងហេតុដទៃ ៗ ទៀត ។

ប្រ. ព្រះពោធិសត្វទាំងឡាយ មានប៉ុន្មានយ៉ាង ?

វិ. ព្រះពោធិសត្វដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ចែកជា ៣ យ៉ាង ។

ប្រ. ចូរអ្នករៀបរាប់មកមើល ?

វិ. បញ្ញាធិក ឬឧគ្ឃដិតញ្ញូ "អ្នកត្រាស់ដឹងយឺនយូរជាងគេបង្អស់" សទ្ធាធិក ឬវិបចិតញ្ញូ "អ្នកត្រាស់ដឹងដោយយឺតយូរមធ្យម" វិរិយាធិក ឬនេយ្យ "អ្នកត្រាស់ដឹងដោយរួសរាន់", ព្រះពោធិសត្វជាបញ្ញាធិកច្រើនប្រើបញ្ញា, ព្រះពោធិសត្វជាសទ្ធាធិក ប្រកបដោយជំនឿ, ព្រះពោធិសត្វជាវិរិយាធិក ប្រកបដោយទូវក្តីព្យាយាមយ៉ាងមាំ ។ ព្រះពោធិសត្វទីមួយ ដែលប្រកបដោយបញ្ញា ពុំសូវរួសរាន់ក្នុងការត្រាស់ដឹងទេ, ព្រះពោធិសត្វទីពីរ ដែលប្រកបដោយជំនឿ ពុំសូវអើពើនឹងរកផ្លូវជាមគ្គញាណឡើយ, ព្រះពោធិសត្វទីបី គិតតែកសាងអំពើល្អជានិច្ចគ្មានបង្អង់ ពុំមានគិតដល់សេចក្តីនឿយលំបាកឡើយ ។

ប្ញ. កាលដែលព្រះពោធិសត្វនៃយើងបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណហើយ ទ្រង់បានសំដែងថា សព្វសត្វទាំងអស់ បានទទួលទុក្ខវេទនាមកអំពីអ្វី ?

វិ. មកអំពីអវិជ្ជា ។

ប្ញ. ចុះអ្វីដែលជាឱសថ ?

វិ. បញ្ញាជាគ្រឿងកំចាត់បង់នូវសេចក្តីងងឹត ដើម្បីឲ្យបានត្រាស់ដឹង ជាឱសថ សំរាប់រំងាប់នូវអវិជ្ជា ។

ប្ញ. ហេតុម្តេចបានជាអវិជ្ជាជាបច្ច័យនាំឲ្យកើតទុក្ខលំបាក?

វិ. ព្រោះអវិជ្ជាជាគ្រឿងនាំឲ្យជំពាក់ចិត្តនឹងរបស់ដែលគ្មានខ្លឹមសារ នាំឲ្យគ្រោធវង្វេងយល់ខុសនូវវត្ថុទាំងពួងដែលមិនទៀងទាត់ ថាជារបស់ទៀងពិតប្រាកដ ញ៉ាំងជីវិតឲ្យកន្លងទៅដោយការស្វែងរកវត្ថុ ដែលគ្មានតម្លៃគ្មានប្រយោជន៍ ហើយបោះបង់បោលវត្ថុដែលមានតម្លៃមានប្រយោជន៍ដ៏ឧត្តមក្រៃលែងនោះវិញ ។

ប្ញ. ប្រយោជន៍ដ៏ឧត្តមនោះ បានដល់អ្វីខ្លះ ?

វិ. កិរិយាដឹងស្គាល់អាថ៌កំបាំងនៃជាតិកំណើត នៃភពនិងវាសនារបស់មនុស្ស ហើយនិងការរកឃើញជាតិកត ដែលជាបច្ច័យនៃសង្ខារ ដើម្បីធ្វើអ្នកដទៃនិងខ្លួនឯង ឲ្យបានសេចក្តីសុខចំរើន ឲ្យផុតពីទុក្ខតាមសភាវៈធម្មតា ចាត់ថាជាប្រយោជន៍ដ៏ឧត្តមយ៉ាងក្រៃលែង ។

ប្. ពន្លឺណាដែលកំចាត់បង់នូវសេចក្ដីល្ងង់ខ្លៅ ហើយចៀសវាង
នូវសេចក្ដីសោយសោកបាន ?

ឆ្. ការដឹងច្បាស់នូវអរិយសច្ចទាំងបួន ដែលព្រះបរមគ្រូសំដែង
ទុកមក ពប់ថាជាពន្លឺសំរាប់កំចាត់បង់នូវសេចក្ដីល្ងង់ខ្លៅ ហើយចៀសចាក
ទុក្ខបាន ?

ប្. ចូររៀបរាប់មកមើល ?

ឆ្. ១)- សេចក្ដីទុក្ខលំបាក កើតពីការអន្ទោលយកជាតិ វិល
ស្លាប់វិលកើត ។ ក្នុងកពគ្ខួចកពង់ ហៅថា " ទុក្ខអរិយសច្ច ",

២)- ហេតុដែលនាំឲ្យកើតទុក្ខគឺសេចក្ដីប្រាថ្នាដែលចេះតែ
ចំរើនធំឡើងៗ ឥតមានកំណត់ ហើយពុំបានសម្រេចតាមបំណង ហៅថា
" សមុទយសច្ច ",

៣)- ការរំលត់នូវតណ្ហា ហៅថា " និរោធសច្ច ",

៤)- ផ្លូវប្រតិបត្តិដំណើរ ឲ្យដល់នូវការរំលត់បង់នូវតណ្ហា
ហៅថា " មគ្គសច្ច " ។

ប្. ចូរអ្នករៀបរាប់ហេតុដែលនាំមកនូវទុក្ខនោះមកមើល ?

ឆ្. ការកើត, សេចក្ដីចាស់គ្រាំគ្រា, ជម្ងឺដម្កាត់, សេចក្ដីស្លាប់,
ការព្រាត់ប្រាស់ចាកសត្វនិងសង្ខារ ដែលជាទីស្រឡាញ់, ការជួប
ប្រទះនូវសត្វនិងសង្ខារ ដែលជាទីស្អប់ខ្ពើម, សេចក្ដីប្រាថ្នានូវរបស់
ដែលមិនអាចនឹងសម្រេចបានជាដើម, នេះឯង ជាហេតុនាំមកនូវទុក្ខ ។

ប្រ. ហេតុទាំងនេះ មានប្លែកគ្នាទៅតាមបុគ្គលដែរឬទេ ?

វិ. ប្លែក, ព្រោះមនុស្សគ្រប់រូបតែងទទួលទុក្ខមានកំរិតផ្សេង ៗ ពីគ្នា ។

ប្រ. ត្រូវធ្វើដូចម្ដេច ដើម្បីនឹងចេញចាកទុក្ខដែលកើតអំពីសេចក្ដីប្រាថ្នាពុំចេះឆ្អែតឆ្អន់ និងសេចក្ដីត្រូវការ ដែលកើតមកអំពីអវិជ្ជា ?

វិ. ត្រូវរំងាប់បង់ឲ្យជ្រះស្រឡះ ត្រូវកំចាត់បង់នូវតណ្ហា និងសេចក្ដីរីករាយ ដែលជាហេតុនៃកងទុក្ខ ដែលហៅថា មគ្គសច្ច ។

ប្រ. ត្រូវធ្វើដូចម្ដេច ទើបឈ្មោះថា ដល់នូវមគ្គសច្ចនោះ ?

វិ. ត្រូវប្រតិបត្តិតាមគន្លងនៃមគ្គទាំង ៨ ប្រការ ដែលព្រះពុទ្ធជាម្ចាស់បានត្រាស់ដឹងនិងសំដែងហើយនោះ ។

ប្រ. ពាក្យថា អដ្ឋង្គិកមគ្គ បានសេចក្ដីដូចម្ដេច? បានដល់អ្វីខ្លះ?

វិ. បានដល់ផ្លូវទាំង ៨ ប្រការ ដែលលោកហៅថា អដ្ឋ គឺ ១ សេចក្ដីយល់ត្រូវ, ២ ការត្រិះរិះត្រូវ, ៣ សំដីត្រូវ, ៤ ការងារត្រូវ, ៥ ការចិញ្ចឹមជីវិតត្រូវ, ៦ សេចក្ដីព្យាយាមត្រូវ, ៧ ការនឹករលឹកត្រូវ ៨ កិរិយាតំកល់ចិត្តត្រូវ ។ បុគ្គលដែលបានប្រតិបត្តិតាមអដ្ឋទាំងនេះ នឹងអាចរលាស់ខ្លួនចាកទុក្ខ ហើយបានដល់ឋានក្សេមក្សាន្តដោយពិត ។

ប្រ. បើនឹងប្រើពាក្យផ្សេងជំនួសពាក្យថា "ក្សេម" នេះបានឬទេ ?

វិ. បាន, នឹងហៅថា រួចចាកចំណង់ ក៏បាន ។

ប្រ. វដ្តតាកចំណងអ្វី ?

វិ. វដ្តតាកទុក្ខលំបាកនៅក្នុងលោក តាកការវិលកើតវិលស្លាប់ ដោយអំណាចអវិជ្ជា និងតណ្ហាដ៏លាមក ។

ប្រ. កាលបើបុគ្គលណាមួយបានវដ្តផុត តាកបំណង ឬអន្ទង់នេះ តើនឹងបានដល់នូវអ្វី ?

វិ. នឹងបានដល់នូវព្រះនិព្វាន ។

ប្រ. និព្វានជាអ្វី ?

វិ. ជាសភាវៈដ៏ស្ងប់ស្ងាត់វិសេស ជាទីក្សេម លែងមានការប្រែប្រួលផ្លាស់ប្តូរ ជាសភាវៈទៀងទាត់ គ្មានតណ្ហាគឺសេចក្តីប្រាថ្នា គ្មានការប្រឡូកប្រឡាក់ដោយសុខនិងទុក្ខ និងគ្មានទុក្ខលំបាក គ្មានចុតិនិងបដិសន្ធិទេ ។ មុននឹងដល់និព្វាន បុគ្គលតែងតែវិលកើតវិលស្លាប់គ្មានឈប់ឈរ; លុះបានដល់ព្រះនិព្វានហើយ ទើបឈប់មានកំណើតតទៅទៀត ។

ប្រ. គេឃើញក្នុងសៀវភៅណាដែលពន្យល់ដោយពិស្តារ ពីព្រះនិព្វាន និងបញ្ញត្តិនាមទាំងពួងដែលបញ្ជាក់សេចក្តីអំពីព្រះនិព្វាននោះ ?

វិ. នៅក្នុងសៀវភៅវចនានុក្រមភាសាបាលីរបស់លោកឈ្ហីលឌើស (Childers) គេឃើញមានពន្យល់ពាក្យ "និព្វាន" យ៉ាងពិស្តារ ។

ប្រ. ជនចំពួកខ្លះគិតស្មានថា ព្រះនិព្វាន ជាឋាននៅលើមេឃ ជា -

ឋានសួគ៌, តើព្រះពុទ្ធសាសនាមានពន្យល់ដូច្នេះឬ ?

វិ. ពុំដូច្នេះទេ, ព្រោះកាលកូដទន្តព្រាហ្មណ៍ក្រាបទូលសួរព្រះអង្គអំពីទីនៃព្រះនិព្វាន ព្រះអង្គតបវិញថា "ព្រះនិព្វាន ស្ថិតនៅត្រង់កន្លែងដែលជាទីតាំងនៃសេចក្តីប្រតិបត្តិត្រឹមត្រូវតាមធម៌វិន័យ" ។

ប្ញ. ហេតុម្តេចបានជាមនុស្សយើងត្រូវកើតទៀត ?

វិ. មកពីសេចក្តីប្រាថ្នាពុំចេះអស់ (តណ្ហា ចំពោះវត្ថុដែលមាននៅក្នុងលោកនេះ និងសេចក្តីប្រាថ្នាក្នុងភពនានា) នេះហើយជាធម្មជាតិមួយ មានឫទ្ធិអំណាចខ្លាំងណាស់ អាចដឹកនាំសត្វឲ្យចាប់បដិសន្ធិកើតនៅក្នុងត្រៃលោកតទៅទៀតបាន ។

ប្ញ. សេចក្តីប្រាថ្នាដែលពុំបានសម្រេច អាចឲ្យផលណាមួយក្នុងបដិសន្ធិរបស់សត្វនោះឬទេ ?

វិ. អាចឲ្យផលបានដូចជាកុសលនិងអកុសលនៃយើងដែរ ។

ប្ញ. កុសលនិងអកុសល អាចឲ្យផលក្នុងបដិសន្ធិកាលរបស់យើងឲ្យមានភាព លក្ខណៈ និងរូបរាងល្អអាក្រក់ បានឬទេ ?

វិ. បាន តាមធម្មតា ផលជាកុសលអាចនាំសត្វឲ្យចាប់បដិសន្ធិនៅក្នុងទីខ្ពង់ខ្ពស់ជាទីរីករាយសប្បាយ, ចំណែកខាងអកុសលវិញ តែងនាំសត្វឲ្យចាប់បដិសន្ធិនៅក្នុងទីថោក-ទាប និងទីទុក្ខលំបាក ។

(នៅមានត)

# ម៉ែចក៏ចាំបួស ម៉ែចក៏ចាំសឹក

សបាដីរីន ផល-រិត នៅពុទ្ធសាសនបណ្ឌិត្យ

(៥-៣-៦៤)

មុនទ័ងដើរត្រូវតាមផ្លូវត្រង់ ត្រូវបេះរេចង់ស្ទង់កំហុស
បើឃើញត្រង់ណាជាផ្លូវខុស ប្រាជ្ញប្រាណជាតិមនុស្សកុំប្រព្រឹត្ត ។
ផ្លែស្លែងវែងពុលជាទោសកាច តែមានគុណអាចកែជីវិត
ស្ដៅ-ម្រះ ក្រាស់ជោយជាតិល្វីងពិត តែគង់មានឫទ្ធិកែរោគបាន ។
ភ្លើងក្ដៅហៅអាចកំណាចក្រៃ តែជាតម្លៃនៃចង្ក្រាន
ជាតិស្រាស្រវឹងរឹងស៊ុនប្រាណ តែគង់ផ្សំបានជាឱសថ ។
កាំបិតពិតជាគ្រឿងប្រហារ តែអាចប្រើការកាប់អុសជុត
ជាតិបរមាណូមានទោសផុត តែមានគុណសុទ្ធផុតដូចគ្នា ។
រីឯពាក្យថ្កោលជោលជេញសួរ ទោះបីគ្មានគួរជួមេត្តា
ក៏គង់មានគុណច្រើនមហិមា មកជាមួយគ្នាអចិន្ត្រៃយ៍ ។
រឿងបួសរួសសឹកជាប្រុសខ្មែរ មិនសមខ្វះដៃតែប្រពៃ
ព្រោះបួសជាបុណ្យគុណច្រើនក្រៃ ជួយក្សាប់និស្ស័យសាងសុចរិត ។
អ្នកដែលបានបួសជាផ្នួសពេញ ដល់សឹកមកវិញហៅបណ្ឌិត
ហៅក្លាយមកទៀតថាអន្ទិត នេះពិតជាឈ្មោះខ្ពស់ពណ្ណកាយ ។
សម័យអង្គរដ៏ថ្កើងថ្កាន អន្ទិតធ្លាប់បានបាទទូលាប
ជាគ្រូអាចារ្យ ជាចៅហ្វាយ ធ្វើការតាំងឡាយថ្វាយក្សត្រា ។

ផ្ការផ្ដាប់អានក្នុងបានខ្ពស់ លើកសិទ្ធិកិត្តិយសខ្ពស់ថ្លៃថ្លា
ផ្ការពស្ត្រីចាស់ស្រុកខ្មែរគ្រប់គ្នា ពប់ថាឈ្មោះហ្នឹងសឹងពិសិដ្ឋ ៗ
ហេតុកំណាន់ប្រកាន់ថា កម្លោះស្តុកណាគ្មានគំនិត
មិនបាននាមថាជាអច្និត នោះពិតជាគេមិនឲ្យកូន ៗ
នៅក្នុងសម័យនៃសង្គ្រាម ហូរឈាមចេញចាកអង្គតាដូន
អក្សរសាស្ត្រខ្មែរស្មើរសាបសូន្យ តើកូនទេវតាណាមកជួយ ៗ
មិនគឺអ្នកបួសនោះឬអ្វី ដែលសាងស្នារតៃលើកស្ទួយ
ទល់ទប់ឱបស័គ្គពក់ទុក្ខព្រួយ ប្រឹងជួយស្ទួយខ្ទលមូលរក្សា ៗ
ខ្មែរជាជាតិតូចតែដូចពេជ្រ ទោះក្រីក្រម្ដេចក៏ហានក្លា
ចេះអានសរសេរតួអក្ខរ ស្មើរតែគ្រប់គ្នាក្នុងមណ្ឌល ៗ
ការនេះពេញជាមិនចាញ់ដៃ ជនជាតិដទៃនាសាកល
ខ្មែរជាជាតិតូចតែដួចដល់ ចិត្តរឹងទឹកថ្ពល់យល់កាលវែង ៗ
ព្រោះបានមានមិត្រចិត្តត្រង់ហួស គឺការកាន់ផ្នួសបួសហ្នឹងឯង
ដែលពាំនាំខ្មែរឲ្យបែរស្វែង ប្រឹងប្រែងក្រែងបាត់ខ្លាតវាសនា ៗ
អ្នកបួសស្ពាយបាត្រដើរបិណ្ឌបាត ក៏គ្មានអន្តរាយដល់ជនណា
លោកមិនដែលញាំងអ្នកជ្រះថ្លា ឲ្យខូចសទ្ធាឬធនធាន ៗ
ព្រោះពុទ្ធសាសនាថ្លាឧត្តម ប្រកាន់និយមរឿងឲ្យទាន
ប៉ុន្តែមិនឲ្យអន្តរធាន បាត់បង់សន្តានខាងស្រង់សត្វ ៗ

ពោះបីសុំគេមកគោក្ដា ក៏គ្មានអាជ្ញាទៅអារកាត់
ពួកអ្នកឲ្យទានឥតមានខ្វាត់ សទ្ធា-សម្បត្តិនៅធម្មតា ៗ
ប្រៀបដូចសត្វឃ្មុំផ្ដុំសំបុក ហើរត្រាច់ត្រកមែកព្រឹក្សា
ខ្វាត់ខ្វែងស្វែងត្រឹបទឹកដមផ្កា យកទៅសង់ជាផ្ទុកឃ្មុំបាន ៗ
បុប្ផាផ្កាតាយផ្សាយក្លិនក្រែប ដែលត្រូវឃ្មុំក្រេបទឹកដមប្រាណ
ក៏ឥតស្រពោនស្វិតរំខាន តាំងនៅតាមឋានដូចប្រក្រតី ៗ
ទាំងក្លិនទាំងពណ៌ក៏នៅស្រស់ ដូចដើមទាំងអស់ឥតប្រែអ្វី
អាចបិចលេចញញ្ញក្តិបផ្ទុំខ្ចី កើនពូជប្រក្រតីឥតបាត ៗ
ឯឃ្មុំក៏ផឹកទឹកដមផ្កា យកទៅសាងជាផ្ទុកដ៏ឃ្មាត
ចិញ្ចឹមកូនចៅផៅវង្សជាតិ ដោយឥតមានខាតទៅខាងណា ៗ
គឺផ្កាក៏ឥតវិបរិតខូច នៅកើតកពូជជាធម្មតា
រីឃ្មុំផ្សព្វរកដមផ្កា ក៏បានកើតជាប្រយោជន៍ធំ ៗ
រឿងនេះប្រៀបបានទីអ្នកបួស កាន់ផ្នត់បទផ្នួសកេរ្តិ៍ឧត្ដម
ប្រឹងប្រែងស្វែងរកគុណដ៏ធំ ដូចជាសត្វឃ្មុំអីចំពឹងឯង ៗ
អ្នកឲ្យឥតខូចកោតសម្បត្តិ ឥតខ្វាត់សទ្ធាចិត្តបាត់ថែង
អ្នកបួសបានហើយក៏ប្រឹងប្រែង ប្រព្រឹត្តខ្លួនឯងស្វែងរកគុណ ៗ
ក្រៅពីខ្លួនលោកយោគដល់ញាតិ ផ្សព្វផ្សាយដល់ជាតិឥតខាតស៊ុន
ខ្មែរយើងថ្កើងថ្កានមានកិត្តិគុណ ដោយបុណ្យអ្នកបួសជួយទ្រទ្រង់ ។

រួមមកគឺមួយៈ ជួបជាក់ច្បាស់ ខាងអក្សរសាស្ត្រឲ្យគង់វង្ស
ពីរជួយអប់រំផ្សំទម្រង់ ឲ្យខ្មែរខ្ពស់ខ្ពង់ខាងចរិយា ។
បីជួយឲ្យបានជាមណ្ឌល ផ្តួចផ្តល់ទៅគ្រូអក្ខរា
កូនខ្មែរខ្សត់ក្រយ៉ាងម្តេចម្តា ទៅនៅសិក្សាបានទាំងអស់ ។
បួនជួយឲ្យជាតិចេះបងផ្តុំ រួមជាសង្គមជុំគ្នារស់
ឲ្យចេះធ្វើទានទ្រព្យរបស់ មានចិត្តសប្បុរសសង្គ្រោះខ្សត់ ។
សង្គ្រោះអ្នកបួសជាអាចារ្យ សង្គ្រោះកុមារដែលនៅវត្ត
សង្គ្រោះពលករដែលក្រខ្សត់ សង្គ្រោះជនបទដែលអត់បាយ ។
ព្រោះតែការបួសនេះសំខាន់ ទើបខ្មែរប្រកាន់មិនដែលណាយ
ផ្តាំត-កូនចៅចៅវែងឆ្ងាយ ត្រូវតែប្រុងកាយបួសកុំខាន ។
បើមិនបួសយូរបូរបព្វជ្ជា ត្រឹមៈចញ្ញវស្សាសឹកក៏បាន
តែកុំឡោះណាឲ្យថ្លោះខាន មុខជាលែងបានប្រពន្ធល្អ ។
ទំនៀមនេះឯងគេតែងត្រិត ដើម្បីទាញចិត្តមនុស្សឲ្យស
មួយគឺឲ្យមនុស្សទាំងមានក្រ ទៅរៀនច្បាប់ល្អឲ្យស្គាល់ច្បាស់ ។
—ពីរគឺឲ្យខ្មែរស្រែចំការ ចេះសរសេរចារអក្សរសាស្ត្រ
បើទុកជារៀនមិនជាក់ច្បាស់ អន់ណាស់អានបានសរសេរបាន ។
ការបួសកើតបុណ្យមានគុណខ្ពស់ រៀបរាប់មិនអស់ហួសប្រមាណ
ទ្រទ្រង់ជាតិយើងឡើងថ្កើងថ្កាន កុំភ្លឹកនឹកស្មានថាថោកទាប ។

ជនណាទៀយណាយកាយកើតក្តុប មិនចង់នៅជាប់អំពើបាប
ជននោះបួសស្វែងផ្លែប្រភាព រៀនការបរហូតអស់ជីវិ ៗ
ជនណាមិនទាន់ទ្រាន់ជិនណាយ នៅឃើញសប្បាយក្នុងកាមខ្លាំង
ជននោះបួសដែរតែមួយភាំង ក៏តាំងសឹកមករកកាមវិញ ៗ

ការបួសដើម្បីផ្តាច់វិស្ស័យ ខាងល្អប្រពៃឲ្យពេញលេញ
តែកុំខាតពេញឥតចំណេញ ត្រូវចេញកហាងខាងសិក្សា ៗ
រៀនទាំងផ្លូវធម៌ទាំងផ្លូវលោក ចេះដឹងគរគោកតែគ្រប់គ្នា
សឹកមកជួយជាតិជួយសាសនា ដូចគេកល់គ្នាអីចឹងដែរ ៗ
មិនបង់បាយជាតិញាតិសន្តាន បំណាច់ខ្លួនប្រាណកើតជាខ្មែរ
បានជួយជាតិសាសន៍ដូចគេដែរ មិនបែរជាស្អប់ចំលាប់ឪ ៗ

ឥឡូវការបួសហួសសម័យ កាលពេលសព្វថ្ងៃលោកតម្រូវ
មិនចាំបាច់បួសឲ្យហួសផ្លូវ គេត្រូវនៅជាយុវជន ៗ
គេក្រេបវិជ្ជាតាមចិត្តចង់ ចេះជាងលោកសង្ឃក្នុងបច្ចុប្បន្ន
ចាំបួសធ្វើអីឲ្យតែអន់ នាំគេរិះគន់ទ្រាំទល់គ្នា ៗ
ពីដើមស្រុកទេសយើងលិចលង់ បានជាពឹងសង្ឃខាងសិក្សា
យើងបួសដើម្បីរៀនអក្ខរ ចម្រើនភាសាជាតិឲ្យរស់ ៗ
ឥឡូវរីកកើនចំរើនណាស់ ខាងអក្សរសាស្ត្ររៀនមិនអស់
មានទាំងគម្រិះបំណេះខ្ពស់ ចាំបួសឲ្យអស់កម្លាំងអី ៗ

ដំណើរសម័យមានថៃ្ងយប់　　វិលឥតឈប់ឈប់ជាប្រក្រតី
តើយើងជាជាតិភ្ជាប់ឈ្មោះល្បី　　កើតនៅលើដីកម្ពុជា　　ៗ
ម្តេចក៏មិនប្រែកែសម្រួល　　សម្រួបឲ្យស្រួលតាមវេលា
ជាសប្តុរទម្លាប់ឲ្យគាប់ជា　　តាមពេលៈវេលាព្រមគ្នាទៅ ?　　ៗ

　　សំដីនេះមិញពេញជាសម　　តែបូលប្រទ្បំពុំទាន់ជ្រៅ
ព្រោះឃើញតែគោលដែលដើរទៅ　　ឯហានបិតនៅពុំសូវគិត　　ៗ
សម័យថ្មីនេះរឿងការបួស　　ទីងថាក់ហួសក៏ពុំពិត
ព្រោះមួយកស្ត្រីខ្មែរនៅពេញចិត្ត　　ពីរពួកអទ្ធិតក៏មានផ្លូវ　　ៗ
បានរៀនបានសូត្រហួតអស់　　ដូចពួកគ្រហស្ថពេលឥឡូវ
ទៀតពេលប្រព្រឹត្តគិតរកត្រូវ　　ដឹកនាំម៉ែឪទៅរកសុខ　　ៗ
ទីបីដូចយើងប្រាប់ខាងដើម　　អំពីផ្តើមកូនអ្នកស្រុក
ជាអ្នកក្រខ្សត់អត់ត្រេបមុខ　　ក៏ជាបន្ទុកការបួសដែរ　　ៗ

　　បើនឹងបញ្ជាក់ឲ្យយល់ឆាយ　　យើងនឹងអធិប្បាយបើកបកកើ្ត
អំពីស្នាដៃអ្នកបួសខ្មែរ　　ដែលបែរបែកផលជាច្រើនយ៉ាង　　ៗ
ការបួសប្រៀបបាននឹងគល់ឈើ　　ដែលលូតទៅលើចេញមែកធាង
ជាទីប៉ុចផ្កាផ្លែប្រូងប្រាង　　ជាព្រៃសំណាងអ្នកបេះធី　　ៗ
គល់ពិតតែមួយតែជួយទ្រ　　ឲ្យល្អមែកធាងសន្ទឹកខ្ចី
បើកាប់គល់ប៉ុាច់ដាច់ពីដី　　មែកធាងអាងអីមិនរលំ　　ៗ

នៅពេលសព្វថ្ងៃសម័យណាស់ តែផ្លាស់មិនផុតពីវាសទុំ
ដូចក្មេងជាតិខ្មែរទាំងតូចធំ នៅតែទៅផ្តុំសុំដេកវត្ត ៗ
អ្នកស្រុកចំណាយតាមធនធាន ច្រើនសែនច្រើនលានគ្មានកំណត់
សាងកុដិសាលាពេញគ្រប់វត្ត តើពិតប្រាកដមកពីអ្វី ៗ
គឺមកពីចិត្តគេជ្រះថ្លា នឹងពុទ្ធសាសនាព្រះជិនស្រី
ដែលមានអ្នកបួសជាសាក្សី ទើបគេឃ្លាតខ្វីគ្មានគិតស្តាយ ៗ
ដល់កើតជាឋានទីលំនៅ លោកនេះធ្លាក់ទៅក្មេងទាំងឡាយ
នៅបួសនៅរៀនតាមសប្បាយ បន្ធូរប្រាក់ម្តាយឪពុកបាន ៗ
បើអស់លោកសង្ឃពីវត្តវ៉ា តើកុដិសាលាម្តេចនឹងមាន
ក្មេងខ្មែរក្រីក្រអន្តរធាន រកទីតាំងប្រាណពុំបានពិត ៗ
មិនត្រឹមប៉ុណ្ណោះអស់ព្រះសង្ឃ ព្រះទ័យស្រោចស្រង់ក្នុងអាណិត
ដឹកនាំបាសកឲ្យដក់ចិត្ត ជួយគិតពីការសិក្សាជាតិ ៗ
អ្នកស្រុកជឿបុណ្យស៊ុនចំណាយ រៃប្រាក់កាសតាយដោយចិត្តស្អាត
សាងសាលារៀនមានព្រោងព្រាត គ្មានខាតថវិកាពដការសោះ ៗ
គ្រប់វត្តសុទ្ធសឹងប្រឹងប្រឹតប្រៀន សាងសាលារៀនគ្មានចន្លោះ
គ្រប់ភូមិកុះករទោះកៀនកោះ សាលាដូចហោះទៅតំកល់ ៗ
បើគ្មានព្រះសង្ឃអ្នកដឹកនាំ ឲ្យមនុស្សជឿមាំក្នុងមគ្គផល
តើងាយអ្នកណានឹងគិតយល់ ជួយផ្តល់កិច្ចការបានប៉ុណ្ណឹង ៗ

សម្ដេចបិតាជាអម្ចាស់ ក៏ទ្រង់បានត្រាស់ច្បាស់ឲ្យដឹង
ជាញឹកញយណាស់ពីរឿងហ្នឹង ឲ្យជាតិយើងដឹងសព្វគ្រប់ហើយ ។
ដូច្នេះការបួសគ្មានចង្រៃ គ្មានហួសសម័យឯណាឡើយ
ពោះមានជនខ្លះធ្វើព្រងើយ ប្រែខ្លួនធ្ងន់ធ្ងើយថាថោកទាប ។
ហ៊ានបួសព្រោះតែហ៊ានលះចិត្ត ដែលធ្លាប់ឆ្មើងគិតប្រកាន់ភាព
ដើម្បីឲ្យបានបាត់ពីបាប ម្ដេចខ្លាចថោកទាបមកដល់កាយ ។
គេប្រឹងប្រព្រឹត្តចិត្តឲ្យស្អាត ព្រឹកឡើងកាន់បាត្រដើរបិណ្ឌបាយ
ស្លៀកពាក់ក៏អន់មិនឆើតឆាយ កោរសក់អត់បាយឆ្ងាយពីផ្ទះ ។
ច្បាប់បួសអ៊ីចឹងគឺគង់តែង ឲ្យមនុស្សលះលែងចិត្តមានះ
បេះទនទោនទាបក្រាបសំពះ សមទំនងឃ្លាល្បះភាសិតថា ។
" ទាសៈខ្មាយបង់មានៈ ជរៈខ្មាយរូបសោភា
ថ្លែងរឿងព្រះពុទ្ធផុតវេក យាចក!ឈ្មោះថាថោកទាបពិត " ។
ដូច្នេះអ្នកបួសហួសពីទាប ព្រោះភាពពឹងគេសាងជីវិត
តែបើមើលពង់ត្រង់ផ្លូវចិត្ត នោះពិតជាថ្លៃឥតគូស្មើ ។
ព្រោះអ៊ីព្រះសង្ឃដែលទ្រង់សីល មិនមែនខូចចិលបុគ្គលធ្វើ
របៀបសុំទៀតក៏ថ្នាក់លើ ដូចយើងស្រាយរើទានលើស្រាប់ ។
មិនមែនដូចសូមដើរសូមទាន ដែលដាក់ទុកប្រាណថាអភ័ព្វ
សុំគេតាមចិត្តឥតខ្មាប់ គេស្អប់គេខ្ពើមឆ្អើមគ្រប់គ្នា ។

ព្រោះខ្ជិលកសាងអាងតែសុំ
មារយាទធ្វើយំព្រួយកំព្រា
រៀបរាប់ឲ្យតែគេមេត្តា
គ្រន់គុណល្អជាគ្មានធ្វើសោះ ៗ
រីឯព្រះសង្ឃខ្ពង់ជាន់ហ្នឹង
មិនធ្វើអីចឹងឲ្យអាប់ឈ្មោះ
ហើយតាំងចរិយាក៏គ្មានមោះ
ល្មមដោះពាក្យគេនិន្ទាបាន ៗ
ធ្វើខ្លួនជូនគេជាស្រែបុណ្យ
ប្រព្រឹត្តសាងគុណតាមកល្យាណ
ជួយថែរសង្គ្រោះញាតិសន្តាន
ជួយជាតិដូចបានថ្លែងមកហើយ ៗ
ខ្វះមិនទាន់ខាំងតាំងចិត្តហួស
ព្រាន់ទឹងការបួសយ៉ាងហ្នឹងឡើយ
មានតែស្តើងស្តួចដែលលួចធ្វើយ
ព្រោះគេដល់ត្រើយស៊ើយគួរជាក់ ៗ
ឯសាលារៀនមានច្រើនពិត
តែស្រេចទឹងចិត្តដែលគេស្ម័គ្រ
មិនបួសក៏រៀនគ្មានឧបសគ្គ
ឡើងថ្នាក់ទៅលើប្រសើរក្រៃ ៗ
តែបើគេចង់ទ្រង់ចីពរ
ដើម្បីកាន់ធម៌ប្រពៃ
បួសចុះប្រុសប្រាជ្ញកុំខ្លាចភ័យ
វាគ្មានទោសពៃរ៍ទៅអ្វីទេ ៗ
រាជការសង្គមបានទំនៀប
របៀបសិក្សាជាហូរហែ
ចែកជាពីរផ្លូវឥតផ្លាស់ប្រែ
ស្រេចតែកូនចៅទៅសិក្សា ៗ
របៀបមួយផ្នែកប៉ែកបច្ចុប្បន្ន
សម្រាប់យុវជនពុំបព្វជ្ជា
មួយទៀតហៅពុទ្ធិកសិក្សា
សម្រាប់ជនណាជាបព្វជិត ៗ
ដូច្នេះការរៀនមានពីរផ្លូវ
សុទ្ធតែត្រឹមត្រូវគ្មានវិក
ចង់រៀនខាងណាស្រេចលើចិត្ត
កុំគិតជាល្បែងប្រជែងគ្នា ៗ

កុំញ្ញអ្នកបួសឲ្យហួសខុស    ផុតពីឋានមនុស្សទៅសួគ៌
អ្នកបួសមិនមែនជាតិទេវតា    គឺជាតិខ្មែរមកដូចគ្នាដែរ ។
ហើយជាយុវជនបន្តវង្ស    មានពូជមានពង្សពីឈាមខ្មែរ
ដូចជាយុវជនទាំងពួងដែរ    មិនមែនក្លាយបែរខ្មែរពីព្រាហ្មណ ។
ប៉ុន្តែអ្នកបួសហួសពីគេ    ត្រង់តែកចិត្តទៅជាពីរស្ថាន
គឺមួយស្វែងរកសួគ៌និព្វាន    ពីរកសាងប្រាណគង់បច្ចុប្បន្ន ។
មុនទឹងទៅសួគ៌គួរតែសាក    បែរឆាកសាងខ្លួនឲ្យគ្រប់គ្រាន់
មិនមែនទៀងសួគ៌ដូចចៃដន្យ    ទាំងពេលបច្ចុប្បន្នអីចឹងទេ ។
មួយទៀតការបួសហើយលាសឹក    តាមយើងរំពឹងទឹករកពាក្យកៃ
ឃើញថាជាគុណគួរកុំប្រែ    ត្រូវទុកហូរហែឲ្យវែងឆ្ងាយ ។
ព្រោះបួសហើយសឹកឬកនេះថ្លៃ    ឲ្យទាន់សម័យដែលប្រែក្លាយ
– ទីមួយឲ្យកូនខ្មែរទាំងឡាយ    ជាប់ចិត្តស្និទ្ធកាយតាមដូនតា ។
ឲ្យសមទឹងពាក្យដ៏សំខាន់    ដែលថាខ្មែរកាន់ពុទ្ធសាសនា
កុំកាន់តែមាត់ចិត្តសារ៉ា    កាន់គ្រាន់ឃោសនាយកបុណ្យស័ក្តិ ។
សម្តេចឪយើងដែលទ្រង់ធមិ    ជាឧទាហរណ៍ដ៏ជាក់លាក់
គឺទ្រង់កាន់វង្សជាខ្មែរម្នាក់    ព្រះទ័យស្មោះស្ម័គ្រនឹងទៀមជាតិ ។
ទ្រង់កាន់ព្រះផ្នួសបួសជាសង្ឃ    តាមបែបព្រះវង្សពង្សនរនាថ
សមជាក្សត្រខ្មែរឥតប្រែឃ្លាត    អ្នកជាតិនិយមពុទ្ធសាសនា ។

– ទីពីរឡើងខ្មែរប្រកាន់ខ្ជាប់ នូវបទទម្លាប់ដ៏ថ្លៃថ្លា
ដែលឲ្យយើងចេះសង្គ្រោះគ្នា ដូចបានពណ៌នាខាងដើមហើយ ។
ព្រោះតែបើយើងលែងបួសវិញ ក៏គ្មានចំណេញប៉ុន្មានឡើយ
យូរទៅអ្នកបួសកាន់តែស្បើយ ដល់ហើយក៏បាត់រលត់បង់ ។
ដល់ផុតអ្នកបួសជំនួសព្រះ គ្រហស្ថអ្នកលះទ្រព្យស្រោចស្រង់
ដាច់សូន្យដូចគ្នាជាពិតត្រង់ ព្រោះគ្មានព្រះសង្ឃជាសាក្សី ។
រលាយអស់វត្តរលត់ឈឹង កូនខ្មែរធ្លាប់ពឹងតើបានអ្វី
វាទឹងធ្លាក់ជូនសាជាថ្មី ដល់ម្ចាស់ផែនដីក្នុងការស្រោយ ។
បើនាំគ្នាបួសឲ្យបន្ទាប់ បន្តគ្នាជាប់ខ្សែស្រឡាយ
សាសនាពិតជាមិនអន្តរាយ អាចតាំងនៅឆ្ងាយអង្វែងបាន ។
ហើយបើយើងប្រឹងឲ្យព្រមគ្នា លើកស្ទួយសាសនាឲ្យថ្កើងថ្កាន
ខ្ពង់ខ្ពស់ជាងនេះទៅទៀតមាន យើងហ៊ានថាធូរដល់សង្គម ។
ព្រោះមនុស្សជឿបុណ្យគុណមគ្គផល រឹតតែជួយផ្ដល់ការឧបត្ថម្ភ
ខាងកិច្ចសិក្សាការអប់រំ មួយភាគយ៉ាងធំសមគួរខ្លះ ។
ជាតិអាចសំចៃលៃថវិកា ពីសាងសាលាពីសាងផ្ទះ
ពីការផ្គង់ផ្គត់កូនចៅខ្លះ ទុកយកទៅប៉ះការខ្វះខាត ។
នៅក្នុងវិស័យដទៃផ្សេង ចម្រើនក្រៃលែងដល់រដ្ឋជាតិ
ប្រសិនជាលុបទម្លាប់ស្អាត នេះនៅតើជាតិចំណេញអី ។

បើនឹងនិយាយ ថាការបួស នាំឲ្យហួសសម័យថ្មី
ខាតពេលដែលត្រូវសាងផែនដី សាងជាតិឃ្លាតឆ្ងាយក្រៃលែង ៗ
ថានេះរិះគ្រាន់តែនៅខុស មិនគិតវ័យមនុស្សឲ្យជាក់ស្តែង
តើអ្នកណាហ្ន៎ ! ទៅកំហែង ឲ្យក្មេងទៅស្មើរធ្វើការងារ ៗ
គេចែកផ្នែកមនុស្សទាំងប្រុសស្រី តាមវ័យទាំងបីមកយូរយារ
ទីមួយគឺវ័យនៃកុមារ ជាវ័យត្រូវការសិក្សាមុន ៗ
ពីរគឺវ័យហៅកណ្តាល ជាកាលត្រូវមនុស្សរកសាងទុន
ទីបីជាវ័យកសាងគុណ ធ្វើបុណ្យធ្វើទានសីលភាវនា ៗ
អ្នកបួសច្រើនក្មេងស្វែងរៀនសូត្រ តាំងចិត្តស្លូតបូតតាមដូនតា
បួសហើយចាប់ផ្តើមការសិក្សា ល្មមវ័យកាលណាក៏សឹកវិញ ៗ
មកលៃប្រតិដ្ឋផលិតផល ជួយជាតិជិតដល់យ៉ាងពេញលេញ
ប្រកបរបររកចំណេញ បំពេញមុខងារជាពលរដ្ឋ ៗ
រីឯយុវជនមិនបានបួស ក៏មិនជ្រុលជ្រួសហួសបែបបទ
ពោះបីមិនចូលជាសិស្សវត្ត ក៏គង់ចូលបទសិក្សាដែរ ៗ
មិនដែលម៉ែឪស្គាល់ត្រូវខុស ណាមួយប្រទុស្តប្រទេចដែរ
ដល់ក្មេងក្នុងវ័យសិក្សាដែរ ឲ្យបែរត្រឡប់ឈប់រៀនឡើយ ៗ
គ្មានការបង្ខំដំបង្ខិត . មានតែលោមចិត្តថាកូនអើយ
ចាំរៀនសូត្រទៅកុំព្រងើយ ខ្លួននាងធំហើយត្រូវបេះភ្នាស ៗ

តាំងនាងនៅក្មេងវ័យវែងឆ្ងាយ កុំឲ្យទឹកស្អាយដល់ទៅចាស់
តែមានគ្រួសារការច្រើនណាស់ គ្មានពេលណាផ្ទាស់វិលវិញទេ ៗ
ដូច្នេះជាបួសនាំឲ្យខាត ឲ្យខូចការជាតិដូចពាក្យតែ
យើងហ៊ានធ្វើយថាមិនពិតទេ ដូចពោលហួរហែមកនេះឯង ៗ
មួយទៀតបើបួស ផលហួសវ័យ ព្រោះលៃមិនទាន់កន្លងកាលក្មេង
រឿងនេះក៏គ្មានចំឡែកផ្សេង វាតែងតែមានជាធម្មតា ៗ
ពោះមិនអ្នកបួសក៏ហួសដែរ ព្រោះខ្មែរឧហាតជាតិសិក្សា
ខ្វះរៀនពីវ័យកុមារ ដល់ចាស់ស្រកក៏មិនឈប់ ៗ
— ទីបីប្រយោជន៍ខាងអប់រំ លើកស្ទួយសង្គមខាងសេពគប់
ព្រោះអីការបួសជាទំនប់ ជួយទប់កូនខ្មែរឡែកខ្លួន ៗ
ជួយផ្តល់សំណាងខាងទិសស្បើយ ឲ្យស្គាល់ទោសពៃ៍អន្ទាយបួន
ចេះការវិន័យយ៉ាងម៉ាំមួន ចេះហាត់ពត់ខ្លួនខាងចរិយា ៗ
ផ្នែកនេះជាភាគមួយយ៉ាងធំ ខាងផ្តល់សង្គមឲ្យថ្លៃថ្លា
កូនខ្មែរដែលបានចូលបព្វជ្ជា សាសនាអប់រំសមគ្រប់កាយ ៗ
ឲ្យចេះគោរពច្បាប់ខុសត្រូវ ស្គាល់គុណម៉ែឪគ្រូបាធ្យាយ
ស្គាល់តូចស្គាល់ធំផងទាំងឡាយ ស្គាល់ញាតិជិតឆ្ងាយមិនវិបត្តិ ៗ
ស្នេហាជាតិសាសន៍ពងពង្ស រូបរម្យកំលាំងថ្មើមប្រម៉ាត់
គាំពាររក្សាព្រះមហាក្សត្រ មិនឲ្យស្ងូនឲ្យបាត់ពីសាវតារ ៗ

ឲ្យបេះដូញចិត្តប្រតិដ្ឋផល ជីកស្រះលើកថ្នល់ផលសាធារណ៍
សាងកុដិសាលាព្រះវិហារ ជួយថែរក្សាការប្រមុខរដ្ឋ ៗ
ដល់សឹកមកវិញចិត្តប្រែពៃ ព្រោះជាប់និស្ស័យដែលហាត់ពត់
មានចិត្តស្លូតត្រង់ក្នុងកម្មបថ ប្រាកដជាប់តាមផ្លូវសាសនា ៗ
បើមិនបានរៀនគង់កើនខុះ មិនមែនស្រឡះបដិអាសា
តាមភ័ព្វនិស្ស័យព្រេងវាសនា តាមបែបដូនតាជាប់តទៅ ៗ
 ដូច្នេះបួសសឹកប្លែកពិសេស ជួយជាតិប្រទេសជាច្រើនផ្លូវ
បើកាន់សាសនាតាមម៉ែឪ នោះត្រូវតែទៀតបួសកុំខាន ៗ
បើមិនបួសយូរប៉ុនតាមសូត្រ ផ្លាស់គ្នាម្តងម្នាក់ឲ្យគ្រប់គ្រាណា
ព្រោះមិនជាធ្ងន់ខ្លួនប៉ុន្មាន ហើយឲ្យយើងបានស្គាល់ច្បាស់លាស់ ៗ
នូវច្បាប់វិន័យពុទ្ធសាសនា នូវច្បាប់ចរិយាខាងធម្មសាស្ត្រ
នូវគោលគំនិតព្រះជាម្ចាស់ នូវភាពកម្រាស់ជម្រៅធម៌ ៗ
កើតមិព្រះពុទ្ធផុតសម័យ ប្តូឲ្យទោសទៅលំអក់ពណ៌
ដល់ជាតិប្រជាពលនិករ ឬក៏ជាធម៌ដឹកនាំសត្វ ៗ

យើងសូមបញ្ជាក់មួយវគ្គទៀត ដោយទៀតជ្រើសយកពាក្យមកស្អាត

ចំពោះបញ្ហាការប្រតិបត្តិ តាមខ្សែបន្ទាត់ពុទ្ធសាសនា ៗ
អ្នកខ្លះបួសហើយលាក់សើយចិល រប៉ូចរប៉ិលវិលសិក្សា
ត្រូវមានទោសពោរដោរហ៊ុំហា មានពាក្យគេថា គ្រប់ទិសទី ៗ

ឲ្យបួសយ៉ាងហ្នឹងបាត់តម្លៃ　នាំតែហិនហោប្រពៃណី
ដូចដែករីងរែះត្រូវច្រេះស៊ី　ល្មេចល្មិចលំលុះឲ្យធ្លុះធ្លាយ ។
　សំដីចាំងនេះយើងរិះគិត　ក៏ឃើញថាពិតឥតប្រែក្លាយ
តែបើរៀបពប់តាមបរិយាយ　យើងអាចដោះស្រាយយ៉ាងនេះថា -
　សាសនាព្រះពុទ្ធបរិសុទ្ធថ្លៃ　ជាទីអាស្រ័យជនគ្រប់គ្នា
គ្មានរើសមុខមាត់ចិត្តយ៉ាងណា　ឲ្យតែជ្រះថ្លាក៏បួសបាន ។
ព្រោះជាសាសនាប្រសើរក្តាត់　របស់មនុស្សសត្វគ្រប់គ្រប់ប្រាណ
ជនណាជ្រះថ្លាក្នុងសន្តាន　ក៏អាចបួសបានដូចដូចគ្នា ។
តែបើបួសហើយល្មើយគំនិត　ប្រព្រឹត្តល្មើសច្បាប់នៃសាសនា
ព្រះពុទ្ធជាម្ចាស់លោកត្រាស់ថា　លោកគ្មានធានាជននោះឡើយ ។
បើគេដាំក្រូចបានផលក្រូច　បើគសាងខូចអាក្រក់ហើយ
មិនអាចចៀសពងផលនេះឡើយ　នេះជាពាក្យឆ្លើយល្មមគ្រប់គ្រាន់ ។
មួយទៀតបើយើងនឹងដោះស្រាយ　ឲ្យឃើញវែងឆ្ងាយមាបច្ចុប្បន្ន
យើងអាចប្រៀបធៀបឲ្យជាក់ស្ទើន　ចែកជាថ្នាក់ជាន់តាមតម្លៃ ។
អ្នកបួសពួកខ្លះក្រាស់ដោយបាប　ប្រព្រឹត្តថោកទាបខុសវិន័យ
ពិតមែន, ប៉ុន្តែបើប៉ាន់ថ្លៃ　ប្រៀបមើលតម្លៃទោសនិងគុណ ។
គង់ឃើញថាគោលការប្រព្រឹត្ត　ជ្រុលខាងសុចរិតច្រើនជាងមុន
គឺមានការធ្វើអំពើបុណ្យ　និងគុណបវរល្អច្រើនណាស់ ។

រីឯការទ្រុស្តទុសបរិយា    ពានត្រៃសិក្ខាដោយឥតខ្លាស
វាជាកាគតូចស្ដួចស្ដើងណាស់    យកមកប្រកាសក៏មិនសម ។
មួយទៀតច្បាប់សង្ឃអគ្គល្អិតខ្ពស់    ជាងច្បាប់គ្រហស្ថខាងអប់រំ
ហើយច្បាប់នេះទៀតជ្រៀតក្រឹត្យក្រម    មានតូចមានធំជាច្រើនស្ថាន ។
ចំណែកអ្នកបួសដែលជ្រួសចិត្ត    ជ្រុលខាងប្រព្រឹត្តបំពាន
បំពោះក្រឹត្យក្រមធំប្រធាន    ក៏លោកមិនហ៊ានបំពានដែរ ។
ជ្រុលជ្រួសថ្មោះធ្លោយដោយនិស្ស័យ    ត្រឹមតែទោសតៃគួរស្ដីដេរ
គ្រង់ហ៊ានជាខ្នាំងនឹងច្បាប់ខ្មែរ    យើងឃើញហើយដែរកម្រណាស់ ។
កំហុសតិចតួចស្ដួចស្ដើងហ្នឹង    បើគៃលៃថ្លឹងគង់ឃើញច្បាស់
វានៅតែត្រង់ត្រូវល្អណាស់    ជាងគ្រឹហាវាសផងទាំងឡាយ ។
គ្រហស្ថអស់ត្រឹមច្បាប់ផែនដី    ក្រៅនេះសេរីមានទូលាយ
ចង់ធ្វើយ៉ាងម៉េចហៅសប្បាយ    ក៏គ្មានគិតកាយក្រែងអាបត្តិ ។
រឿងស្រីរឿងស្រាបាក់ច្រៀង    ស្ដាប់សូរស័ព្ទសៀងច្រៀងប្រតិព័ទ្ធ
ស្រែកហ៊ោកញ្ជ្រៀវពុំក្រែងមាត់    ដើរលាត់ដើរស៊ើយតាមចិត្តចង់ ។
ដើរលែងលំហែក្បែរមុខវាំង    ក្រៀបត្រាលើតាំងកៅអីបង់
មើលកុនមើលល្ខោនឡូកឡំវង់    ធៀតដើរថែចង់ផ្លូវស្នេហា ។
មានប្ដីប្រពន្ធរួមស្នេហ៍ស្និទ្ធ    ផ្ដេកផ្ដិតផ្លូវកាមតាមប្រាថ្នា
ជិះកង់ជិះឡានស្រែកឡូឡា    ចង់ធ្វើយ៉ាងណាក៏គ្មានភ័យ ។

គ្មានគិតគិតក្ដុកនឹកនាំក្រែង　　អាបត្តិអាប្រែងច្បាប់វិន័យ
ឯលោកសង្ឃវិញគ្មាននិស្ស័យ　　លោកគ្មានអស់ដៃអីដល់ម្ទឹង ៗ
បើធៀបប្រៀបប្រឹតចិត្តជាបុណ្យ　　ផញ្ជួងទោសគុណទប់ទល់ថ្លឹង
រវែកដូចចែងថ្លែងអីចឹង　　ពណ៌នាបុណ្ណឹងជាទំនង ៗ
ប៉ុន្តែសូមមិត្ររួមសាសនា　　យល់ឲ្យច្បាស់ថាការខុសត្រង់
របស់អ្នកបួសទាំងនោះផង　　ទោះជាសៅហ្មងតូចក៏ដោយ ៗ
ក៏ច្បាប់វិន័យកាត់ក្រិតទោស　　មិនដែលសន្ដោសអនុគ្រោះឲ្យ
លោកដែលប្រព្រឹត្តចិត្តថ្លោះធ្លោយ　　ត្រូវប្រែកែក្រោយឲ្យស័ក្តិសម ៗ
ពីព្រោះករណីយកិច្ចលោកសង្ឃ　　ដោយត្រង់គឺដៅការអប់រំ
ឲ្យល្អចរិយាជាប្រថម　　ទើបគេមកទំប្រឹងអត់បាយ ៗ
ចុះបើមកបួសជ្រួសបណ្ដោយ　　បណ្ដែតចិត្តឲ្យនៅរាយមាយ
ធ្វើតាមតែចិត្តគិតសប្បាយ　　យកតាមតម្រាយត្រឹមហាក់ស ៗ
ការបួសចិញ្ចឹមចិត្តដូច្នេះ　　ពិតជាគ្មានខ្លះគួរឲ្យខ្មាស
បួសតាំងពីក្មេងរៀងដល់ចាស់　　គ្មានផ្លាស់ចរិយាមារយាទប្រាណ ៗ
ការបួសនោះទៀតក៏គ្មានន័យ　　មានតែទោសពៃរ៍អន្តរធាន
ការខ្វះក៏ខាតជាតិក៏ខាន　　បង់បាយមិនបានប្រយោជន៍អ្វី ៗ
អ្នកបួសលោកដ៏ខ្វះយ៉ាងនេះ　　បានជាលោកបេះតាំងស្មារតី
ប្រព្រឹត្តអប់រំតាំងតាស់ថ្មី　　ឃើញគួរគប្បីមិនសូវត្រង់ ៗ

អ្នកស្រែធ្វើស្រូវរដូវកាល ស្ទុះស្ទាស្រើបស្រាលដោយបំណង
ចង់បានផលច្រើនជាងមិត្រផង ដោយនូវគន្លងផ្លូវសុចរិត ។
រីឯអ្នកបួសក៏ដូច្នោះ ប្រឹងប្រែងក្រោយដោះខាងផ្លូវចិត្ត
យកជ័យជំនះឈ្នះអស់មិត្រ ដោយការប្រព្រឹត្តិអប់រំប្រាណ ។
អស់មិត្រទាំងឡាយរួមសាសនា មានចិត្តជ្រះថ្លាដែលបានអាន
សូមមិត្រមេត្តាកុំខាន នឹកស្មានថាខ្ញុំក្រុមទៅក្រោយ ។
ខ្ញុំក្រងចងជាបទបរិយាយ នេះគឺដោះស្រាយការថ្លោះធ្លោយ
ដែលអស់យុវជនជំនាន់ក្រោយ បណ្ដោយតាមចិត្តបំបិទគុណ ។
មិនបើកឲ្យឃើញភាគផលល្អ ដែលកកើតពីរស្រែបុណ្យ
ជាដែនដំរេកមកពីមុន ជាគុណជួយកែកូនខ្មែរអើយ ! ។

—ចប់—

ផ្ចាញ់កាចដោយការធ្វើកាចតប
ផ្ចាញ់អបដោយអាបធ្វើអប ត
ផ្ចាញ់ល្អដោយល្អិតធ្វើចិត្តល្អ
ផ្ចាញ់ក្រដោយតស៊ូធ្វើខ្ជាប់

ដ - ឌ

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគង់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ
ប.គ.

## ពិចារណាដើម្បីយល់តក្កវិជ្ជា

(ត)

លោក ហ៊ុន គិមសៀ រៀបរៀង

យើងទាំងអស់គ្នាពិនិត្យតាមឧទាហរណ៍នេះ ក៏អាចយល់បានភ្លាមថា នេះហើយមកអំពីការសួរគ្មានវិធាន សួរច្របូកច្របល់ អាងតែខ្លួនផ្ទុំពុកបេះតែសួរមិនគិតគូរ ពាល់តែជាប់នឹងសំនួររបស់ខ្លួនវិញ ។ និយាយសង្ខេបមកវិញគឺថា យើងទាំងអស់គ្នាសុទ្ធតែទទួលយល់ព្រមថា មានវិធានមែនក្នុងការរៀបចំគំនិត ដើម្បីនិយាយឲ្យបានត្រឹមត្រូវនិងជាក់លាក់ ពីព្រោះថាសំដីជារូបភាពនៃគំនិត បើគំនិតសាំញ៉ាំច្របូកច្របល់គ្មានក្បាលកន្ទុយ . . . តើសំដីយើងមានសណ្ដាប់ធ្នាប់ក្បោះក្បាយទៅម្ដេចកើត ។ ការនិយាយចេញទៅ គេស្ដាប់មិនបាននេះហើយដែលអ្នកប្រាជ្ញបណ្ឌិត គេចងក្រងទៅជាក្បួនសម្រាប់សិក្សាដែលយើងហៅថា តក្កវិជ្ជា គឺជាវិជ្ជារៀបចំគំនិត ទុកដាក់សំដីដើម្បីនិយាយឲ្យបានជ័យជំនះ ។

# វិធានកើតពីណាមក ?

ខាងលើ យើងបានអធិប្បាយរួចមកហើយ ក្នុងការនិយាយទាក់ទងគ្នា មនុស្សយើងគេប្រើសំដី ។ និយាយដល់សំដី, មានតក្កវិទូម្នាក់មានយោបល់ថា : " សំដីជាឧបករណ៍នាំឲ្យមនុស្សអាចយល់គ្នាបាន " " ការវិវត្តន៍ជឿនលឿនគ្រប់ផ្នែក ជាពិសេសគឺខាងផ្នែកគំនិតបញ្ញារបស់មនុស្សមួយភាគធំដែលរស់នៅក្នុងសង្គម ក៏អាស្រ័យមកតែអំពីសំដីគំនិតដែលគិតតែឯង ៗ ប្រាសចាកសំដី ប្រាសចាកសម្ភារៈ គឺមិនអាចទុកជាធរមានបានទេ " ។

បើយើងធ្វើការពិចារណាចំពោះការទាក់ទងយ៉ាងជាក់ស្តែងខាងលើនេះ, យើងទាំងអស់គ្នាយល់ថា : សំដីជាសំបកខាងក្រៅ ទុកដូចជារូបភាព សតិអារម្មណ៍ ( គំនិត ) នៅខាងក្នុង ទុកដូចជាអត្ថរសឬខ្លឹមសារនៃសំដី ។ គឺចាប់ពីត្រង់នេះទៅហើយដែលនាំឲ្យកើតជាបញ្ហាមានរូបភាព ( សំដី ) និង អត្ថរស ( គំនិត ) ហើយតក្កវិជ្ជារូបភាពក៏ជាវិជ្ជាសិក្សាអំពីរូបភាពនិងវិធានប្រើរូបភាពពោលគឺសំដី ដែលលាតត្រដាងនូវគំនិតខាងក្នុង ឲ្យចេញមកក្រៅនោះ ។ តាមធម្មតា រវាងរូបភាព និងអត្ថរសច្រើនមានការផ្ទុយគ្នា គឺថា សំដីនិយាយដែលចេញមកក្រៅ ជួនកាលមិនអាចបកស្រាយនូវគោលគំនិតខាងក្នុងឲ្យបានក្បោះក្បាយត្រឹមត្រូវទេ ពីព្រោះតែយើងមិនយល់វិធានសម្រាប់ប្រើសំដី ហេតុ

នេះហើយបានត្រូវមានតក្កវិជ្ជារូបភាពពន្យល់ឲ្យយើងយល់នូវ "វិធាន" ក្នុងការប្រើរូបភាពពោលគឺសំដីនោះឲ្យបានជាក់លាក់ហ្មត់ចត់ មានសមត្ថ-ភាពអាចបកស្រាយពន្យល់នូវគំនិតខាងក្នុង ឲ្យបានត្រឹមត្រូវ ។ មនុស្សមានគំនិតល្អ, តែបើសំដី មិនអាចបកស្រាយបានគំនិតល្អនោះទេ អ្នកដទៃក៏គេមិនអាចយល់នូវលក្ខណៈល្អបានរបស់យើងបានដែរ, ហេតុនេះ តក្កវិជ្ជារូបភាព មានភារៈទទួលខុសត្រូវនៅក្នុងវិស័យនេះឯង ។

## តើរូបភាពនិងវិធានត្រិះរិះនៃតក្កសាស្ត្ររូបភាព វាយ៉ាងណាខ្លះ?

តក្កសាស្ត្ររូបភាពមានសមត្ថភាពសិក្សា, ពិចារណានូវរូបភាព និង វិធានតុបតែងគំនិត ដើម្បីលាតត្រដាងសតិអារម្មណ៍ឬបំណងរបស់ខ្លួនឲ្យបានជាក់លាក់យ៉ាងទៀងទាត់ ។ ដូច្នេះ, តក្កសាស្ត្ររូបភាព មិនសូវជាសំគីដល់អត្ថរសនៃបញ្ហាប៉ុន្មានទេ, សំគីពិចារណាតែអំពីវិធាននៃការលាតត្រដាងពោលគឺការលេងសំដីច្រើនជាង បានសេចក្ដីថា : តក្កសាស្ត្ររូបភាព ពុំមែនមិនដឹងដល់អត្ថរសនៃបញ្ហាអ្វីបន្តិចបន្តួចនោះទេ, ប៉ុន្តែភារៈរបស់វា ត្រូវត្រិះរិះខាងរបៀបប្រើសំដី ខាងការលេងវោហារឲ្យបានសមរម្យនិងត្រឹមត្រូវ ច្រើនជាង ។

និយាយថា តក្កសាស្ត្ររូបភាព ដែលមានដំណើរ ឬ និទ្ទាការ តែខាងប្រើសំដីនោះ តើមានន័យយ៉ាងដូចម្ដេច ?

ដើម្បីឲ្យងាយយល់ យើងសុំជូនឧទាហរណ៍ខ្លះ ៗ នៅក្នុងវិស័យ

អក្សរសិល្ប៍ (Domaine littéraire) មកបញ្ជាក់ដូចត ៗ ៖

វណ្ណកម្មអក្សរសិល្ប៍ (Œuvres littéraires) មានអត្តរសនិងរូបភាពរបស់វា ៗ អត្តរស មានរាប់រយរាប់ពាន់ ប៉ុន្តែក៏សំដែងចេញលេចឡើងដោយរូបភាព ជា កំណាព្យ, ជារឿង, ជាប្រលោមលោក, ឬ ជារូបភាពផ្សេង ៗ ។ល។ បានសេចក្តីថា : តក្កសាស្ត្ររូបភាពត្រូវទទួលខុសត្រូវធំ ចំពោះវិធីតែង, របៀបចងក្រងកំណាព្យ, របៀបនិពន្ធ.... ចំណែកឯអត្តរស ក៏មានខុសមានត្រូវ អនុលោមទៅតាមទស្សនៈនៃអ្នកនិពន្ធនោះ តក្កសាស្ត្ររូបភាពមិនសូវទទួលខុសត្រូវប៉ុន្មានទេ ទុកឲ្យវិទ្យាសាស្ត្រដែលមានសមត្ថកិច្ច ឬមុខងារនាទីដូចជាទស្សនវិជ្ជា (Philosophie) គេវិនិច្ឆ័យទៅចុះ ។

ដើម្បីឲ្យងាយយល់, យើងសុំលើកយកឧទាហរណ៍ មនុស្សខ្វាក់ ៤ នាក់ ជជែកគ្នាអំពីរូបដំរី មកពិចារណា :

ក– ១– ដំរីដូចឈើង

២- ដំរីដូចសសរផ្ទះ

អាពីរនាក់ទៀតត្រឡប់ ជានិយាយថា :

ខ – ១– ដំរីដូចសសរផ្ទះ

២– ដំរីមិនដូចសសរផ្ទះទេ

ក្នុងករណីទាំងពីរខាងលើនេះ តើមិត្តយល់ថា ក៏មានយោបល់

ខុសគ្នាយ៉ាងណា ? តើយើងអាចយកក្បួនតក្កសាស្ត្រ ទៅប្រើក្នុងការនិយាយ ជាមួយមនុស្សម្នាក់ទាំងនោះរបៀបណា ក្នុងពេលដែលយើងមិនស្គាល់សត្វដំរីដូចគ្នា ។

ការពិត ក្នុងករណីដែលយើងមិនស្គាល់សត្វដំរីដូចគ្នានោះ យើងពុំអាចយករបៀបតក្កសាស្ត្របុរាណទៅប្រកែកការកាត់ អំពីរូបរាងដំរី ថាជាយ៉ាងនេះឬយ៉ាងនោះបានទេ ប៉ុន្តែមនុស្សម្នាក់ពីនាក់ឆ្លើយក្នុងករណី " ៣ " តក្កសាស្ត្របុរាណអាចយល់បានថា : ចម្លើយនោះខុសទាំងពីរនាក់ ពីព្រោះឆ្លើយក្នុងរង្វង់ចង្អៀត ។ ចំណែកឯក្នុងករណី " ១ " វិញ គឺតក្កសាស្ត្របុរាណអាចយល់បានថាមានមួយត្រូវ មួយខុស ពីព្រោះចម្លើយថា " ដំរីមិនដូចសសរផ្ទះទេ " ក៏ខូចណាយជាង ក៏ឆ្ងាយត្រូវជាង ។ ការពិត ដំរីក៏ដូចអី ក៏ដូចទៅ ឲ្យតែខុសពីសសរផ្ទះ អាចត្រូវនឹងចម្លើយយើងបាន ពីព្រោះចម្លើយយើង មិនបានបញ្ជាក់អះអាងជាដូចនេះឬ ដូចនោះ . . . ។ល។

ចំពោះករណីទូទៅ បើមានគំនិតផ្ទុយគ្នាបែបដូច " ១ " ខាងលើ, តក្កសាស្ត្របុរាណបើកច្បាប់ឲ្យយើងឆ្លើយតែត្រឹម " មានមួយខុស មួយត្រូវ " ប៉ុណ្ណោះទេ តែត្រង់បញ្ជាក់ថា : អ្នកណាមួយខុស អ្នកណាមួយត្រូវគឺតក្កសាស្ត្រមិនឲ្យបញ្ជាក់ទេ ។ ( ប្រការនេះនឹងនិយាយច្បាស់ក្នុងជំពូកក្រោយ ) ។

## វិធានសំខាន់ៗ នៃតក្កសាស្ត្ររូបភាព

តក្កសាស្ត្ររូបភាពចងក្រង និងលាតត្រដាងឡើង នូវរូបភាព, នូវវិធីប្រើសំដី, នូវវិធានគ្រឹះនៃគំនិត . . . ហេតុដូច្នេះ បន្តទៅនេះ យើងនឹងសិក្សាម្តងមួយ ៗ នូវប្រការសំខាន់ ៗ នៃតក្កសាស្ត្រ ។

តក្កសាស្ត្ររូបភាពបានអះអាងថា : គំនិតណាមួយដែលសមរម្យ ហើយត្រឹមត្រូវ គឺជាគំនិតដែលគ្មានការផ្ទុយ សំដីជាក់លាក់, ក្បោះក្បាយ, មានហេតុផល, ហើយមានឯកភាព . . . ។ ផ្ទុយទៅវិញ, បើគំនិត ឬពាក្យសំដីណាដែលមានការខ្វែងយោបល់ខាងក្នុង, និយាយតាប់ចុងព្រយុងដើម មិនច្បាស់លាស់ . . . មិនអាចនាំជ័យជំនះ ឬ នាំការបេះដឹង ឬ កំពន្យល់បញ្ហាណាមួយបានលទ្ធផលទេ ពីព្រោះគំនិតយើងខុស, វិធីប្រើសំដីកមិនច្បាស់ ស្រពិចស្រពិលនាំឲ្យគេច្រឡំ . . . ។ល។ ពីព្រោះតែសេចក្តីត្រូវការឲ្យបានច្បាស់លាស់នៃគំនិតរបស់យើង ក្នុងការប្រើសំដីនេះហើយ, បានជាតក្កសាស្ត្ររូបភាព បានចងក្រងឡើងជាវិធាន ៤ យ៉ាង ដែលគេហៅថា វិធានជាមូលដ្ឋាននៃតក្កវិជ្ជា គឺមាន:

១ - វិធានឯកភាព (Le principe d'identité)

២ - វិធានផ្ទុយ ( Le principe de contradiction )

( អាចហៅថាវិធានមិនផ្ទុយក៏បាន )

៣– វិធានកាត់ចោលអាទីបី ឬវិធានកណ្ដាល

– Le principe du milieu ou tiers exclu

៤– វិធានតាមហេតុផល ឬ វិធានមានហេតុផលគ្រប់គ្រាន់

– Le principe des Raisonnements biens complets

ហើយម្យ៉ាងទៀត . តក្កសាស្ត្របុរាណ នៅមានពិចារណាដល់អត្តរូប (Forme) នៃការត្រិះរិះទៀត ដូចជា :

ការយល់ Concept

ការវិនិច្ឆ័យ Jugement

ការសន្និដ្ឋាន Déduction

នៅចុងក្រោយបង្អស់ តក្កសាស្ត្របុរាណនិយាយដល់បញ្ហាភស្តុតាងបញ្ជាក់ ។

មនុស្សយើងទាំងអស់គ្នា គ្មានអ្នកណាកើតឡើងហើយស្រាប់តែចេះពូកែតែម្ដងនោះទេ ការចេះដឹងតែងកើតមកពីការរៀនសូត្រដោយស្វិតស្វាញម្ដងបន្តិច ៗ ។ ហេតុនេះ រឿងតក្កវិជ្ជា ចំពោះមិត្តខ្លះ ដែលមិនបានធ្លាប់ត្រចៀកនឹងវិជ្ជានេះ មិនអាចគេចផុតពីការពិបាកស្ដាប់ទេ ប៉ុន្តែយើងខ្ញុំជឿថា : បើមិត្រត្រាំលំបាក អានម្ដងបន្តិច ៗ ទំ ប្រឹងពិចារណាឱ្យយល់បាន យើងជឿថាវិជ្ជានេះនឹងមានប្រយោជន៍ច្រើនដល់ការនិយាយស្ដីរបស់មិត្តក្នុងអនាគត ។

## ជំពូកទី-២

# ពិចារណាគឺជាអ្វី?

## ពិចារណាគឺជាចលនានៃខួរក្បាលដើម្បីការចេះដឹង

យើងទាំងអស់គ្នាកំពុងតែសិក្សាតក្កសាស្ត្រ, តក្កសាស្ត្រគឺជាវិជ្ជាសាស្ត្រនៃការពិចារណា; ដូច្នេះ យើងទាំងអស់គ្នា គួរបានយល់អំពីការពិចារណាតើវាជាអ្វីសិន ជាមុនដែរ ។

## ពិចារណាគឺជាអ្វី?

ខ្ញុំបានឃើញសិស្សខ្លះអង្គុយសម្លឹងមើលដំបូលថ្នាក់, សិស្សខ្លះចងចិញ្ចើម, ច្របាច់ថ្ងាស, មានសិស្សខ្លះទៀតទាំងដងប៉ាកកាលេង ។ល។ បើកាលណាយើងសួរគេ គេនឹងឆ្លើយប្រាប់យើងថា: គេកំពុងតែពិចារណា គេពិចារណាមិនទាន់ឃើញ (ខ្ញុំសុំប្រើពាក្យគិតជំនួសពិចារណា) ។

កាលណាយើងគិតអ្វីមួយមិនឃើញវាហាក់ដូចជាខួរក្បាលយើងគ្មានចលនា គឺជាខួរក្បាលយើងវានៅស្ងៀមមួយកន្លែង ។ វាមិនខុសគ្នានឹងម៉ាស៊ីនឡានខូច បើចង់ឲ្យវាទៅមុខទៀត មនុស្សត្រូវតែរុញវា ។ កាលណាគិតមិនឃើញ មនុស្សយើងខំប្រឹងគិត : ដៃស្ទាបក្បាល ច្របាច់ថ្ងាស . . . ហាក់ដូចជារុញច្រានខួរក្បាលយើងឲ្យវាលឿនទៅមុខមួយគ្រឹត បើយើងពិនិត្យមើលរូបភាពខាងក្រៅយើងនឹងឃើញថា : ការគិតគឺជាចលនានៃខួរក្បាល ។

បើមិត្តណាធ្លាប់បានយល់វិជ្ជាបដិច្ចសមុប្បាទ ( Dialectique ) ខ្លះ ។ ពីមុនមកហើយ គេមុខជាទំនងយល់ថា បាតុភូតទាំងអស់សុទ្ធតែជាសភាវៈចលនា ។ គំនិត គឺជាបាតុភូតធម្មជាតិ ហេតុដូច្នេះគំនិត ក៏មិនមែនជាចលនាឯណាបាន ? ។

តែនិយាយដល់ចលនាហើយ គឺយើងត្រូវនិយាយដល់សម្ភារៈហើយ ពីព្រោះសម្ភារៈទើបក៏មានចលនា ។

ក្នុងរឿងគំនិត Pensée នេះ យើងខ្ញុំនឹកទៅដល់ឃ្លាមួយដែលគេច្រើនតែនិយាយថា : « ខ្ញុំគិតល្អិតម៉ត់អស់ហើយ » ។ ពាក្យថាល្អិតម៉ត់ នាំឲ្យខ្ញុំនឹកឃើញទៅដល់រឿងកិនម្សៅ គឺថាកិនអង្ករឲ្យល្អិតម៉ត់ទៅជាម្សៅ ។

និយាយមកដល់រឿងកិនម្សៅនេះ ខ្ញុំសុំទោសមិត្តអ្នកអានបើករង្វង់ក្រចកមួយ ។ គឺថា : មិត្តក៏ធ្លាប់បានអានសៀវភៅតក្កសាស្ត្រជាអក្សរបរទេស អ្នកនិពន្ធជាតិណាមួយ បើគេសរសេរគឺគេបម្រើផលប្រយោជន៍ខាងគំនិតរបស់ជាតិគេ គេយកឧទាហរណ៍ណាដែលមានលក្ខណៈស្របទៅតាមសមត្ថភាពនៃប្រជាជនស្រុកគេ ពោលគឺលក្ខណៈនៅក្នុងស្រុកដូច្នេះ ក្នុងករណីពន្យល់រឿងចលនា យើងខ្ញុំសុំយកឧទាហរណ៍ជាក់ស្តែង ដែលប្រជាជនយើងភាគច្រើនធ្លាប់បានប្រទះកន្លងមក ដើម្បីឲ្យងាយយល់ដូចជារឿងកិនម្សៅនេះ ។

កិនម្សៅគឺជាចលនាមួយ គឺចលនារបស់ត្បាល់កិនអង្ករឲ្យល្អិតម៉ដ្ឋទៅជាម្សៅ ហេតុនេះបើយើងប្រៀបធៀបទៅនឹងការគិតគឺយ៉ាងដូច្នេះ ៖ គិតគឺជាចលនានៃខួរក្បាល ( ខួរក្បាលជាសម្ភារៈ ) ដែលយើងទុកដូចជាត្បាល់នៅខាងលើ ។

ចង់កិនម្សៅត្រូវមានអង្ករយកទៅកិននឹងត្បាល់ ហេតុនេះ ចង់គិត មនុស្សក៏ត្រូវមានបញ្ហា, ចំណោទ . . . ដើម្បីគិតអំពីដែរ ខួរក្បាលមនុស្សមិនអាចគិតទទេ ៗ បានទេ ។ រឿងរ៉ាវ, ចំណោទ, បញ្ហាទាំងអស់នេះ គឺជាសម្ភារៈ ដែលវិញ្ញាណរបស់យើងទទួលបានមកធ្វើឧបករណ៍សម្រាប់ឲ្យខួរក្បាលគិត ។ និយាយសង្ខេបមកវិញបានសេចក្ដីថា ៖ គិតគឺជាចលនានៃខួរក្បាលផ្អែកទៅលើសម្ភារៈខាងក្រៅជាមូលដ្ឋាន ដើម្បីធ្វើយ៉ាងណាឲ្យមនុស្សយល់បាននូវធាតុពិតទាំងអស់នៅក្នុងប្រព័ន្ធទាំងមូល ។

ប្រការនេះសំខាន់ណាស់ សព្វថ្ងៃនៅលើសាកលលោកទាំងមូលក៏មានការប្រកែកប្រណាំងគ្នាមិនចេះចប់មិនចេះអស់ពីរឿងសម្ភារៈ និងគំនិតនេះដែរ ដែលគេសាប៉ាក់ហៅថាពួក Matérialisme dialectique និងពួក Idéalisme métaphysique ( ពួកសម្ភារៈនិយមបដិច្ចសមុប្បាទ និងពួកគំនិតនិយមបរមត្ថសាស្ត្រ ) ។

(នៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

ព្រះមហា ចាំង-ខាត់ រៀបរៀង

---

-សានុ ក្រ.វិ. ឮដ៏ជំរៅនៃភ្នំ ។ -សារ គុ. ដែលមានសារៈឮដ៏ខាងក្នុង ។ ន.បុ. ភាពខាងក្នុង; ពល.ខាងក្នុង, ទ្រព្យដែលកប់ទុក, បម្រុក ។ -សុខ គុ. ដែលមានសេចក្ដីសុខឮដ៏ខាងក្នុង ។ -ស្ថ គុ. ដែលឋិតនៅខាងក្នុង។ -ស្បឝ៌ គុ ដែលប៉ះពាល់ឮដ៏ខាងក្នុង ។ -ស្មេរ គុ. ដែលសើចឮដ៏ខាងក្នុង ។ -អន្តស្ចរ គុ. ដែលកម្រើកខាងក្នុង, ដែលនៅក្នុង ។ -អន្តស្តាប ពុ. ភ្លើងខាងក្នុង, គុ. ដែលដេះឮដ៏ខាងក្នុង ។ អន្តស្តុហាវ គុ. ដែលមានដំណក់ទឹកឮដ៏ខាងក្នុង ។ --អន្តស្តោយ គុ. ដែលមានទឹកឮដ៏ខាងក្នុង ។

អន្តរ គុ ដែលជាខាងក្នុង, ដែលនៅជិតខាង, ជំនិត, ស្និទ្ធស្នាល ។

នបុំ ខាងក្នុង, ទីចន្លោះ, រន្ធ, ។ ចម្រក, ទីចន្លោះ ។
កាល, សម័យ, ភាគ ។ សមាជិកកណ្តាល ។ ១, សេចក្តី ។
ចម្ងាយ, ភាពឆ្ងាយ, ភាពទីទៃពីគ្នា ។ អាការពិសេស,
ឱកាស, ទោសដាចន្លោះ, ការរោគា ។ —គត គុ.
ដែលនៅចន្លោះ, ដែលនៅឆ្ងាយ , —ចារិន៍ គុ. ដែល
ត្រេចទៅឆ្ងាយ ។ —ជ្ញ គុ. ដែលដឹងទៅខាងក្នុង,
ដែលដឹងច្បាស់ ។ —ទស្សី ដែលឃើញនូវកណ្តាល ។
—បតិត គុ. ដែលធ្លាក់ក្នុងចន្លោះ, ដែលបាត់, ដែលមិន
មាន ។ —បុរុឞ ប៉ុ. (បុរសខាងក្នុង) —អាត្មន៍
ព្រលឹង ។ —ប្រភវ (ដែលកើតក្នុងចន្លោះ) ប៉ុ. វណ្ណៈ
លាយគ្នា ។ —ប្រេក្សិន៍ គុ. ដែលមើលឃើញទោសដា
ចន្លោះ ។ —ស្ថ គុ. ដែលឋិតនៅជាចន្លោះ, ប៉ុ. សាក្សី ។
អន្តរាន្វេសិន៍ គុ. ដែលស្វែងរកទោសដាចន្លោះ, ដែល
ចាំឱកាសដាទំនង ។ —អន្តរាគមន៍ នប៉ុ. កិរិយាចូល ។

–អន្តរាទិស ស្ត្រី. ទិសជាចន្លោះ ។ –អន្តរាវេទិ ស្ត្រី របៀង, ជញ្ជាំងខាន់ ។ –អន្តរវេបរ គុ. ដែលចរនៅក្នុងផ្ទះ ។

អន្តរាល នបុ. ពេលជាចន្លោះ, ខាងក្នុង ។ គុ. ដែលនៅជាចន្លោះ អន្តរាលេ ក្នុងពេលកំពុងដើរ ។

អន្តរ-តិ ធាតុ ទៅក្នុងចន្លោះ, លាក់, ញែក ។

អន្តរិក្ស នបុ. អន្តរិក្ស ទីចន្លោះឰដ៏អាកាស, អាកាស, មេឃ ។ –ក្សិត គុ. ដែលនៅលើអាកាស ។ –លោក បុ. អន្តលោក មេឃ, ។ –សទ៑ គុ. ដែលនៅលើមេឃ ។ –អន្តរីក្សគ គុ. ដែលទៅតាមអាកាស, បុ. បក្សី ។

អន្តរីយ នបុ. អន្តរីយ អាវទ្រនាប់ ។

អន្តជ្វល ធាតុ ឆេះខាងក្នុង, ភ្លឺខាងក្នុង ។

អន្តទ៌ហ៍ ធាតុ ឆេះខាងក្នុង ។

អន្តធា ធាតុ លាក់, ទុក, លាក់ទុក, បំបាត់ ។

អន្តភិតិ ធាតុ ធ្វើការល្បត់ ។

អន្តភ៌ ធាតុ ជ្រាបចូល, នៅខាងក្នុង ។

អន្តព្រាម្យ ធាតុ ធ្វើឲ្យទន់ខ្សោយ ។

អន្តវត្នី ស្ត្រី. ស្ត្រីមានគភ៌ ។

អន្តវសិ ធាតុ នៅខាងក្នុង ។

អន្តវិគ្គ គុ. ដែលមានទីបំផុត, ដែលកន្លងទៅ ។

អន្តស្វ៌ ធ.គុ គ្របពេញខាងក្នុង ។

អន្តិ អាយត. ទៅជិត, ផ្ទុយ ។

អន្តិក ដែលទៅដល់ទីបំផុត ។ នបុ. ការទៅជិត ។

អន្តិម គុ អ្នកចុងបំផុត ។

អន្ត្យ គុ ដែលចុងបំផុត. វណ្ណ.ចុងក្រោយ ។ –កម៌ន៍ នបុ. អន្តកម្ម ការរំលាយសព ។ –ជ គុ. បុ. អ្នកកើតក្នុងវណ្ណៈក្រោយបំផុត, –ឧត្តម –យោនិ ដូចគ្នា ។

( នៅមានត )

# ព្រះរាជនិពន្ធរាមកេរ្តិ៍

ភាគ ១២

(ក)

ពេភក ទឹក-ពាម

ស្រាវជ្រាវ និង រៀបរៀង

និយាយតាំងតែពីព្រះបាទធតរដ្ឋ ក្រោយដែលបានតែងពិធីអាពាហ៍ពិពាហ៍ព្រះរាមរួចហើយ ក៏លើករេហ៍ពលវិលត្រឡប់ទៅនគរវិញ ប្រទះជួបនឹងរាមេសូរ ច្បាំងគ្នានឹងរាមេសូរ ។ បាញ់ រហូតដល់រូភីនិងទូភា ។ ស្លាប់ ទូភីទៅច្បាំងនឹងពាលី ។ សម្លាប់ទូភីស្លាប់ ។

*កាលនោះ ព្រះរាមសុរិវង្ស បានស្តាប់ពាក្យអសុរស្តីហើយ ទើប ព្រះអង្គឆ្លើយតបទៅវិញថា ខ្លួនឯងនេះ ចង់ដណ្តើមយកនាង ហើយ មកអួតអាងថា មានឫទ្ធានុភាពខ្លាំងក្រៃ ឯងមិនបានដឹងគេដៃអញនេះ គឺព្រះនារាយណ៍បែងភាគ ចុះមកកើតជាព្រះរាមា នឹងប្រហារផ្ចាញ់ពួក ពាលកុម្ភ័ណ្ឌ ដែលមានចិត្តទុច្ចរិតឫស្យា ឯងនេះឈ្មោះអ្វី បានជា អហង្ការក្លាហាន មិនដឹងប្រាណនឹងក្ស័យសូន្យអស់ហើយ ៗ កាលនោះ រាមសូរអសុរក្លាហាន បានស្តាប់វាចាហើយ ក៏ក្តៅក្តួលឆួលឆេះក្នុង វិញ្ញាណញ័រអស់អង្គកាយា ហើយក៏ទះហត្ថាលាន់ឮផ្ទាំងកាំងគ្រហារ ហើយឆ្លើយតបទៅវិញថា ខ្លួនអញនេះ ឈ្មោះរាមសូរទេវេស មាន រិទ្ធិតេជៈដៃក្រពេកណាស់ ខ្លួនឯងជាមនុស្សប៉ុនស្រមោចសត្វ ហេតុដូចម្តេច ក៏ហ៊ានអួតថានារាយណ៍បែងភាគចុះមក ឯងនេះ ប្រៀបគណនាបីដូច*

ជាសត្វអំពិលអំពែក មកអួតពន្លឺឲ្យភ្លឺស្មើនឹងព្រះសុរិយា ហើយនៃមនុស្ស ឯងកុំអាលអួត អម្បាលតែអង្គព្រះអរជុនគា មានរិទ្ធាក្រៃ ក៏គង់ក្ស័យរលត់មិនខានដោយអញ ឯងនេះ បើទុកជាព្រហ្ម ក៏ដីរឯងគង់តែនឹងក្ស័យរលត់ផុតសង្ខារ ជាហើយ ក៏តន្ត្រំបាទាកក្រោកទាំងប្រឹថពីគ្រីក្រឡឹងឥតូថៅពេជ្រ គេចវិញខ្លាល់ ដូចកញ្ហាល់កញ្ហារវែក សម្តែងឫទ្ធិទាំងព្រះសុរិយាអរុណោទ័យ មិនឃើញនៃខ្ទមស្រុក អាកាសវេហាស៍ក៏បណ្តាលលាន់ឮគ្រឹកគ្រែង កក្រើកទាំងនៃព្រព្រឹក្សជាគោលាហល រន្ធះអសនីក៏បន្លឺសព្ទអឺតអស់ទាំងទសទិសា ។ កាលនោះ ទាំងបីមហេសីអគ្គជាយា ទាំងអង្គអគ្គវេតសីតា នូវអស់ហ្វូងកំណាន់ស្រីស្រីង្គាររហោជាពលាករ បានឮសូរសព្ទសម្ទីងគគ្រឹកគគ្រេងកក្រើកទាំងនៃព្រព្រឹក្សពនារ៉ែន ផងខ្លបរំងាំងពនាក់មាគ៌ាស្ថាន អាកាសវេហាស៍ក៏ខ្មៅខ្មូលផង្គាលដង្គុំ ផងឹតទាល់មើលមិនយល់គ្នា ដូចរាត្រីយប់ ព្រះនាងទាំងបី ក៏ភ័យភិតស្មើនឹងក្ស័យជីវិត ហើយស្រែកអឺងកងរំពងទាំងនៃព្រព្រឹក្សព្រះអង្គក៏ប្រាប់ថា មានពួកកុម្ភ័ណ្ឌមកតតាំងច្បាំងជាញជ័យ ទើបក្សត្រថ្ងៃមានព្រះរាជ ទៅនឹងព្រះរាជមហេសីទាំងបីថា ម្នាលនាងទាំងបី កុំនាងមានសេចក្តីស្ងួតរន្ធត់ឡើយ ថ្មើមអើយ ចូរនាងរង់ចាំមើលរិទ្ធិព្រះរាមកូនសម្លាញ់យើងសិន ។

កាលនោះ ព្រះនាគយណ៌ហាវង្សក្រុងចក្រនោះ លុះឃើញខាង

សីកាយ៉ៅម៉ិត្តភ័យភិតតក្កមាដូច្នោះហើយ ទើបព្រះអង្គថ្នមឱបក្រសោប
អង្គនាងធីតា ថាម្នាលអនុជ អ្នកកុំភ័យខ្លាចថ្វីអាយក្ស កុំជាងងឹតមេឃ
ដីឡើយ ហើយបងក៏នឹងប្រហារដំវៃកំទេចក្ស័យប្រល័យជន្មហោង ៗ
ថាហើយព្រះអង្គទ្រង់ចាប់យកសរពាលចន្ទ ហើយក៏ក្រោកឈរឡើង
តម្កើងធ្នូជ័យព្រះអង្គ ដ៏ល្អហាក់ដូចនៃអង្គព្រះកោសីយ៍ ចក្រថ្លែងទៅ
ហោង ៗ វីស័ព្ទសន្ធឹកក៏លាន់ព្ទូគ្រឹកគឹកកងរំពងទាំងអាកាសពសុធា
ក៏ញាប់ញ័រខ្លាខ្វូរ វីទ្ធិអំណាចសរនោះ បណ្ដាលក្ដីស្មានដូចដួងអរុ-
ណោទ័យ ព្រះអង្គក្រឡេកមើលទៅវៃ ឃើញអសុរកាមសូរ ៗ

កាលនោះ វីកាមសូរនោះ លុះឃើញសិល្បមនុស្សថ្លែងមកដោយ
វិទ្ធិក្លាហានដូច្នោះ ក៏នឹកក្រោធក្រេវក្រៃ ក៏ស្រែកគម្រាម ទូវស័ព្ទ
សម្រេងដូចផ្គរលាន់ ហើយកុម្ភ័ណ្ឌក៏ចាប់យកសិល្បដ័យវៃថ្លែងទៅដោយ
ច្ឆូរាហោង ៗ វីស័ព្ទសន្ធឹកសរអសុរនោះ ក៏លាន់ព្ទួសន្ធឹក ស្មើរ
ទីងក្ដុកផ្ទាប់ក្រឡាប់មហាប្រថពី ក៏ក្រើករំពើកដល់ឋានតុសិតា វីសរ
សក្ដាអសុរនោះ ក៏ទៅប្រទក្សិណទានកជរថ មិនអាចនឹងចូលទៅជិតអង្គ
ព្រះបក្រាឡើយ ៗ កាលនោះ វីព្រះកមាធិបតី ឃើញកមសូរ
យក្សាថ្លែងសរមកតគាំងច្បាំងទីងព្រះអង្គដូច្នោះហើយ ទើបព្រះអង្គចាប់
យកព្រះវៃសេងសរអគ្គិសនីវាត ហើយសម្ដែងថ្លែងទៅបំផ្លាញសរអសុរ
ព្រះអង្គទ្រង់តម្រង់ថ្លែងទៅ ក៏ឮលាន់កក្រើកទាំងត្រៃលោកា ៗ វីសរថ្មី

នោះ ក៏ត្រឡប់កើតជាកង់ចក្រកែវក្លៃផ្ទុក ហើយក៏តម្រង់ត្រង់ទៅបំផ្លាញ សរយក្សាក៏ខ្ទេចខ្ទីដូចផង់ធូលីមួយរំពេច ដូចព្រិចភ្នែក ដោយតេជានុភាព ព្រះហត្ថា ៤ ។ កាលនោះ កុមសូរអសុរីក៏ក្រេវក្រោធជាខ្លាំងណាស់ ដូចភ្លើងប្រល័យកល្ប ហើយក៏ចាប់យកព្រួញថ្វាពេជ្រទិព្វក្លា ត្រៃវង់ពោល ទៅ លាន់ឮសូរខ្ទឹកខ្ទាប់លើវេហាស៍ ដូចភ្លៀងធំ ងងឹតអ័ព្ទអស់ ទាំងសែនអរុណោទ័យ រីព្រួញថ្វាពេជ្រនោះក៏ដេញសរព្រះចក្រ ។ កាល នោះ រីព្រះកុមាធិបតី ឃើញព្រួញថ្វាពេជ្រអសុរីមានឫទ្ធានុភាពមហិមា ទើបព្រះអង្គយកសរផ្កាផ្កាញរាក ដ៏មានរិទ្ធិអំណាចសក្តាក្រៃ ហើយក្លៃ-ទ័យក៏បំណាន់មើលមិនព្រិចនេត្រា ព្រះយ៉ាតហ្លាទកស័ខ្ទ ក៏ផ្ទុងទៅ ដោយរិទ្ធិយោង ។ លាន់ឮគគ្រឹកទាំងគិរីសុមេរុសត្តបរិភណ្ឌសីទន្ត រហូតទូទាំងពិភពសុធា ដល់ទៅព្រហ្មអកនិដ្ឋ ងងឹតអន្ធការអ័ព្ទអស់ ទាំងទសទិស រីសរផ្កាក៏ផ្ចាញព្រួញថ្វាពេជ្រអសុរា ។ កាលគ្រានោះ កុមសូរសេដ្ឋីសក្តិយក្ស ឃើញព្រួញថ្វាពេជ្រចាញ់រិទ្ធិសរព្រះកុមា ក៏សែន ក្រោធា នេត្រាទាំងពីរក្រឡេកក្រឡៅជាលក្រហមច្រាលដូចដួងអរុណោ ទ័យ គន្ធ្រឹមធាតារ ក៏ស្រែកសម្រែកសន្ធាប់ខ្លាំងក្រៃ អសុរីក៏សម្តែង អំណាចញាប់ញ័រទាំងផែនដី ស្ទុះវៃចូលទៅចាប់ចុងពន្លោលព្រះកជរថ របស់ព្រះកុមា ដោយហត្ថាទាំង ៤ ហោង ។

កាលនោះ ព្រះសុរិវង្សអង្គនាគយណ៍រិទ្ធី ត្រិះត្រត់សព្វសារដើយ

រស្មីភ្លឺដូចភ្លើងព្រានព្រាយ ហើយស្តេចក៏ក្រោកចុះពីរាជរថ ចូលក ដៃនឹងអសុរប្រចាប់ចំបាប់គ្នាវិលវល់ទៅវិញទៅមក ប៉ុនប៉ងបំណងក្នុងចិត្ត តាំងសង្ខារនឹងផ្តួលផ្តាច់ជីវិតល្បងរើគ្នាហោង ។ កាលនោះ កមសូរ អសុរិន្ទ្រាហាន ចូលរុករានមិនមានគិតជីវិតជីវាគ្នាសោះឡើយ ហើយ សុទ្ធសឹងតែក្លាពលខ្លាំង ចូលគក់តាំងច្បាំងគ្នា មួយកាប់មួយការពារ តាំងសង្ខារ ក្រឡាប់ក្រឡាសវិលវល់វិលវល់ទៅវិញទៅមក ។ គ្រានោះ ព្រះរាមាធិបតីចក្រីក៏ចាប់រឹងនឹងអសុរ ការមិនឱ្យត្រូវព្រះអង្គឡើយ ហើយ ព្រះអង្គក៏ចាប់ដៃអសុរបាន ព្រះអង្គក៏លើកជើងស្តាំជាន់លើដង្គង់ដើមទ្រូង របស់អសុរ ។ គ្រានោះ កមសូរយក្សាក្នុងចិត្តនោះប្រាថ្នានឹងផ្តាច់ ជីវិត ព្រះទ្រង់ទ្វីក៏ត្រីធ្នូជ័យ ពាយសំពងទៅត្រូវអង្គអសុរ ។ កម-សូរយក្សានោះ លុះត្រូវកាយក៏ឈឺស្បើរទឹងក្សយប្រល័យជន្មា ទឹង ទ្រាំពុំបាន ក៏យំស្រែកថា នុអង្គអញអើយ សែនស្តាយកម្លាំងរិទ្ធី ដោះតាំងទសទិសានុទិស ក៏អញធ្លាប់បង្ក្រាបប្រាប់បាន គួរឬមកតាញ់ ឫទ្ធិមនុស្សសាមាន្យប៉ុនសុចសត្វ អសុរក៏តូចចិត្តក្រៃ ទឹងល្បីកេរ្តិ៍ ឈ្មោះខ្ញុំទៅដល់កល្បកប្បគាប់សក្តិ ខាសអស់ទេព្រក្សត្រគ្រៃ តាំង ទេវសួគាល័យគ្រប់ស្ថានពស៊ី អសុរខ្ញញាល្បែបប់ក្លាង ក៏ក្រឡេកភ្នែក មើលទៅព្រះចក្រី អសុរក៏ឃើញដៃ ៤ កាន់ចក្រគទាពេជ្រពណ្ណរាយ អសុរក៏ដឹងថា ជាអង្គព្រះនារាយណ៍ទ្រង់រិទ្ធិប្រចេះហើយ ក៏ស្ទុះក្រោក

ចូលទៅក្រាបក្រោមព្រះបាទា វន្ទិយទូលអង្វរសុំទោសព្រះរូ
ទ្រង់ព្រះករុណាមេត្តាប្រោសលោះទោសទុកជីវិត ដ្បិតខ្ញុំព្រះ
នេះ ឃើញខុសពិតជីវិតគួរក្ស័យ ព្រោះមិនស្គាល់ព្រះអង្គឡើយ ហោ.
ហ៊ានទទឹងរឹងចង់ច្បាំងនឹងព្រះអង្គ សូមព្រះរាជទានជីវិតក្នុងជាន់គ្រានេះ
ម្តងឲ្យបានរស់នៅបម្រើបាទតទៅ ។

កាលនោះ ព្រះនារាយណ៍រាមា បានស្តាប់យុទ្ធមារអសុរ ទួញ
ពណ៌នាសូមជីវិតដូច្នោះហើយ ព្រះអង្គទ្រង់សើចធ្វើញឹម ៗ ទើប
មានព្រះរាជឱង្ការថា ម្នាលកមសូរអសុរ ខ្លួននេះ ដំទ្រង់សក្តារិទ្ធិ
ជាកន្ទោងលោកាធាត្រី អង្គអញអវតារចុះមកបង្ក្រាបយុគ ដើម្បីប្រាថ្នា
នឹងឲ្យលោកជាសុខក្សេមក្សាន្ត រំលត់ទុក្ខសោកឲ្យបានត្រជាក់តាំង
ផែនក្រោម ជាទីពំនាក់នៃត្រៃលោក ។ ឥឡូវនេះអ្នកដឹងខ្លួនធ្វើខុសមែន
ពិត ជីវិតនោះ ណ្ហើយចុះ អញលើកឲ្យតាំងតែពីថ្ងៃនេះតទៅ ចូរ
តាំងចិត្តប្រព្រឹត្តនៅក្នុងសត្យក្នុងធម៌ ។ កាលនោះ កមសូរអសុរ
បានស្តាប់ព្រះឱង្ការព្រះទ្រង់ត្រុះហើយ អសុរក៏ក្រាបក្រោមព្រះបាទា
វន្ទិយទូលតបទៅវិញថា ដែលព្រះអង្គទ្រង់ព្រះមេត្តាការុណ្យព្រះគុណ
នោះជាទីបំផុត ទូលព្រះបង្គំជាខ្ញុំគ្មានវត្ថុអ្វីនឹងតបស្នងធ្ងន់ព្រះបាទព្រះ
បារមី មានតែសេចក្តីមួយនេះ គឺអង្គព្រះសយម្ពូញាណ ព្រះរាជ
ទានអង្គត្រៃមេឃយក្ស ជំជាអធ្យាធិបតី ខ្ញុំព្រះករុណានេះ បាន

គដំណាពន្យមក សូមថ្វាយក្នុងធូលីព្រះបាទបរមលោកនាថ ទើបបាន បង្ក្រាបប្រាបពួកពាលពាលាបច្ចាមិត្រ ដើរចិត្តជាសត្រូវត្រូវតែក្នុងលោ-កាហោង ។

កាលនោះ ព្រះទ្រង់គពលុបលើសលោកា ទទួលយកសរពៃផ អសុរ ព្រះមេតបាក់សែតអោយមន្ទសប្រគ្រពេត ។ ឯកមសូរអសុរ លុះថ្វាយសរសិល្បហើយ ក៏ក្រាបថ្វាយបង្គំលាហោះទៅវិញហោង ។

កាលនោះ វិអគ្គិអគ្គការធិបតី បក្រក៏មានព្រះវាចាថា ម្នាលព្រះពិរុណ វិសសិល្បនេះ យើងសូមផ្ញើទុកនឹងអ្នកផង បើយើងធ្វើការទៅមុខនោះ ទញ់ទាល់តិទកកាលណា សឹមយើងមកយកពីអ្នកវិញហោង ។ ថាហើយព្រះអគ្គិក៏ហោះហោលទៅលើអាកាស ។ ហេតុនៃគេជាទុកាភអគ្គព្រះបក្រាក៏កកើតអំពីកតាំងទសទិស ។ វិអគ្គិ ព្រះពិរុណទេពក៏ទទួលទុកដោយសោមនស្សហោង ។

កាលគ្រានោះ វិអស់ហ្វូងទេពគ្រប់កសិណនោះ ក្រុះឃើញពួកអសូរ អសុរ ចាញ់ធ្វើបារមីព្រះពមសហើយ ទេវេសគ្រប់ស្ថានក៏អរសាទរ ទះដៃឲ្យពរ ទេពខ្លះក៏ថា ពួកអសុរមារ ក្នុងគ្រានេះ ទើងវិនាសល្អិតខ្ទេចខ្ទី ដោយបុណ្យព្រះបរមត្រៃផ ៤ , ទេពខ្លះ ក៏បាចសាចនូវមាលាផ្កាក្រមាស នូវផ្ទឹមន្ទាវិព្វកេស ហើយក៏ស្រែកនូវសព្ទសាធុប្រែកឲ្យជ័យសិរីសួស្តីជាច្រើន ១ ហោង ។

កាលនោះ ព្រះបាទវចរវដ្ឋធិបតី ទាំង ៣ សម្តេច
ខ្ញុំអស់ពលយោធាទាំងពួងនោះ ឃើញព្រះកុមារមានជ័យ ជំនះឈ្នះក៏
ទេវតាក៏បាចសាចបុប្ផាទិព្វដេរដាសព្រះធរណី រីឯមាណពទាំងនោះ ក្រអូប
អប់ក្រឡប់ពេញទាំងព្រៃព្រឹក្សា អ្នកខ្លះក៏ចាប់រើសយកមកថើប ហើយ
សៀតត្រចៀកដោយសោមនស្សរីកសរង់ ៗ រីឯព្រះបិតុរង្គ ទ្រង់ឲ្យ
គ្រវីទង់ជ័យ លើកយោធាដើរហោង ៗ លុះស្តេចយាងតាមផ្លូវព្រែក
ជ្រៅជ្រលងស្ទឹងបឹងបួរព្រៃកព្រៃហិមពាន្ត ក៏ឈប់ដាក់យោធា ដោយ
យេះដំណាក់រៀង ១ ក្នុងអញ្ញ លុះដល់អយុធ្យាធានីហើយ ទើប
ព្រះអង្គឲ្យបញ្ឈប់ហែពលសកលយោធា នៅនាក្បែរកំផែង ៗ ទាំង
៩ ក្បូរស្រុកវិថីពន្ធ្យា ក៏ស្តេចយាត្រាទៅកាន់ប្រាសាទកែវមរកតា ដល់
ហើយក៏ដាក់អង្គគង់លើបល្ល័ង្កអាសន៍ ព្រះអង្គល្អដូចទេវរាជកោសីយ នា
កណ្តាលទៅមុខសុរិន្ទ ឬមន្ត្រីសុណិសា ព្រះស្នំក្រមការកំណាន់ទាំង
ពួងដេរដាសពិតប្រកិតជំនិត ទើបព្រះអង្គទ្រង់ប្រទានទាំងទ្រព្យសម្បត្តិ
ដាក់ស្ពាន ឲ្យព្រះកជបុត្រា ទាំងស្រីស្រីស្នំរ ជាបរិវារ ទាំងសេនាអាមាត្យ
មុខមន្ត្រី សង្ឃការីតោវវិតម្រួតត្រួតត្រាមហាតលិតគ្រប់គ្រាន់ហើយ ទើប
ព្រះអង្គទ្រង់បង្គាប់ទៅនឹងព្រះពិរុទព្រះសុតទ្រុងថា ម្នាលកូនអ្នកដ៏មានបុណ្យ
អានុភាពក្រៃដូចក្មួងប្រល័យកល្ប ចូលអ្នកគ្រឡប់ទៅតបស្នងធ្ងន់ព្រះ
បាទសម្តេចព្រះអយ្យកាធិរាជដូចដើម នឹងបានបម្រុងរក្សាអាណាប្រជាជន
ឲ្យអ្នកបានសេចក្តីសុខសួស្តីសិរីសោភាហោង (នៅមានត)

# ឯកសារ សាស្ត្រាស្លឹករឹត និង ក្រាំង

*ដែលមាននៅវិជ្ជាស្ថាននៃពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

( ក )

ចំណងជើង " សាស្ត្រា ច្បាប់ក្បួនគម្ពីរ "

អ្នកនិពន្ធ រកពុំបានឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាព្យ : បទកាកគតិ ។

ប្រភពរឿង ច្បាប់អាពុកទូន្មានកូនឥទ្ធិពលពុទ្ធនិយមនិងភពនិយម ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៣ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្ត

កាយកើនឬកាយព្រំ កំពង់ឆ្នាំងដែរ ចុះលេខ ៦៤៤ ។

អត្ថបទផ្ដើម កូនអើយគម្ពីរ មានព្រះបាលី គាថាច្រះហោង លោក

ទុកជាច្បាប់ សម្រាប់អ្នកផង ឲ្យរៀនក្រងរងរបៀនសាស្ត្រា ។

បរមយោ ខសម្បន្នោ គុណវិជ្ជា វិសាលិកុ - លំសុភក់

ឥកំសា នសោកន្តិ ។ ខ្ញុំអ្នកណា . . . ។ល។

អត្ថបទបញ្ចប់ ព្រះរាជសក្ខ ខ្ញុំបាទបុត្រគេ ចរិបូណ៌ស្រេចហើយ

ផ្គត់ផ្គង់មហាក្សត្រ ប្រណិបតន៍ជាក្រោយ មិនឲ្យឃ្លាតឡើយ

នឹងច្បាប់ធម៌ថ្លៃ (១) ។

\+ + +

បំណាំងជើង " សាស្ត្រា ច្បាប់ស្ទះស្មែង "

អ្នកនិពន្ធ រកពុំបានឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធន៍ ពាក្យកាយបទភាគគតិ ។

ប្រភពរឿង ច្បាប់ខ្ញុំបាទសាមណេរនិងសិស្ស តាមប្រពៃណីខ្មែរ

ពីព្រេងនាយ ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែមាន ៤ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្ត

បទុមវតីនៈ ខេត្តកំពង់ចាម ចុះលេខឯកសារ ៦៤០ ។

---

១) តទៅទៀត មានវិបត្តិទាំងជើងពាក្យទាំងអត្ថន័យ ។ ប្រហែលអ្នកចារ ចារបន្ថែម ដោយខ្លួនឯងទេដឹង? ល្បះបន្តទៅទៀតដូច្នេះ ៖

ផតអ្នកកក់កាន់ កំណត់សព្វថ្ងៃ ទាំង ១១ គ្រាន់គ្រប់ប្រពៃ រក្សាសីលថ្ងៃ ត្រូវធំវិញណា ។ យើងឃ្មូរលង់លុះ មេ្ទងផន្ទា សឹងទៅកើតឋាន ពិមានសួគ៌ា បរិបូរប្រុះប្រា-កដ កបទៀងហោង ។

អត្ថបទផ្ដើម : ហៃអ្នកស្ទះស្រង់ លះតីតម្លៃង លែងល្អក់កុះករ សង្វាត

មកបួស ពុទ្ធអង្គបារ ប្រាជ្ញាកុះករ ដឹងធម៌ពីណា ៗ ហេតុ

បានពីគ្រូ ប្រដៅនៃថ្ងៃ ដោយទូរសត្យា កុំអាងអ្នកចេះ ចំណេះ

អាត្មា ផុលពីបិត្តា ឯងជាលើសគ្រៃ . . . ។ល។

អត្ថបទបញ្ចប់ : គួរតែលើក សព្វថ្ងៃញឹកៗ ជាប្រក្រតីហោង

ឲ្យខំសង្វាត ឧហាតស្រូវង ឲ្យចេះចាំចង តាមច្បាប់បុរាណ ៗ

ច្បាប់នេះឧត្តម ឲ្យកូនចៅខំ មើលហើយឲ្យចាំ (?) បណ្ដាំ

ពាក្យព្រេង ដឹងកោតក្រែងបាប ដកបទៅហោង (?)

បរិបូរហត្ថម៉ី (?) សូរចេចប់ហោង (១) ។

\+ + +

ចំណងជើង " សាស្ត្រា ល្បើការផុត "

អ្នកនិពន្ធ រកពុំបានឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ ក្នុងអត្ថបទ ។ ប្រហែលខាងចុង សតវត្សទី ១៩ ឬ ខាងដើមសតវត្សទី ២០ នេះឯង ។

---

១) – ពីល្បះខាងចុងនេះ វិបត្តិដោយដើងភាស តកចាប់ចុងថ្លៃនឹងឃ្លាខាងលើ ។

របៀបនិពន្ធ ពាក្យកាយ បទបន្ទោលកាក និង ព្រហ្មគីតិ ។

ប្រភពរឿង មនោគតិរបស់អ្នកនិពន្ធ អំពីដំណើរដុចនិងត្រី ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ផ្សែមាន ៩ សន្លឹកកន្ទុះ ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពី

វត្តបទុមរតនៈ ខេត្តកំពង់ចាម ចុះលេខ ៦៤០ ។

អត្ថបទផ្ដើមៈ នេះបទបន្ទោលកាក ។ ថ្លែងដោយចំនង ដំណើរត្រី

ផងយាត្រា តើបទឹងដុចណា ត្រីស្រែកថាហើយចៀសចេញ ។

ដុចថាអីអើ បងអ្នកនេះតើម្ដេចមិញ កំមកប្រើអញ ចៀស

ចេញឲ្យអ្នកជាល្បែង ។ . . . . . ។ល។ . . . .

អត្ថបទបញ្ចប់ៈ ប្ដូនឹងប្រពន្ធ រៀងក្ដៅលើសលន់ញ័រប្រាណ ក្ដៅរប់

ពុំបាន ដេកថ្ងូរទីទៃពលគ្នា ។ កាំបែកទាំងផ្ទាំង ហើយកាំ

ឈើទាំងសាត្វា អត់ទាំងអាហារ ពុំបានទីត្រីនោះសោះ ។ ដំណើរ

ដុចត្រី មិនមានអំពីព្រេងនោះ គ្រាន់គ្រប់តែម្ដោះ បរិបូណ៌

ស្មូរបេចហើយហោង ។

( នៅមានត )

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ញូ-កាន

ប្រែ-រៀបរៀង

(គ)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាសបើបានអាន
> នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ
>
> — យូរ—អ៊ុន —

បើកាលណាទាន់ទីន់សែនឲ្យយើងនោះ ត្រូវឲ្យមានភ្លេងមហោរីពិណពាទ្យឲ្យគ្រប់ទិវារាត្រី ហើយនាំគ្នាបញ្ចប់ភ្នាក់ងារមេការឲ្យកសាងទីបុាំង (គឺអនុស្សាវរីយ៍) បញ្ចុះសពយើងនៅទីព្រះលានក្រៅក្រុងឲ្យបាន ៧២ អនុទ្ទិសដូចៗ គ្នា ដើម្បីកុំឲ្យមនុស្សនានាចាំសំគាល់បានថាសពយើងនោះបញ្ចុះត្រង់ទីកន្លែងណា ពីព្រោះថាខ្លួនយើងនេះ មានមនុស្សស្អប់ច្រើនណាស់ ក្រែងគេលបលួចគាស់កាយយកសពនោះទៅចោលអសារឥតការ, ចូចូផ្តាំផ្ញើសព្វគ្រប់ហើយក៏ចេះតែដកដង្ហើមធំយំអណ្តើតអណ្តក ទឹកភ្នែកក៏ហូរមកជោគរសេមទាំងមុខមាត់ បាត់ស្មារតីដួលចុះ អស់ជីវិតសង្ខារ, កាលចូចូធ្វើកាលកិរិយានោះ ក្នុងខែមាឃ អាយុ ៦៦ ឆ្នាំ; ព្រះចៅហៀនតេ ចៅគង់នៅក្រុង ហ៊ូតោបាន ២៥ ឆ្នាំ ( ពុទ្ធសករាជ ៧៦៣ ) ។

អស់បណ្ដានាម៉ឺនសព្វមុខមន្ត្រីដ៏ធំថា ចូចូក្ស័យជីវិតហើយ ក៏នាំគ្នាថ្ងូញសោកាល័យ ហើយប្រើបម្រើឲ្យទៅតៀរប្រាប់កូនចូចូ ដែលទៅឈរខេត្តទាំង ៤ នាក់, ចូភីនៅខេត្តឆៀងគុន, ចូវៀងនៅខេត្តអៀងឡេង, ចូស៊ុតនៅខេត្តលិមឈី, ចូហ៊ឹមនៅខេត្តសៀវហួយ ឲ្យចូលមកឯស្រុកឡុកអៀង, នាម៉ឺនទាំងពួង ក៏នាំគ្នារៀបតែងការសពជាធំ ពទ្ទឹក តាមរបៀបព្រះមហាក្សត្រ ហើយឲ្យរៀបគ្រឿងហែ សែងអញ្ជើញសពទៅទាំងកណ្ដាលយប់កណ្ដាលថ្ងៃ តម្រង់ទៅស្រុកឆៀងគុន ។

ឯចូភីដឹងថា បិតាអនិច្ចកម្ម ក៏យំសោកបោកខ្លួនប្រាណ ហើយនាំអស់ភ្នាក់ងារទាំងប៉ុន្មាន ចេញពីខេត្តមកប្រហែល ១០០ សិន ( ៤ គី. ) ក៏ប្រទះនឹងក្បួនហែសពបិតា; ចូភីក៏អញ្ជើញសពត្រឡប់ហែចូលទៅក្នុងស្រុកឆៀងគុន ហើយឲ្យប៉ាវគង់ប្រាប់អស់នាម៉ឺនមុខមន្ត្រី និងបណ្ដាប្រជាក្នុងស្រុក ប្ដាណាខេត្តដែលទៀមទាំងប៉ុន្មាន ឲ្យស្លៀកពាក់ស ជួតក្បាលសំពត់ស តាមបែបម្ចាស់ផែនដីសុគត; ចូភីនិងបណ្ដានាម៉ឺនមុខមន្ត្រីទាំងពួង ក៏នាំគ្នាសោកយំជំនុំកូទាំងមីក្រង ។ ខណៈនោះ មានមនុស្សម្នាក់មកស្រែកឃាត់ថា ៖ យើងពាស់គ្នាកុំអាលយំសោកថ្វី, ឯសេចក្ដីស្លាប់នោះ មានគ្រប់រូបជាធម្មតា ត្រូវតែគិតការរៀបចំផែនដីសិន, ពួកទាំងនោះ ក្រឡេកទៅឃើញស៊ុម៉ាហ៊ូ ក៏ដណ្ដឹងសួរទៅវិញថា ហេតុអ្វីបានជាមកឃាត់ហាមដូច្នោះ ?

សុម៉ាហ៊ូ ឆ្លើយថា ស្រុកទេសរបស់យើង មិនមានម្ចាស់គ្រប់គ្រងរក្សា ត្រូវតែបារម្ភខ្លាចក្រែងមានសត្រូវមកប្រមាថបៀតបៀន, ហេតុនេះ គួរតែលើកបុគ្គលឡើងស្ដេចជាម្ចាស់ស្រុក ទើបបណ្ដារាស្ត្រទាំងពួង នឹងបានសង្ឃឹមទុកចិត្ត មិនគិតញញើតខ្លាចសឹកសត្រូវ ។ ក៏មិនអាចនឹងករម្រើកចិត្តគិតប្រទូសរ៉ាយបាន ។ នាម៉ឺនទាំងអស់ឆ្លើយថា គំនិតអ្នកគិតនោះ ត្រូវណាស់ហើយ តែថាវេលានេះ ព្រះនៅហៀនគេ នៅមិនទាន់មានព្រះតម្រាស់ត្រាស់ឲ្យតាំងដូច្នេះនៅឡើយ; យើងនឹងធ្វើតាមអំពើចិត្តនោះដូចពុំគួរទេ ។

គាន់កៀវឆ្លើយថា ចាំទៀមម្ចាស់ស្រុកវិវត្តផុតទៅ ត្រូវតែឲ្យបុត្រច្បងឡើងនិយាយការជំនួស, ថាហើយក៏ចាប់យកព្រះសែងដាវលើកឡើងកាន់ ហើយកាត់ដាយអាវផ្កាចបន្តិចទម្លាក់ទៅលើផែនដី ដើម្បីបង្ហាញឲ្យមន្ត្រីទាំងពួងមើល ហើយស្រែកថា យើងត្រូវលើកបុគ្គឲ្យឡើងជាម្ចាស់ក្នុងពេលនេះ បើនរណាតែងទទឹងនឹងកាត់ក្បាលអ្នកនោះឲ្យដាច់ចុះដូចជាកំណាត់អាវដែលកាត់នេះ ។ នាម៉ឺនទាំងអស់ឃើញដូច្នោះក៏ភ័យទាំងអស់គ្នា ក៏គ្មាននរណានឹងឆ្លើយតបថាអ្វី. ទទួលពេលនោះហ្វូហ៊ុមជានាម៉ឺនធំ ទើបមកពីក្រុងហ៊ូគោ ដើរចូលទៅក្នុងទីប្រជុំធំ, នាម៉ឺនទាំងពួងឃើញហើយ ក៏ឲ្យមានសេចក្ដីខ្លាចណាស់ ទើបនាំគ្នាសួរដណ្ដឹងថា លោកអញ្ជើញមកដោយកិច្ចការអ្វី ?

ហ្វីហ៊ុមឆ្លើយថា វេលានេះ អត់ពីព្រះចៅវ៉ុយអង់ទៅហើយ យើងបានឮក្រែងមានសត្រូវទឹងក់រម្រើក, ហេតុនេះ ទើបយើងមក ដើម្បីទីងជំនុំគ្នា អញ្ជើញចូក៏ឲ្យឡើងជាស្ដេចនិយាយកដការផែនដីជំនួសបិតា នាម៉ឺនទាំងពួងឆ្លើយឡើងថា ឥឡូវបានប្រឹក្សាគ្នាហើយថា ត្រូវលើកចូក៏ឡើងជាម្ចាស់ តែទៅយល់ថាស់ ព្រោះមិនទាន់ត្រាតាំងពីព្រះចៅហៀនតេកដទានមក ។ ហ្វីហ៊ុមឆ្លើយថា ខ្ញុំបានទូលសុំត្រាព្រះចៅហៀនតេ ហើយទ្រង់ព្រះកដទានមកនេះ តាំងអស់គ្នាពុជ្ឈនោះ ក៏មានអំណរណាស់ នាំគ្នាស្រែកហោកញ្ជៀវលោតកំព្រហើងអឹងកង ។ ហ្វីហ៊ុមក៏យកត្រាតាំងបង្ហាញឲ្យមើលកល់គ្នា, ឯហ្វីហ៊ុមនោះ នៅធ្វើកដការជាល់គងព្រះចៅហៀនតេ តែជាពួកម៉ាក់របស់ចូចូ ចាំស៊ើបការល្អអាក្រក់មកប្រាប់ចូចូ, លុះដឹងថាចូចូស្លាប់ហើយ ទឹងចង់ឲ្យលើកចូក៏ជាម្ចាស់ជំនួសឡើង បានជាសរសេរត្រាតាំងសុំឲ្យាយព្រះហស្ដកាន់នាំមក ។

ឯចូក៏ក៏ឲ្យប្រមូលនាម៉ឺនមុខមន្ត្រីចូលមកគាល់; មន្ត្រីតាំងពួង ក៏ក្រាបថ្វាយបង្គំ ហើយចូក៏ឲ្យរៀបតុលៀងអាហារដល់នាម៉ឺនមុខមន្ត្រីធំ-តូចតាំងពួង, មានចំរើសើបការចូលទៅចូក៏ថា ចូជៀងជាប្អូនទ្រង់ នៅស្រុកទៀងអាន់ លើកកងទ័ពធំ មានទាហានប្រហែល ១០ ម៉ឺន ។ ចូក៏ព្ឺដូចោះ ក៏ភ័យណាស់ ប្រឹក្សាទឹងនាម៉ឺនតាំងពួងថា អាទោរខូច

នេះ កាលដែលនៅជាមួយគ្នា ក៏ជាមនុស្សរឹងរូសមោហោខ្លាំង ហើយ ព្រហើនកោងកាច មិនខ្លាចក្នុងការចម្បាំងសោះ ដែលក៏លើកទ័ពមក គ្រានេះ គឺប្រាថ្នានឹងដណ្ដើមយករាជសម្បត្តិជាប្រាកដហើយ ។

គៀគុយទូលថា ទូលបង្គំនឹងសុំចេញទៅនិយាយសម្រួលនឹងចូ-ដៀងមើល ដើម្បីឲ្យដឹងថា មកនោះល្អអាក្រក់ប្រការម្ដេច ។ នាម៉ឺនទាំងពួងឆ្លើយព្រមគ្នាថា អ្នកនិយាយនោះត្រូវណាស់, ទោះបីជាគេមកដោយកាច ក៏អាចសម្រួលបានទៅជាល្អ ដោយនូវវោហាររបស់អ្នក ។ ចូគីឮដូច្នោះ ក៏មានអំណរណាស់ ទើបត្រាស់ប្រើគៀគុយឲ្យចេញទៅជួបនឹងចូដៀង ។

ចូដៀងក៏សួរថា បិតាយើងមរណភាពទៅហើយ; ព្រះចៅហៀន-តេ ទ្រង់តាំងអ្នកឯណានិយាយរកការជំនួសបិតានោះ ។ គៀគុយឆ្លើយថា ប្រពៃណីបុរាណ បើជាភ្នាក់ងារស្រុកទីមួយ ៗ បើអត់ពីអាពុកទៅ ត្រូវឲ្យកូនប្រុសច្បងដែលនៅក្នុងបន្ទុកនោះ ទទួលកាន់ការជាជំនួសអាពុក, បើជាស្ដេចផែនដីវិញ ក៏ត្រូវឲ្យព្រះរាជឱរសច្បងឡើងសោយរាជ្យជំនួសព្រះវររាជបិតាដូចគ្នា, ដូចជាខ្ញុំអ្នកនេះសោក គឺមិនមែនជាបុត្រច្បងទេ ឬជាមន្ត្រីធំក៏មិនមែនផង នឹងត្រូវការអ្វីក៏មកសួររឿងនេះមិនត្រូវការ ។

ចូដៀងបានឮដូច្នោះ ក៏គិតឃើញថា គៀគុយលើកយកទំលាប់

ទាំងទៀមមកនិយាយជាត្រឹមត្រូវប្រាកដ ក៏ទៅទៀម, ហើយនាំគៀគុយ ចូលទៅក្នុងស្រុក, លុះទៅដល់ជិតកំផែងហើយ គៀគុយក៏សួរថា អ្នកអញ្ជើញមកវេលានេះ នឹងដណ្ដើមយកកេរសម្បត្តិ ឬមករៀបចំសពបិតា ? ចូជៀងថា ខ្ញុំមកនេះ នឹងបានតាំងចិត្តគិតដណ្ដើមយកបុណ្យស័ក្តិអ្វីក៏ឥតអត្ថិមាន មកនេះប្រាថ្នានឹងធ្វើការសែនសពបិតាជាទតបគុណទេ ។ គៀគុយថា បើពិតដូច្នោះ ហេតុម្ដេចបានជាអ្នកនាំទាហានមកច្រើនម៉្លេះ ? ចូជៀងឮដូច្នោះ ក៏យល់ឃើញថាជាខ្លួនធ្វើខុសមែន ទើបបណ្ដេញទាហានទាំងពួងឲ្យវិលត្រឡប់ទៅវិញ នៅតែខ្លួនមួយទៅជាមួយនឹងគៀគុយ ចូលទៅគាល់បង ។ ក៏ចេញមកទទួល ឃើញមុខគ្នាហើយ ក៏គៀកគ្នាយំសោកទាំង ២ នាក់, លុះអស់សំណោកហើយ ចូជៀងក៏គិតថា ក្រែងបងសង្ស័យក៏និយាយថា ទាហានខ្ញុំបានដែលមកវេលានេះ ខ្ញុំបានសូមប្រគល់ជូនបងទាំងអស់ ហើយចូជៀងក៏ចូលទៅគំនាប់សពបិតា ។ ទើបចូភីប្រើចូជៀងឲ្យទៅឈររក្សាស្រុកអៀនឡេង; ចូជៀងក៏ធ្វើការគំនាប់សពបិតា ហើយក៏លាបងលើកទាហានទៅរក្សាស្រុកអៀនឡេង ។ ចូភីឲ្យតាក់តែងគ្រឿងឧបភោគបរិភោគឲ្យដូចគ្រឿងកងបរិភោគព្រះចៅហៀនតេគ្រប់ប្រការ ។ កាលចូភីបានឡើងជាស្ដេចនោះ ព្រះចៅហៀនតេទៅគង់នៅក្រុងហ៊ូតោ បាន ២៦ ឆ្នាំ (ពុទ្ធសករាជ ៧៦៤) ។

ចូភី គឺគាំងហ៊ូហ៊ុមជាសេនាបតីស្ដាំ. គាំងកាសៀង ជាសេនាបតីឆ្វេង, គាំងអេងឡូង ជាទីប្រឹក្សាធំ, បណ្ដាខាម៉ុនទាំងពួង គឺឲ្យលឿនទីតាមគុណានុរូប ហើយឲ្យតែងទីបញ្ចុះសពបិតា ៧២ អង្គ តាមពាក្យបណ្ដាំបិតា ហើយឲ្យចារឹកអក្សរពីមុខអនុស្សាវរីយថា ទីនេះជាកន្លែងបញ្ចុះសពព្រះចៅវ៉ុយអង តាមក្បែរផ្ទាំងនោះ ពីខាងក្រៅឡើងគូរជារឿងអ៊ុគិមទៅច្បាំងនឹងគួនអ៊ូ នៅតំបន់ស្រុកអ៊ុនសៀ, គួនអ៊ូធ្វើកលឧបាយឲ្យនាំទាហានទៅទប់ទឹកឲ្យលិចកងទ័ពអ៊ុគិម ១ បាក់ទ័ព, គួនអ៊ូវាយអ៊ុគិមនិងបាំងតេកបាន, គួនអ៊ូអង្គុយលើទីខ្ពស់ ឲ្យអ៊ុគិមនិងបាំងតេកអង្គុយទីទាប, បាំងតេកជាជាតិទាហានមិនខ្លាចសេចក្ដីស្លាប់, គួនអ៊ូឲ្យនាំទៅប្រហារជីវិត, អ៊ុគិមខ្លាចស្លាប់ ក៏ក្រាបសំពះគួនអ៊ូលន់តួទោសសុំអាយុជីវិត, ចូភីឲ្យធ្វើរឿងដូច្នេះ ប្រាថ្នានឹងផ្ចាញ់ផ្ចាលអ៊ុគិមឲ្យឃើញថា អ៊ុគិមខ្លាចស្លាប់ មិនមែនជាជាតិទាហាន មិនមានសេចក្ដីអៀនខ្មាស បានជាអង្វរគេសុំអាយុជីវិត ក្រោយនោះក៏រស់រួចខ្លួនមកវិញ, ដើម្បីមិនឲ្យទាហានទាំងពួងយករឿងយ៉ាងតាមតទៅ ទើបប្រើឲ្យអ៊ុគិមទៅឈររក្សាទីប៉ាធ (អនុស្សាវរីយ) ដែលបញ្ចុះសពចូចូនោះ, ឯអ៊ុគិមកាលទៅនៅរក្សាសពចូចូ ក៏បានឃើញគំនូររឿងដែលខ្លួនទៅធ្វើចម្បាំង ក៏ថា ចូភីឲ្យធ្វើផ្ចាញ់ផ្ចាលខ្លួន ក៏មានសេចក្ដីអៀនខ្មាសណាស់, អំណើះតមក ក៏ផ្តួលចិត្តទៅជាឈឺស្គមក្រំក្រៀមស្លាប់ ។

ហ៊ូហ៊ឹម ក៏ទូលទូកថា ចូរដៀងថាប្អូនទ្រង់នោះ បានមកគំនាប់សពបិតា ហើយលើកយកពលទាហានថ្វាយប្រគល់អស់ តែចូស៊ុតនៅស្រុកលិមឈើ ចូហ៊ុមនៅស្រុកសៀវហ្ស៊ួយ ប្អូនទ្រង់ទាំងពីរនាក់នេះ មិនបានមកជួយរៀបចំសពបិតានោះ ត្រូវឲ្យទ្រង់បង្គាប់ទៅឲ្យចុះអាជ្ញា តាមទោសានុទោសទើបគួរ ។ ចូភីយល់ឃើញត្រូវ ទើបចាត់ប្រើនាយទាហានធំឲ្យនាំកងទ័ពទៅចុះអាជ្ញាប្អូនទាំងពីរនាក់ ។ នាយទាហានធំ ២ នាក់ក៏លើកពលចេញទៅតាមបង្គាប់ចូភី ។ ពួកល្បាតចូហ៊ុម ក៏នាំពត៌មានទៅប្រាប់ចូហ៊ឹមថា បងលោកខឹងនឹងលោក ពីព្រោះមិនទៅគំនាប់សពបិតា, ឥឡូវប្រើទាហានឲ្យមកចុះអាជ្ញាធ្វើទោសលោកហើយ ។

ចូហ៊ឹម បានឮដូច្នោះ ក៏មានសេចក្ដីភ័យខ្លាំងណាស់ ព្រោះខ្លាចអាជ្ញា ក៏ចងកស្លាប់ទៅ ។ នាយទាហានដែលទៅចុះអាជ្ញានោះដឹងថា ចូហ៊ឹមចងកស្លាប់ហើយ ក៏លើកទ័ពត្រឡប់ទៅទូលចូភី ។ ក៏បង្គាប់ឲ្យភ្នាក់ងារទៅរៀបចំសពចូហ៊ុមបញ្ចុះតាមប្រពៃណី ហើយឲ្យចារឹកអក្សរទុកទៅមុខអនុស្សាវរីយ៍ថា ទីបញ្ចុះសពចៅហ្វាយស្រុកសៀវហ្ស៊ួយ ។

ឯពួកល្បាតស្រុកលិមឈើដឹងថា មានបំរើចូភីទៅធ្វើទោសចូស៊ុតដូច្នោះ ក៏នាំពត៌មាននោះទៅប្រាប់ចូស៊ុត វេលានោះ ចូស៊ុតកំពុងអង្គុយផឹកស្រាជាមួយនឹងគេងស៊ុ, គេងអ៊ុ, ចូសិត ដឹងសេចក្ដីហើយ ក៏មិនមានតក់ស្លុតកោតញញើតសោះ ។ (នៅមានត)

# ឯកសារ កម្ពុជសុរិយា

(ស)

លោក ទឹក-គាម ប្រមូលរៀបរៀង

សត្វាធេវមនុស្សធំ : ព្រះឧបាលិវង្ស មឹង-សេស ទ.ក. ១២, ទំព័រ ៨៨៣, ឆ្នាំ ១៩៥៤, (ម.៥២/២៥) ។

សត្វខ្លា (រឿង) : ទ.ក. ១, ទំព័រ ៣៩, ឆ្នាំ ១៩៣១ (ម.៥២/៤) ។

សត្វចាបនិងដំរីស្គ : លោក ប៊ូ ប៉ូ ទ.ក. ៤, ទំព័រ ៣៦៨, ឆ្នាំ ១៩៥៩, (ម ៥២/៣១) ។

សត្វលោកនិងកាមគុណ : លោក មាស-យុគ្គ ទ.ក. ៧, ទំព័រ ៦៩៧, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

សត្រូវរបស់ខ្ញុំ : លោក ប៊ូ-ប៉ូ ទ.ក. ២, ទំព័រ ១៨២ ឆ្នាំ ១៩៦០ (ម.៥២/៣២) ។

សទ្ធម្មគាថា : ព្រះញាណារិយ ក៊ិន-សាខុំ ទ.ក. ៥, ទំព័រ ៣៩៩, ឆ្នាំ ១៩៥៨, (ម ៥២/៣០) ។ ទ.ក. ៥, ទំព័រ ៤៥៣, ឆ្នាំ ១៩៦២, (ម.៥២/៣៤) ។

សទ្ធម្មប្បជោត : ព្រះមហា អ៊ុក-អ៊ិន ទ ក ៧, ទំព័រ ៦០១, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។

សន្តិភាពតាមគតិពុទ្ធសាសនា : ព្រះភិក្ខុ ខៀវ-ជុំ ខ.ក. ៧, ទំព័រ ៦០៣, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

សរភ្ជាសរគាថា : ឃុនបណ្ឌិតក្សេ ប៊ូ-ប៊ូ ខ.ក. ៨ ទំព័រ ៧០៣ ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

សន្និបាតប្រគល់មុខការ ព្រះសង្ឃជាយកាវត្តឧណ្ណាលោម : សមុហាពោធិញ្ញាណ ជួន-ណៀត ខ.ក. ៣, ទំព័រ ២២៥, ឆ្នាំ ១៩៤៨ (ម.៥២/៣០) ។

សន្និបាតនៃបណ្ឌិតវិស្សាន៍អេក្សាត : លោក ក៏យ-ប៊ុក ខ.ក. ៩, ទំព័រ ៨៦៣, ឆ្នាំ ១៩៤៧ (ម.៥២/២៩) ។

សន្និសីទនៃលោកម៉ាក្វិសគាក់ : ក៏ះប-ប៊ុក ខ.ក. ៤, ទំព័រ ២២៩, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

សន្និសីទព្រះពោធិវង្សហួត-តាត អំពីសមាជសកលលើកទី ៦ នៃពុទ្ធសាសនា : ព.ប. ខ.ក. ១, ទំព័រ ៦៤, ឆ្នាំ ១៩៥៣ (ម.៥២/២៥) ។

សន្និសីទ អំពីពុទ្ធសាសនានៃលោកបណ្ឌិតជាត់ជាតិ ន.ណ្ហា : ខ.ក. ៩, ទំព័រ ១០៦៦, ឆ្នាំ ១៩៦៤ (ម.៥២/៣៤) ។

សប្បុរិសកថា : ព្រះបាឡាត់ពោធិកម យូរ-ប៉ុណ្ណ ខ.ក. ៤, ទំព័រ ២១៥, ឆ្នាំ ១៩៤៧ (ម.៥២/១៩) ។ ភិក្ខុ អ៊ុំ-សុខ

ទ.ក. ៣, ទំព័រ ៤៤៩, ឆ្នាំ ១៩៦៤ (ម.៥៤/៣៦) ។

សប្បុរិសធម៌ (កាព្យ) : លោក បាន . គេង ទ.ក. ១០-
១១ - ១២ ទំព័រ ១៣៧, ឆ្នាំ ១៩៣៦ (ម.៥៤/៨) ។

សប្បុរិសធម្មកថា : ព្រះទេពសត្ថា សូរ-ហាយ ទ.ក. ៥
ទំព័រ ៣៧៤, ឆ្នាំ ១៩៥០ (ម.៥៤/៤៤) ។

សប្បុរិសកប្បុរិសកថា : ភិក្ខុ ពេជ្រ - តុម្ព ទ.ក. ៧, ទំព័រ
៦៩៣, ឆ្នាំ ១៩៦៤ (ម.៥៤/៣៦) ។

ស័ព្ទបារាំងប្រែជាខ្មែរ : ហួនទិពន្ធមន្ត្រី ញ៉ុក-ថែម ទ.ក.
៥, ទំព័រ ៣៤១; ឆ្នាំ ១៩៤៩ (ម.៥៤/២១) ។

សព្វសិទ្ធិ : ទ.ក. ១, ទំព័រ ៥៣, ឆ្នាំ ១៩៥៩ (ម.៥៤/៣១) ។

សត្តិសមាសកថា : ព្រះធម្មបាលវង្ស សូរ-ហាយ ទ.ក. ១,
ទំព័រ ១; ឆ្នាំ ១៩៥៨ (ម.៥៤/៣០) ។

សមណសញ្ញានៃព្រះសង្ឃ ១០ រូប : ពុ.ប ទ.ក. ៤, ទំព័រ
៣១៩, ឆ្នាំ ១៩៤៤ (ម.៥៤/២៥) ។

សមត្ថភាពគីមី : ព្រះមុនីកោសល សូរ-ហាយ ទ.ក. ៦, ទំព័រ
៦២១; ឆ្នាំ ១៩៦៤ (ម.៥៤/៣៦) ។

សមភាពក្នុងព្រះពុទ្ធសាសនា : យុទ្ធបណ្ឌិតរក្ស ប៊ូ-ប៉ូ
ទ.ក. ៨, ទំព័រ ៥៦៣ ឆ្នាំ ១៩៥៤ (ម.៥៤/២៥) ។

សម័យចំរើនរបស់ក្បាច់រចនាខ្មែរ : លោក ហ.មារ្សែល
ទ.ក. ៧-៨-៩ ទំព័រ ១៦៩, ឆ្នាំ ១៩៣៦,
(ម.៥២/៨) ។

សមាជសភាគណៈលើកទី ៦ នៃពុទ្ធសាសនា សុន្ទរកថាសម្តេចព្រះសង្ឃនាយក នៅប្រទេសសីឡង់ :
ទ.ក. ១, ទំព័រ ៦៩, ឆ្នាំ ១៩៥៣, សុន្ទរកថាបណ្ឌិត
ម៉ាឡាល៉ាសេកេរ: ទ.ក. ២, ទំព័រ ១៥៣, ឆ្នាំ ១៩៥៣,
(ម.៥២/២៥) ។

សម្តេចព្រះមហាសមណ: : ភិក្ខុ ឈឹម-ស៊ុម ប្រែ ទ.ក ៤-
៥-៦ ទំព័រ ៧៥, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

សម្ពុលាជាតក : ព្រះបាឡាត់ពោធិកម យូរ-ប៉ុណ្ណ ទ.ក. ៦,
ទំព័រ ៣២១, ឆ្នាំ ១៩៤៥, (ម.៥២/១៧) ។

សម្ពោធពុទ្ធសាលាបាលីរង់នៅឃុំគគីរធំ ស្រុកកៀនស្វាយ : ទ.ក. ១០-១១-១២ ទំព័រ ៩៩ ឆ្នាំ ១៩៣៥
(ម.៥២/៧) ។

សម្មាទិដ្ឋិកថា : ព្រះអាចារ្យ អាំ-សាមុល ទ.ក. ១០, ទំព័រ
៧៣១, ឆ្នាំ ១៩៥១, (ម ៥២/២៣) ។

សម្មោទមានជាតក : ព្រះញាណកោសល ញាណ-ឈឺន
ទ.ក. ៣, ទំព័រ ៣២០, ឆ្នាំ ១៩៦២, (ម.៥២/៣៤) ។

សម្លាញ់ពីរនាក់ : ទ.ក. ១-២-៣, ឆ្នាំ ១៩៣៣ (ម.៥២/៦) ។

សម្លាញ់ពីរនាក់ចង់ពង្រីកពីកសមុទ្រ : លោកទៀន-
តៃឈុន ទ.ក. ៦, ទំព័រ ៥៤១, ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

សម្លាញ់ពីរនាក់នៅក្រុងជាមួយគ្នា : ទ.ក. ៧-៨-៩, ទំព័រ
១៦៤, ឆ្នាំ ១៩៣៣, (ម.៥២/៦) ។

សរណាគាថា : លោកអាចារ្យ ឧង-សាមិទ្ធ ទ.ក. ៦, ទំព័រ ៤២៤,
ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

សរណាគមន៍ : ព្រះមហាកជធម្ម ឌិត កជាគណៈ ទ.ក. ៣, ទំព័រ
២១, ឆ្នាំ ១៩២៧ (ម.៥២/២ ។

សរសើរព្រះរស្មី : លោកគ្រូសីលសំវរ អ៊ុត ហាក់ ទ.ក. ៧ ទំព័រ
៣៦៩ ឆ្នាំ ១៩៤៣ (ម.៥២/,៥) ។

សរសបណ្ឌិតជាគត : ព្រះគ្រូសាសនវង្ស គុយ សូត្រ ទ.ក. ១១
ទំព័រ ៨៦៣ ឆ្នាំ ១៩៥០ (ម.៥២/១៥) ។

សាធុរក្ខាណាគាថា : ព្រះគ្រូសិរីសោភណ កឹម-គូរ ទ.ក. ១២,
ទំព័រ ៨៨៦ ឆ្នាំ ១៩៥៣ (ម.៥២/២៥) ។

សភាៈក្កុតា : អ្នកទុកញ្ញាវិបុលពជសេនា នូ កន ទ.ក. ២ ទំព័រ ៩០,
ឆ្នាំ ១៩៤៥ (ម.៥២/២០) ។ ពាក្យបរិយាយដើមនៃរឿង
សាមកុក: ហួងទិតឧមន្ត្រី ញ៉ុក-ថែម ទ.ក. ៤, ទំព័រ ៨១,
ឆ្នាំ ១៩៤៨ (ម.៥២/២០) ។

សាមគ្គីកថា : មហា សេ-កោ ទ.ក. ៤, ទំព័រ ២៩៣, ឆ្នាំ ១៩៤៩ (ម.៥២/២១) ។ ព្រះឃុាឡាក់ តាន់-លី ទ.ក. ៦, ទំព័រ ៤០៩, ឆ្នាំ ១៩៥២ (ម.៥២/២៤) ។ ព្រះគ្រូវិសុទ្ធិញាណ សួរ-ហាយ ទ.ក.៦, ទំព័រ ៣១៧, ឆ្នាំ ១៩៤៧ (ម.៥២/១៩)។ ព្រះមហា ឈឹម-ម៉ី ទ.ក. ១១, ទំព័រ ៨០៣; ឆ្នាំ ១៩៥៤, (ម.៥២/២៥) ។

សាមគ្គីធម៌ : សម្តេចព្រះពោធិវង្ស ហួត-តាត ទ.ក. ៣, ទំព័រ ២២៦, ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

សាជឿ : បុណ្យស្រង់ព្រះពុទ្ធរូប ទ.ក. ៦, កូមិបាថខគ្រួសារ ត្រកូលក្បា៉ ទ.ក. ៩, ទំព័រ ១, ធាតុចេតិយលាវនៅមឿង ទ.ក. ១០, ទំព័រ ១, ឆ្នាំ ១៩៥១ (ម.៥២/១៣) ។

សារលិខិតនៃលោកស្វាមីវិវេកានន្ទ : លោក ក៉យ-ប៊ុក ទ.ក. ៤, ទំព័រ ២៦៦, ឆ្នាំ ១៩៥១ (ម.៥២/២៣) ។

សារទេសនា : ព្រះវិសុទ្ធិវង្ស ហ.តាត ទ.ក. ១០-១១-១២, ទំព័រ ៣, ឆ្នាំ ១៩៣៧ (ម ៥២/៩) ។

សាវតារវត្តចាយន : មេឃុំ ឌួង-អ៊ុប ទ.ក. ៧, ទំព័រ ៥១៩, ឆ្នាំ ១៩៥០ (ម.៥២/ ២) ។

សាវតារវត្តវិហារឧណ្ណឹម : អ្នកឧកញ៉ា កែវ ហង្ស ទ.ក. ៥, ទំព័រ ៣៥៣, ឆ្នាំ ១៩៥០ (ម.៥២/២២) ។

សារាណីយធម្មកថា : ព្រះមហា កែ អឿន ទ.ក. ១, ទំព័រ ៣,
ឆ្នាំ ១៩៥២ (ម.៥២/២៤) ។

សារាណីយធម៌ : ព្រះមហា ជាច់.សឿន ទ.ក. ៩, ទំព័រ ៦៤៣,
ឆ្នាំ ១៩៥៣ (ម.៥២/២៥) ។

សាវតារជាងហង្សជាតក : លោក អុំ-ហ៊ុ ទ.ក. ១, ទំព័រ ៣២,
ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

សាវតារវត្តកោកណ្ដាល : លោក ឌ.តាម ទ.ក. ១, ទំព័រ ៧៥,
ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

សាវតារវត្តអដ្ឋរស : អ្នកអង្គម្ចាស់ក្សត្រី ន.សុខានារី ទ.ក. ៩,
ទំព័រ ៦៨៤, ឆ្នាំ ១៩៥០ (ម.៥២/២២) ។

សាវតារវត្តកែវឧត្តរង្សី : ព្រះមហា គុយ ហួត ទ.ក. ៤, ទំព័រ
៤៨០, ឆ្នាំ ១៩៥១ (ម.៥២/២៣) ។

សាលាអាកិវសេសនៅចុងបូព៌ាប្រទេស : ក្រមការ ជុំ-មៅ
ទ.ក. ៤, ទំព័រ ៥១, ឆ្នាំ ១៩២៧ (ម.៥២/២) ។

សាលាបង្រៀនមនុស្សខ្វាក់ នៅប្រទេសសៀម និង
ទ្វីបអឺរុប : ខេមរង្សី ទ.ក. ៣, ទំព័រ ៩, ឆ្នាំ ១៩៤០ (ម.៥២/១៦) ។

សាលារៀននៅប្រទេសជប៉ុន : អ្នកស្រីសារិះយ៉ាន ទ.ក. ១២,
ទំព័រ ៩២០, ឆ្នាំ ១៩៥៥ (ម.៥២/២២) ។

សាសនបវត្តិបរិច្ឆេទ ទី ១-២ : ព្រះមហាពិទូរក្រសេម ទ.ក. ១-៦, ទំព័រ ១៦២, ឆ្នាំ ១៩៣៣ (ម.៥៤/៥) ។ ទី ៨ ទ.ក. ៤ ៥-៦ ទំព័រ ៤១, ឆ្នាំ ១៩២៥ (ម.៥៤/៧) ។

សាសនាវតារសង្ខេប : លោកអាចារ្យ មៀវ-នន្ទ ទ.ក. ៥, ទំព័រ ៤៦៥, ឆ្នាំ ១៩៤៥ (ម.៥៤/១៧) ។

សាសនភក្តី (កោតព្យ) : យុនស្នេហា ហ៊ឹម ទ.ក. ៧-៨ ៩, ទំព័រ ១៣១, ឆ្នាំ ១៩៣៦ (ម.៥២/៨) ។

សាសនាមានប្រយោជន៍យ៉ាងណា : ព្រះឧបាលិវង្ស សូរ-ហាយ ទ.ក. ១០, ទំព័រ ៤៤៣, ឆ្នាំ ១៩៥៥ (ម.៥២/២២) ។

សាសនាឥស្លាម និង សាសនាកាតូលិក : លោក ទៀង-តៃឈុន ទ.ក. ១, ទំព័រ ៦៤, ឆ្នាំ ១៩៥៧, (ម.៥៤/៦៩) ។

សាសនបវត្តិ : ព្រះមហាពិទូរក្រសេម ទ.ក. ១-២-៣, ទំព័រ ៦៧, ឆ្នាំ ១៩៣៦ (ម.៥៤/៨) ។

(នៅមានត)

# ជីវប្រវត្តិរបស់ខ្ញុំ

## ឈ្មោះ អៀង-សាយ

(គ)

មិនមែនតែម្តង ពីរដងនេះទេ មានម្តងក្រោយឆ្ងាយមកទៀត រាជការបានចែករថយន្តធុនធំ ១ ឲ្យមួយ ១ គ្រប់ក្រសួង ឲ្យគូបតែងលំអរ តាមចេះគិត ចេះធ្វើយ៉ាងណាឲ្យបានល្អមើល ក្នុងឱកាសបុណ្យហែក្បួនយ៉ាងធំ ក្នុងយប់មួយនោះ គេឲ្យលេខឲ្យរង្វាន់ ៗ កាលនោះរថយន្តដែលខ្ញុំគូបតែងលំអរ ដោយគោមក្រដាស ដាក់ភ្លើងខាងក្នុង និងលំអដោយសម្លៀកបំពាក់សិស្សប្រុស - ស្រី ប្អូន - ប្រាំនាក់ ឈរមានរបៀបនៅលើរថយន្តបានទទួលរង្វាន់លេខ ១ ។

សូមបញ្ជាក់បញ្ចប់ ១ ភាគខាងវិចិត្រសិល្បៈថា សញ្ញាបត្រពុទ្ធិកសមាគមកម្ពុជរដ្ឋ ដែលព្រះតេជព្រះគុណ, ព្រះករុណា និង លោកអ្នកជាសមាជិកមាន ១ សន្លឹក ដាក់ក្នុងក្របកញ្ចប់នោះ គឺជាសំណាដៃរបស់ខ្ញុំព្រះករុណា ខ្ញុំបាទបានគិតគូរ គម្រូរឲ្យគេតាមគោលអត្ថការនេះ ឲ្យគេធ្វើពុម្ពតាមគំរូនោះ ។

មួយទៀត គ្រាន់តែអក្សរ ក ខ គ ឃ ង ដែលគេចេះសរសេរគ្រប់គ្នា ក៏គេពឹងពាក់ខ្ញុំ ឲ្យសរសេរយកមកធ្វើពុម្ព ដាក់នៅដើមពាក្យតាមលំដាប់អក្សរ ក្នុងវចនានុក្រមខ្មែរទាំងពីរក្បាល ដែលមាននៅ

គ្រប់ទីកន្លែងទាំងអស់ សព្វថ្ងៃនេះ គឺអក្សរ ក ខ គ ឃ ង ធុនធំ ដែលមានស្រមោលខ្មៅនៅទំព័រដើមពាក្យ តាមលំដាប់អក្សរនោះ ៗ

កូនប្រវត្តិខ្ញុំ មានរឿងមួយ ដែលខ្ញុំទុកដូចជាខ្យល់ព្យុះបោកបក់មកលើទូក ដែលខ្ញុំនៅកណ្ដាលសមុទ្រ គឺកាលគ្រាដែលហោចហៅកូនសាកល ( គ្រឹះម៉ុងឌីយ៉ាល់ ) រដ្ឋការអាណាព្យាបាលនៅឥណ្ឌូចិន សម្រេចថា ត្រូវបន្ថយចំនួនអ្នករាជការ ដើម្បីសំចៃប្រាក់ទុកទប់ទល់ នឹងការហោចហៅរកប្រាក់មិនបាន គេបាត់អាំងស្បិកទ័រ ឲ្យមកគិតបន្ថយចំនួនអ្នករាជការ អ្នកណាមិនសូវចេះ ឬ ចេះដែរ តែធ្វើការមិនសូវមានប្រយោជន៍ គេបណ្ដេញលុបឈ្មោះចោល ៗ គេសើរើមើលពិនិត្យគ្រប់ក្រសួង មកដល់សាលាឧស្សាហកម្ម គេពិនិត្យសើរើមើលសញ្ញាប័ត្រគ្រូ ៗ មើលកិច្ចការដែលបានធ្វើ ឬ បានបង្រៀន មើលការសិស្សរបស់គ្រូម្នាក់ ១ ៗ មកដល់ឈ្មោះខ្ញុំ គេឃើញខ្ញុំថា ខ្ញុំគ្មានសញ្ញាប័ត្រខាងគំនូរសិប្បិយការ មានតែសញ្ញាប័ត្រខាងគំនូររចនា តែចៅហ្វាយនាយខ្ញុំ បង្ហាញការដែលខ្ញុំគូរ,ប៉ុឡង ហើយបង្ហាញការ ដែលខ្ញុំបានគូរនិងបង្រៀនគំនូរសិប្បិយការជាច្រើនឲ្យគេមើល គេឆ្ងល់គេសួរខ្ញុំថា : អ្នកឯងចេះដេស្សាំងអាំងឌុស្ទ្រីយែលពីណាមក? ខ្ញុំឆ្លើយថា : ខ្ញុំរៀនតាមសៀវភៅច្បាប់ក្បួនគំនូរ ៗ គេចាររកសៀវភៅនោះ ខ្ញុំយកមកឲ្យគេមើល ៗ គេមើលរួច គេនិយាយ

នឹងទៅហ្វាយខ្ញុំថា : វាចេះតូកែធ្វើការបានល្អហើយ តែកុំឲ្យបង្រៀន ធ្វើការតាមសៀវភៅច្បាប់ក្បួនជាន់ចាស់ ដែលវារៀននោះ ត្រូវឲ្យវា ទៅមើលគេបង្រៀនធ្វើការតាមសៀវភៅច្បាប់ក្បួនថ្មី ឯអេកូលប្រាទិច-ដាំងឌុសទ្រីយ៉េល ឯព្រៃនគរវិញ ។

ក្នុងគ្រានោះ នៅស្រុកយួន ស្រុកលាវ និងស្រុកខ្មែរ ប្រហែលជាគេបណ្ដេញលុបឈ្មោះអស់ច្រើន ដ្បិតគ្រាន់តែសាលាឧស្សាហកម្ម មានគ្រូខ្មែរតែនាក់ និងគ្រូយួនម្នាក់ ត្រូវគេបណ្ដេញលុបឈ្មោះចោល ។

ឯខ្លួនខ្ញុំ ត្រូវគេបញ្ជូនឲ្យទៅមើល ទៅហាត់ធ្វើការ តាមច្បាប់ក្បួនថ្មីនៅសាលាឧស្សាហកម្មឯព្រៃនគរ ខ្ញុំចម្លងច្បាប់ក្បួនគំនូរដែលគេបន្ថយការឲ្យងាយធ្វើបានឆាប់ ឲ្យងាយយល់ឃើញត្រង់ណាប្លែកពីសៀវភៅចាស់ ខ្ញុំចម្លងដោយសរសេរផង គូរផង បានមួយសៀវភៅ ។ ចាងហ្វាងសាលា ជាតិបារាំងឃើញថា ខ្ញុំចេះដឹងសព្វគ្រប់ហើយ ឲ្យខ្ញុំប្រឡងជាមួយពួកសិស្សយួន ដោយដាក់វិញ្ញាសាដូចគ្នាទាំងអស់ គឺសិស្សថ្នាក់ទី ៣ ។

ខ្ញុំធ្វើបានល្អត្រឹមត្រូវដែរ តែចាស់ខ្ញុំធ្វើយឺតយូរជាងគេ បើបារាំងវាថាប្រមូលយកទៅពេលម៉ោងដែលគេហើយគ្រប់គ្នានោះ ខ្ញុំធ្វើបានតែ ៧ ភាគ ១០ តែគេបណ្ដោយឲ្យខ្ញុំហើយក្រោយគេ ខ្ញុំខ្មាសកូនសិស្សជាតិយួន ដោយវាដឹងថា ខ្ញុំធ្វើជាគ្រូទៅហើយ មកធ្វើការមិនរហ័ស

ដូចរ៉ា ៗ ដល់ខ្ញុំពិនិត្យរកហេតុ ដែលកង្វេរហ៍សនិងខ្ញុំធ្វើយឺតយូរទៅ ឃើញថា ការគូសដីខ្មៅ ហើយដាក់ទឹកខ្មៅបង្ហើយ គេមិនបាច់គូរ, សរសេរដោយដីខ្មៅ ចាំងអស់នេះ ១ ដោយគេចាំគូរ ចាំសរសេរ ដោយទឹកខ្មៅតែម្តង ត្រង់ណាដែលឆ្គាយនោះ ៗ មួយទៀត ការដាក់ទឹកខ្មៅគេមិនចាំស្ងួតទឹកខ្មៅទើបដាក់បន្ទាត់ ដូចជាខ្ញុំខ្លាចដាម ខ្លាចប្រឡាក់នោះទេ គេមានបន្ទាត់ពិសេស ដែលមានកំណល់ចុងដើមបង្ហើបមិនឲ្យប៉ះដល់ក្រដាស ដែលមានគំនូសទឹកខ្មៅនៅសើម ៗ

ដល់ខ្ញុំត្រឡប់មកពីព្រៃនគរវិញ ខ្ញុំចង់រើបម្រះចេញពីសាលាទស្សា·កម្មដោយពិបាកនឹងយានជំនិះទៅមក ឆ្ងាយពីផ្ទះដែលមានចម្ងាយ ៥ គីឡូម៉ែត្រ បើគុណនឹង ៤ ដែលខ្ញុំទៅមក ៤ ដើង ក្នុង ១ ថ្ងៃ ឃើញជះកង់ចម្ងាយ ២០ គីឡូម៉ែត្រ ៗ

ខ្ញុំរកបាយដោយសរសេរសៀវភៅច្បាប់ក្បួនបង្រៀនគំនូរ ធរណី·មាណសាស្ត្រ ( ដេស័្សាង ហ្សេអូមេទ្រិក ) នៅខាងដើមសៀវភៅនេះ មានពាក្យផ្តើមដែលខ្ញុំរំលឹកអំពីគ្មានគ្រូខ្មែរ បេះគំនូរធរណីមាណ-សាស្ត្រ មានខ្ញុំម្នាក់ និងគ្រូបារាំងជាច្រើន ហើយបញ្ចូលគំនិតដែលខ្ញុំគិត ចង់ឲ្យខ្មែរបេះគំនូរ ដោយរបៀបណានោះ ៗ

ខ្ញុំយកសៀវភៅ ដែលខ្ញុំទើបនឹងសរសេរគូរ បានភាគខាងដើមបន្តិច យកទៅជូនលោកនាយកនៃការសិក្សា ដែលកាលនោះមាន

លោក អ៊ុំ-ឈាងស៊ុន និង លោក ទៀង-គង់ នៅទីនោះ ។ ខ្ញុំធ្វើជាសួមសួរថា សូមមេត្តាជួយឲ្យយោបល់ តើសៀវភៅបែបនេះ បើខ្ញុំសរសេរចប់ទៅ ហើយបោះពុម្ពលក់ ឬ ជូនមកពជការ តើវាមានប្រយោជន៍ឬទេ ?

ពេលនោះគេទទួលសៀវភៅខ្ញុំទុក ថាចាំមានពេលទំនេរពិនិត្យមើលៗ

ក្រោយពីពេលនោះមកមិនយូរប៉ុន្មាន ខ្ញុំបានគេផ្លាស់ឲ្យមកបង្រៀនគំនូរធរណីមាណសាស្ត្រទៅសាលាគរុវិជ្ជា ដោយកាលនោះ សាលាគរុ-វិជ្ជានៅជាប់នឹងវិទ្យាល័យស៊ីសុវត្ថិ ។

កាលនោះ អាយុខ្ញុំបាន ៤៥ ឆ្នាំ ខ្ញុំនៅតែជាប់គំនិតបង្រៀនសិស្សផង នាំលេងចំរៀង និង លេងកល់ផ្ទូនក្នុងផង តែដល់មានពិធីចែករង្វាន់ ឬ បុណ្យកឋិន ខ្ញុំតែងតែជួយលេងកំដរបរិយាកាស ឲ្យបានសប្បាយរីករាយ ហើយដល់ពេលវិស្សមកាល នាំអ្នកហាត់លេងចំរៀង ចេញទៅលេងខេត្តក្រៅ កាលឆ្នាំណោះ លោក កេង-វ៉ាន់សាក់ និង លោក ហាន់ ជុនហាក់ កាលនៅជាសិស្សវិទ្យាល័យនៅឡើយ បានទៅលេងជាមួយនឹងខ្ញុំ នាំគ្នាចូលទៅលេងក្នុងរោងកុន ឬ រោងល្ខោន នៅខេត្តកំពង់ចាម យកប្រាក់មកជួយជាតិ ។

ឯសិស្សសាលាគរុវិជ្ជានិងខ្ញុំ បាននាំគ្នាហាត់លេងរឿងកញ្ញា ដែលខ្ញុំសរសេរឲ្យលេងតាមគំនិតខ្លួន ៗ និងហាត់ចំរៀងគម្រូវតាមពិធីចែករង្វាន់ ឬ

បុណ្យផ្កា បុណ្យកឋិន ហើយមានបាននាំគ្នាទៅលេង ឲ្យគេមើលនៅខេត្តក្រៅ យកប្រាក់មកជួយសិស្សដែលទីទ័លក្រ ឲ្យទៅបន្តវិជ្ជាឯប្រ-ទេសបារាំង ។

បើសរសេរពីការដែលបានជួយសរសេរអត្ថបទ បានជួយគូររូបដាក់ក្នុងសារពត៌មាន ខ្ញុំត្រូវត្រឡប់ទៅសរសេរពីខាងដើមមកវិញថា : កាលអាក្សត់ជាតិម្នាក់ វានៅជាមនុស្សល្អនៅឡើយ វាបបួលបានគ្នាដប់នាក់ គឺខ្លួនវា ១ ឯ. ។. ស. រ. កាលនៅជាមេធាវី ១, លោក ប៊ិ-ហ៊ី-១, លោក ស៊ិ-រ-១, មហា ក-ស-១, មហា ច-១, លោកអាចារ្យ ស-១, លោក ជ-ម-១, និងខ្ញុំនេះ ១ បាននាំគ្នាចេញសារពត៌មានមួយឲ្យឈ្មោះថា ខេមរវត្ត គេចែកមុខការឲ្យខ្ញុំសរសេរអត្ថបទខាងសិល្បៈ មានរចនា និងរបាំជាដើម ខ្ញុំជួយធ្វើតាំងពីកាសែតនេះកើតរហូតដល់ស្លាប់ ដោយខ្ញុំមិនដឹងចិត្តគំនិតអាមេក្សត់នេះ ខ្ញុំស្មានថាវាធ្វើការជាប្រយោជន៍ដល់ជាតិ ខ្ញុំចេះតែជួយរហូតបាត់ខ្លួនវាម្តងទៅ ដល់វាត្រឡប់មកវិញ នាំធ្វើកាសែតមួយទៀតឲ្យឈ្មោះថា ខ្មែរក្រោក ខ្ញុំនៅតែស្មានថា វាជាមនុស្សល្អ ដោយពួកអ្នកដែលខ្ញុំរាប់ឈ្មោះបួនដប់នាក់មុននេះ ក៏បានចូលជួយដែរ ថែមតាំងមានលោកអ្នកថ្មីជួយទៀតមានលោក ម.យ និង ជ-ជ ជាដើម តាំងលោក រ.គ. និង ហ. ឆ. ហ. ក៏ចូលជួយធ្វើការកាសែតខ្មែរក្រោកនេះដែរ ។

ខ្ញុំស្តាយហោសែនស្តាយ ដោយរៀនកល់ពេលថ្ងៃសៅរ៍ ដែលយកអត្ថបទទៅជួបជុំគ្នានោះ មានប៉ូលិសចាំយាមឆ្មាំរកគាតខ្ញុំមើលហើយ កត់ឈ្មោះគ្រប់គ្នា លោកអ្នកដែលចូលនោះ ។

លុះដល់កាមេកសែតនេះ កាទៅជាមេក្បត់ជាតិចូលព្រៃបាត់ ទើបចាំងអស់គ្នាភាក់ខ្លួនភ័យជាក្រោយ ដោយមានឈ្មោះកង៍បញ្ចូលទៅថាជាពួកកា មានទោសប្រកាន់ចង់បណ្តេញខ្ញុំឱ្យលែងធ្វើការ ចង់បន្ទយថ្នាក់ស័ក្តិយសខ្ញុំ តែខ្ញុំសូមទោសគេថា ខ្ញុំមិនមែនជាអ្នកនយោបាយ ខ្ញុំជាកវីនិពន្ធជាវិចិត្រសិល្បករ ដោយខ្ញុំមានចំណេះនេះ គេហៅឱ្យជួយសរសេរ ជួយគួរ មិនមែនឱ្យជួយក្បត់ជាតិទេ ពក្បត់តែម្នាក់ឯង ខ្ញុំគ្មានបានទៅរួមគំនិតក្បត់ទេ ខ្ញុំសរសេរបំភ្លឺ សរសេរអប់រំគេទេតើ ។

គេលែងទោសប្រកាន់ទោសខ្ញុំ តែឈ្មោះខ្ញុំប្រឡាក់លាងមិនជ្រះ ខ្ញុំចង់ឱ្យជ្រះ ខ្ញុំចេញពីគណៈបក្សប្រជាធិបតេយ្យ មកសុំចូលក្នុង ចលនាសង្គមរាស្ត្រនិយម ។

ខ្ញុំចង់ឱ្យមានឈ្មោះជាអ្នកបកប្រែភាសាបារាំងមកជាភាសាខ្មែរ ខ្ញុំឃើញអក្សរបារាំងក្នុងសៀវភៅ ឬនៅកាសែត ដែលជាពាក្យមួយឃ្លា ពិបាកយល់សេចក្តី ពិបាកបកប្រែ ខ្ញុំយកមកបកប្រែគិតតាមសេចក្តីពន្យល់នៅក្នុង ឌិកស៊ីយ៉ូនែរ មួយម៉ាត់ម្តង លុះតែយល់ល្អបកប្រែជាខ្មែរបានសេចក្តីល្អ ។ ដោយពីដើមមិនទាន់មានគណៈកម្មការវប្បធម៌

គ្មានសៀវភៅបកប្រែពាក្យបារាំងមកជាពាក្យខ្មែរនៅឡើយ ខ្ញុំលេងតែម្នាក់ឯង ដល់លេងណាស់ទៅ ចេះតែយល់ឃើញភ្លាម ៗ សរសេរជាខ្មែរតាមសេចក្ដីនោះ ធ្វើជាសួរគេអ្នកមានសញ្ញាប័ត្រធំ ៗ ថាបើប្រែជាខ្មែរយ៉ាងនេះត្រូវឬទេ ? ជួនកាលយកឃ្លាណាដែលដឹងថា ពិបាកបកប្រែជាខ្មែរទៅសួរគេអ្នកចេះ ឲ្យគេជួយបកប្រែ តែគេមិនញាប់បកប្រែ គេគ្រាន់តែយល់សេចក្ដី មិនអាចនឹងសរសេរបកប្រែឲ្យខ្ញុំហើយត្រូវតាមពាក្យនោះ ដល់ខ្ញុំធ្វើជាសរសេរបកប្រែហើយ សួរថា បើប្រែយ៉ាងនេះត្រូវឬទេ គេឃើញថា ខ្ញុំពូកែដល់មា ការបកប្រែ គេហៅឲ្យជួយ ៗ ញយ ៗ ទៅល្បីឮឈ្មោះថាខ្ញុំចេះបកប្រែភាសាបារាំងមកជាភាសាខ្មែរល្អណាស់ ។

ខ្ញុំមានរឿងមួយទៀត ដោយគេបញ្ជូនសៀវភៅបោះពុម្ពអក្សរបារាំង ១ ក្បាល និងសៀវភៅសរសេរដោយដៃ ១ ក្បាល ជាអក្សរខ្មែរព្រមទាំងសំបុត្រមួយមកចៅហ្វាយខ្ញុំ ៗ ឲ្យគេហៅខ្ញុំមកជួបលោក ឃើញមុខខ្ញុំលោកសើចញឹម ៗ ហើយហុចសៀវភៅទាំងពីរនិងសំបុត្រមួយឲ្យខ្ញុំ ៗ មើលឃើញសេចក្ដីក្នុងសំបុត្រនោះ សូមលោកអាណិតឲ្យឈ្មោះ អៀង - សាយ មើលពិនិត្យកែឲ្យបានត្រឹមត្រូវ សៀវភៅដែលគេបកប្រែពីបារាំងមកជាខ្មែរដែលផ្ញើមកនេះ ។

(នៅមានត)

# សិរី នៃកបិលមហាព្រហ្ម

សហជីវិន ផល-ទិត នៅពុទ្ធសាសនបណ្ឌិត្យ

(១៣-៤-៦៣)

ដល់តែពេលចូលឆ្នាំថ្មី រឿងកបិលមហាព្រហ្មដែលចោទបញ្ហាអំពីសិរីចំពោះធម្មបាលមាណព គេតែងលើកឡើងមកសំដែងជាសាធារណៈអស់កាលយូរលង់មកហើយ, តើយើងបានចាប់ភ្លឹកនឹកនាដល់ន័យដ៏មានខ្លឹមសាររបស់ពាក្យថា សិរី នេះឬទេ ? បើបាននឹកនាដែរ, តើអ្វីទៅដែលហៅថា សិរី ?

តាមប្រភពរឿងព្រេងកបិលមហាព្រហ្មនេះ បានឲ្យដំណឹងដល់យើងថា សម័យកាលនោះ ពិភពមនុស្សលោក ឋិតនៅក្រោមទេវបញ្ជារបស់ព្រហ្មដែលនៅឯព្រហ្មលោក ។ ព្រះព្រហ្មបានចាត់ឲ្យកបិលមហាព្រហ្មមកគ្រប់គ្រង ដឹកនាំមនុស្សលោកឲ្យប្រតិបត្តិតាមទូវអ្វីៗគ្រប់យ៉ាងតាមទេវបញ្ជា ដោយហេតុគេយល់ថា មនុស្សលោក ជាកូនបង្កើតរបស់ព្រះព្រហ្ម គឺព្រះព្រហ្មហ្នឹងឯង ជាអ្នកបង្កើតពិភពលោកតាំងមូល ព្រមទាំងមនុស្សសត្វ និងសារពើធម្មជាតិទូទៅ ។

ប៉ុន្តែ ពិភពមនុស្សលោកនេះ ត្រូវបានផ្លាស់ប្តូរបរិនាយកថ្មីដែលមានជាតិជាមនុស្សដូចគ្នាវិញ ចាប់តាំងពីខណៈដែលមាណពម្នាក់មានសញ្ជាតជាមនុស្សឈ្មោះ ធម្មបាល បានជោគជ័យលើកបិល

មហាព្រហ្មក្នុងការដោះស្រាយបញ្ហា ហើយកបិលមហាព្រហ្មប្រគល់កិច្ចការដឹកនាំមនុស្សលោកឲ្យដល់ជាតិមនុស្ស រួចលោកកាត់ព្រះសិរៈក្ស័យព្រះជន្មនោះមក ។

សេចក្តីនេះ សឲ្យដឹងថា ប្រហែលជាពេលពីមុនមក ពុំទាន់មានជាតិមនុស្សណាម្នាក់ដែលមានសតិបញ្ញា អាចនឹងដឹកនាំពិភពលោកយើងនេះបានឡើយ ទើបការកិច្ចដឹកនាំនេះ ឋិតនៅក្នុងកណ្តាប់ព្រះហស្តរបស់ព្រះព្រហ្ម ។ លុះក្រោយមក ជាតិមនុស្ស កាន់តែចំរើនការចេះដឹងឡើងជាលំដាប់ រហូតដល់អាចគ្រប់គ្រងពិភពលោកដោយខ្លួនឯងបាន ទើបព្រះព្រហ្ម ទ្រង់ផ្ទេរក្រសួងគ្រប់គ្រងដឹកនាំពិភពលោកនេះ មកឲ្យមនុស្សលោកកាន់កាប់ផ្ទាល់ដោយខ្លួនឯងវិញ ។

ការកាត់ផ្តាច់នូវព្រះសិរៈរបស់ព្រះព្រហ្ម គឺជានិមិត្តរូបនៃការផ្ទេរអំណាចសព្វយ៉ាង, បានសេចក្តីថា ព្រះព្រហ្ម លោកផុតអំណាចដឹកនាំពិភពមនុស្សលោក ចាប់តាំងពីត្រឹមនោះ មក ។

ដើម្បីជាអនុស្សាវរីយ៍ និងដើម្បីសំដែងនូវកតញ្ញូតាចំពោះព្រះពជ-ហឫទ័យដ៏សប្បុរសរបស់ព្រះព្រហ្ម ដែលបានប្រគល់អំណាច និងសិទ្ធិគ្រប់យ៉ាងក្នុងកិច្ចគ្រប់គ្រងដឹកនាំពិភពលោក មកឲ្យមនុស្សលោកដោយមេត្តាករុណានេះ ទើបបានជាមនុស្សលោក តែងតែធ្វើពិធីយ៉ាងអធិករំឭកដល់ប្រវត្តិរបស់លោក ជារៀងរាល់ពេលចូលឆ្នាំថ្មីនេះឯង ។

រីឯបញ្ហា ដែលព្រះព្រហ្មលើកមកចោទសួរជាតិមនុស្ស ដើម្បីស្ទាបស្ទង់មើលសតិបញ្ញាការចេះដឹងនោះ គឺ បញ្ហាសិរី ។

ពាក្យថា សិរី នេះ បើនិយាយឲ្យខ្លីថា អ្វី ៗ ដែលជាប៉ែកខាងល្អប្រសើរ ហៅថា សិរី ទាំងអស់ ព្រោះវចនានុក្រមខ្មែរបានបញ្ជាក់ថា សិរី គឺ លំអ, លំអដែលគួរឲ្យស្រឡាញ់; សួស្ដី, ស្រីសួស្ដី; មង្គល; ជោគ; សេចក្ដីសុខ, សេចក្ដីចំរើន; បុណ្យ, ភ័ព្វបុណ្យ; ភ័ព្វព្រេង, សំណាងល្អ, ព្រេងសំណាងល្អ; ទ្រព្យ; ការមានបាន, លាភ; ឥស្សរភាព; តេជះ, អំណាច; រាជស័ក្តិ; ទិព្យស័ក្តិ; ភគវតី; លក្ស្មី ។ល។

ដូច្នេះ គប្បីយល់ថា បានជាព្រះព្រហ្មលើកយកសិរីមកចោទសួរមនុស្ស ព្រោះសិរីនេះ អាចចាត់ទុកបានថា ជានិមិត្តរូបនៃឥស្សរភាពរបស់មនុស្សលោកហ្នឹងឯង ។

ឥឡូវ យើងចង់ដឹងន័យខាងចំឡើយ របស់ធម្មបាលមាណព ដែលលើកយកទឹកមកឲ្យឈ្មោះថាសិរីវិញ, ចំឡើយនោះថា សិរី នេះ ពេលព្រឹកបិតនៅត្រង់មុខ ព្រោះពួកមនុស្សតែងភ្ញាក់ឡើងពីដេក ហើយយកទឹកមកលុបមុខរាល់តែពេលព្រឹក, ពេលថ្ងៃត្រង់បិតនៅត្រង់ដើមទ្រូង ព្រោះពួកមនុស្សកាលណាតែក្ដៅខ្លាំង តែងតែយកទឹកមកលាបស្រឡាបដើមទ្រូង, ពេលល្ងាចបិតនៅត្រង់ជើង ព្រោះពួកមនុស្សតែងយកទឹក

មកលាងជើងមុនទើបចូលដល់លោក ។ បានសេចក្ដីថា បើទឹក នៅទទឹក ទីនៅយ៉ាងណា, សិរី ក៏ឋិតនៅត្រង់អយ៉ាងនោះដែរ គឺទិក្កហ្នឹង ឯងជាសិរី ។

តើសមឬទេ ? ចំពោះបំឡើយធម្មបាលមាណពនេះ ដែលលើក ទិក្ក មកឲ្យឈ្មោះថា សិរី ។

តាមយោបល់ខ្ញុំ ថាសមហើយ ព្រោះសម័យនោះ នៅប្រទេស ឥណ្ឌា មានសាស្ដាច្រើនណាស់ ដែលប្រកាសលទ្ធិប្លែកៗ ពីគ្នា ។ បណ្ដាលទ្ធិទាំងនោះ, មានលទ្ធិខ្លះ គោរពភ្លើង, ខ្លះ គោរពសត្វអាសិរពិស, ខ្លះ គោរពដី, ខ្លះ គោរពខ្យល់ ។ល។ ខ្លះ គោរពទឹក ។ ដើម្បីឲ្យបានចំណេញឥទ្ធិពលរៀងខ្លួន, សាស្ដាទាំងនោះ ក៏ខំសំដែងរឿងកំរែងលទ្ធិរបស់ខ្លួនឲ្យឃើញអស្ចារ្យផ្សេងៗ ជាប្រភពបញ្ជាក់ថា លទ្ធិរបស់ខ្លួន ពិតជាលទ្ធិត្រឹមត្រូវប្រាកដមែន ។ ដូចលទ្ធិគោរពគោញី, មេលទ្ធិខំប្រឹងអួតសរសើរ អំពីគុណសម្បត្តិគោញី ជាជាព្រះនៃមនុស្សលោក, លទ្ធិគោរពភ្លើង, ក៏ប្រឹងពណ៌នា អំពីលទ្ធិនៃព្រះភ្លើងថា ជាព្រះនៃពិភពលោកមនុស្សយើងដែរ ។

ឯលទ្ធិគោរពទឹក ក៏ខំប្រឹងធៀតបញ្ចូលព្រះទឹក ទៅក្នុងទេវប្រវត្តិ លើកតំកើងទឹកថា ជាវត្ថុពិសេសបំផុតក្នុងលោក ដូចគ្នាដែរ ។ យ៉ាងហ្នឹងហើយ បានជាទឹកក្នុងរឿងមហាព្រហ្មនេះ លោកចាត់ទុកថាជា

សិរីរបស់ពិភពលោក គឺគេចាត់ទឹកនេះទុកជា ជាតែសក្តិសិទ្ធិបំផុត រហូតដល់មានគេជះសាចទឹករំដោះយកឥស្សរភាពនៃមនុស្សលោក អំពីព្រះព្រហ្មដែលជាកំពូលនៃត្រៃលោកបានទៀតផង ។

ម្យ៉ាងទៀត ទឹក នេះ ជារបស់យ៉ាងចាំបាច់របស់មនុស្សសត្វ ព្រោះមនុស្សសត្វត្រូវការទឹក ដើម្បីរស់ ហើយក៏ជារបស់ចាំបាច់ ម្យ៉ាងទៀត គឺមនុស្សត្រូវការប្រើប្រាស់ទឹកសំរាប់ជូតជំរះកាយ, លាង សំអាតនូវអ្វី ៗ ដែលប្រឡាក់ និងសំរាប់លាបស្រឡាបឲ្យត្រជាក់ ។ល។ ដូច្នេះ លុមតែចាត់ ទឹក ទុកជា ជាសិរី បានមែន ។

ប៉ុន្តែ បើឲ្យរិតតែសមជាងនេះទៅទៀត គឺទឹកដែលចាត់ទុកជាជា សិរីនេះ សំដៅយកទឹកចិត្តត្រជាក់របស់មនុស្សលោក ។ មនុស្ស ក្នុងលោកនេះ តែងមានភាពពុំស្មើគ្នា ដូចជា ខ្លះមានកម្លាំងច្រើន, ខ្លះ ខ្សោយ, ខ្លះបេះ, ខ្លះល្ងង់, ខ្លះមានប្រាជ្ញា, ខ្លះអប្បប្រាជ្ញា, ខ្លះមាន ទ្រព្យច្រើន, ខ្លះក្រីក្រ, ខ្លះមានអំណាច, ខ្លះអាប់រស្មី ។ល។ ខ្លះជាមហាអំណាច, ខ្លះនៅទន់ខ្សោយ ។ ការខុសសភាពគ្នានេះ បើមនុស្សក្នុងលោកពុំយកទឹកចិត្តត្រជាក់ មកប្រើសម្រាប់លាងជំរះ ដោះស្រាយបញ្ហាផ្សេង ៗ រវាងគ្នានោះ ពិភពលោកនេះ ទិសដៅទៅ រកការក្តៅក្តីអន្តរាយយ៉ាងឆាប់រហ័ស ព្រោះតែភ្លើងចិត្តដ៏ក្តៅ ដ៏ ប្រចាញទៅ ។ ដូច្នេះ សិរី សំដៅយកទឹកចិត្តត្រជាក់នេះ

ឃើញថា ត្រូវហើយសមៈទៀតផង ដែលពុំចាំបាច់កែប្រែទៀតឡើយ ព្រោះធីតាចិត្តដ៏ត្រជាក់ ជាសភាវៈអាចគ្រប់គ្រងពិភពលោក ឲ្យបានសេចក្តីសុខ សេចក្តីចំរើន ជោគ មង្គល តេជះ អំណាច ឥស្សរភាព ។ល។ រីឯភ្លើងចិត្តដ៏ក្តៅវិញ ជាសភាវៈពុំមែនជាកត្តានៃសិរី គឺរាំពុំអាចគ្រប់គ្រងពិភពលោក ឲ្យកើតសិរីដូចបំណងព្រះព្រហ្មបរមទេវៈនោះបានឡើយ ។

ហេតុដូច្នោះហើយ បានជាធីតានេះ លោកចាត់ទុកថាជា សិរី ។

---

សួស្តីជ័យជោគលោកពពៃ
ពង្សឆ្នាំមមែពូជទេពតា
តាយកព្រះនាមកិម៉ិន្ន
បួលវែនរក្សាពិភពមនុស្ស

# ផ្នែកកំណត់ និង ប្រវត្តិការណ៍

## អនិច្ចធម្មនៃព្រះមហាវីរវង្សាចារ្យ

ភិន សាឌុម

ព្រះតេជព្រះគុណព្រះមហាវីរវង្សាចារ្យ ភិន - សាឌុម, ព្រះរាជាគណៈ ថ្នាក់ត្រី, ជាសមាជិកក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ គង់នៅវត្តទួនមណីរាម សង្កាត់លេខ ៦ ក្រុងភ្នំពេញ. បានទទួលអនិច្ចធម្ម កាលពីថ្ងៃអាទិត្យទី ២២ មករា ១៩៦៧ ដោយរោគាពាធ ក្នុងព្រះជន្ម ៦០ ឆ្នាំ នៅមន្ទីរពេទ្យព្រះកេតុមាលា ។ ពុទ្ធបរិស័ទ បានរៀបចំតំកល់ព្រះសពនេះយ៉ាងសមរម្យថ្កុំថ្កើង តាមប្រពៃណី នៅវត្តទួនមណីរាម ហើយធ្វើបុណ្យទក្ខិណានុប្បទាន ឧទ្ទិសកុសលចំពោះព្រះសព រៀងរាល់ថ្ងៃ ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះសង្ឃនាយក, ចាប់តាំងពីថ្ងៃចន្ទទី ២៣ មករា ដល់ថ្ងៃចន្ទទី ៣០ មករា ១៩៦៧ ដែលជាថ្ងៃត្រូវបូជាព្រះសព ។

ពុទ្ធសាសនបណ្ឌិត្យ មានសេចក្តីសោកស្តាយយ៉ាងក្រៃលែង ចំពោះការបាត់បង់ព្រះមហាថេរអង្គនេះ ដែលជាព្រឹទ្ធសមាជិកមួយអង្គ មានសមត្ថភាពដ៏ខ្ពង់ខ្ពស់ ក្នុងវិស័យព្រះពុទ្ធសាសនា គួរឲ្យសរសើរ ក្នុងចំណោមព្រឹទ្ធសមាជិកឯទៀតទាំងឡាយ នៃក្រុមជំនុំព្រះត្រៃបិដក ។

ក្នុងថ្ងៃចន្ទទី ៣០ មករា ១៩៦៧ ពេលម៉ោង ២ កន្លះរសៀល

គណៈកម្មការចាត់ការបុណ្យ ព្រមទាំងពុទ្ធបរិស័ទទាំងឡាយ ទាំងបណ្ឌិត ទាំងគ្រហស្ថ បានរៀបចំពិធីដង្ហែព្រះសពជាក្បួនផ្លូវការ យ៉ាងឱឡារិក អធិកអធម ចេញពីវត្តទួនមណីកមទៅតាមវិថីបុណារស, វិថីព្រះសុរាម្រឹត. មហាវិថីព្រះនរោត្តម ទៅចួបនឹងវិថីសុធារសវិញ បត់ចូលទៅកាន់ឈាបនដ្ឋាន ដែលសង់ទុនាវិចិត្រជារបៀបមណ្ឌប នៅមុខព្រះវិហារវត្តទួនមណីកម ។

ពិធីបូជាព្រះសពនេះ បានធ្វើឡើងក្រោមព្រះរាជាធិបតីភាពនៃអ្នកអង្គម្ចាស់ នរោត្តម-កន្តុល អគ្គនាយកក្រសួងនាគ្គបរមរាជវាំង ជាព្រះរាជតំណាងនៃសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ដោយមានសមាជិកសភាទាំងពីរ, សមាជិកគណៈរដ្ឋមន្ត្រី មួយរអន្លើដោយមន្ត្រីអ្នករាជការជាច្រើន បានចូលរួមក្នុងពិធីនេះផង ៗ ផ្នែកខាងព្រះសង្ឃ, មានសម្ដេចព្រះសុធម្មាធិបតី ទេព-លៀង ព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ, សម្ដេចព្រះពោធិវង្ស ហួត-តាត ជាព្រះរាជតំណាង នៃសម្ដេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជគណៈមហានិកាយ ព្រមទាំងព្រះសង្ឃរាជាគណៈ បានានុក្រម ភិក្ខុ-សាមណេរទាំងឡាយ ៗ

មុននឹងបូជាព្រះសព, សហជីវិន គុយ-ពៅ អនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសុន្ទរកថា ទិន្នន័យប្រវត្តិនៃព្រះមហាវិរវង្សចាប ពិន-សាឌុម ៗ បន្ទាប់មក, មានសុន្ទរកថាតំណាងសម្ដេចព្រះសង្ឃនាយក ៗ ឯសុន្ទរកថា ទាំងពីរ យើងសូមចុះផ្សាយដូចតទៅនេះ ៖

## សុន្ទរកថា

ព្រះសមុហ៍ពុទ្ធាចារ្យ ញុង - ប៊ុណ្ណា ជាតំណាងសម្ដេច

ព្រះសុធម្មាធិបតីព្រះសង្ឃនាយក ព្រះនាមគន្ធបេ ឆេក - លៀង

សូមទូលព្រះពុទ្ធដីកា ព្រះករុណាគ្រប់ព្រះអង្គ

សូមថ្វាយព្រះពរ សម្ដេច - ទ្រង់ - ឯកឧត្ដម - លោកជំទាវ

អស់លោក-អ្នកសប្បុរសទាំងឡាយ

សូមគោរព - សូមទ្រង់ជ្រាប - សូមជ្រាប ។

ខ្ញុំព្រះករុណា អាត្មាភាព សូមអភ័យទោសអំពីសំណាក់ព្រះតេជព្រះគុណ ព្រះករុណាគ្រប់ព្រះអង្គ – ទ្រង់ – ឯកឧត្ដម លោកជំទាវ-អស់លោកអ្នកទាំងឡាយ ដ្បិតពេលនេះ ខ្ញុំព្រះករុណា អាត្មាភាព បានទទួលព្រះបញ្ជាពីសម្ដេចព្រះសង្ឃនាយក ឲ្យថ្លែងសុន្ទរកថា ជំនួសព្រះអង្គ ដូចមានសេចក្ដីដើមទាំងស្រុងតទៅ :

## សុន្ទរកថា

– សូមពិតព្រះថេរានុថេរៈ គ្រប់ព្រះអង្គ មានសម្ដេចព្រះពោធិវង្ស ជាដើម ។

— សូមថ្វាយព្រះពរ អ្នកអង្គម្ចាស់ព្រះរាជតំណាងនៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

— សូមថ្វាយព្រះពរ សម្តេចព្រះរាជកិច្ចារង្សីសោភ័ណ និងព្រះរាជវរានុវង្ស

— សូមចំរើនពរ ឯកឧត្តម លោកជំទាវ និងអស់លោក-អ្នក ពុទ្ធបរិស័ទទាំងឡាយ

សូមទ្រង់ជ្រាប-សូមជ្រាប ។

ក្នុងនាមនៃសម្តេចព្រះសង្ឃនាយក ក្នុងនាមនៃគណៈកម្មការវត្ត និងក្នុងនាមនៃសិស្សានុសិស្ស ក្រុមគ្រួសារញាតិមិត្តនៃសព ជាបឋមខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងអំណរព្រះមហាករុណាធិគុណ យ៉ាងជ្រាលជ្រៅបំផុតចំពោះសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត ដែលព្រះអង្គសព្វព្រះរាជហឫទ័យ ចាត់ព្រះរាជតំណាង យាងមកជាព្រះរាជាធិបតីក្នុងឱកាសនេះ ព្រមទាំងព្រះគុណដែលព្រះអង្គទ្រង់បានចំណាយព្រះរាជទ្រព្យយ៉ាងច្រើនលើសលុប ក្នុងការព្យាបាលរោគព្រះមហាវិរវង្សាចារ្យ ហ៊ិង-សាធុម ចាប់តាំងពីលោកមានអាពាធ រហូតដល់ថ្ងៃនេះបុណ្យធម្ម ស្រម្បៃតពិធីបូជាសពព្រះមហាវិរវង្សាចារ្យ ហ៊ិង-សាធុម ដែលបានប្រព្រឹត្តទៅ យ៉ាងឧឡារិក ក្នុងឱកាសនេះ គឺសុទ្ធតែស្ថិតនៅក្រោមព្រះរាជូបត្ថម្ភ នៃសម្តេចជាអម្ចាស់ជីវិតទាំងអស់ ។

— ចំពោះព្រះករុណាទិគុណដ៏មហិមានេះ ធ្វើឲ្យអាត្មាភាពនិងពុទ្ធបរិស័ទ សិស្សានុសិស្ស ក្រុមគ្រួសារញាតិមិត្តទាំងអស់ មានសេចក្ដីរំភើបចិត្តរកទីបំផុតគ្មាន ហើយសូមកំណត់ចាំទុកក្នុងចិត្តឥតភ្លេចជាប់អស់មួយជីវិត ។

បពិត្រព្រះករុណាថ្លៃវិសេស អាត្មាភាពសូមព្រះរាជានុញ្ញាត ព្រះបរមរាជវរោកាស ថ្វាយអំណរព្រះមហាករុណាទិគុណចំពោះសម្ដេចជាអម្ចាស់ ព្រមទាំងទ្រង់ ឯកឧត្តម លោកជំទាវ លោកស្រី និងអស់លោក-អ្នកទាំងឡាយ ដែលបានចំណាយព្រះរាជទ្រព្យ ព្រមទាំងកម្លាំងកាយ, កម្លាំងចិត្ត ក្នុងការព្យាបាលរោគ ព្រះមហាវីរវង្សាចារ្យ ក៏ង - សាឧុមក្ដី ក្នុងការចាត់ចែងបូជាសពក្ដី និងសូមថ្លៃងអំណរគុណ ចំពោះព្រះរាជរដ្ឋាភិបាល មានក្រសួងធម្មការ និង ពុទ្ធសាសនបណ្ឌិត្យ; រាជការក្រុង និងក្រុមព្រះបរមរាជវាំងជាដើម ដែលមានចិត្តជ្រះថ្លា ជួយរៀបចំក្នុងពិធីបុណ្យសពនេះយ៉ាងក្រៃលែង ។

ព្រះមហាវីរវង្សាចារ្យ ! ពិតមែនតែលោកបានអនិច្ចធម្មលះលោកនេះ ទៅកាន់បរលោកហើយក៏ដោយ តែគុណសម្បត្តិ និងបរិយាសម្បត្តិរបស់លោកទាំងអស់ ទ្រង់ព្រះករុណាថ្លៃវិសេសក្ដី ពួកពុទ្ធបរិស័ទទាំងឡាយក្ដី នៅនឹករលឹកឃើញជានិច្ច ឥតភ្លេចឡើយ ។

ចំពោះពាក្យពេចន៍ ដ៏ប្រកបដោយគតិបណ្ឌិតទាំងប៉ុន្មានរបស់

លោក គ្រូសិស្សានុសិស្ស និងញាតិមិត្តនៅចាំជាប់ក្នុងចិត្ត ហើយនិង ប្រតិបត្តិតាមតទៅ ។

នៅទីអវសាននេះ ខ្ញុំព្រះករុណា អាត្មាភាព សូមលើកបុញ្ញរាសី ដែលកើតមានឡើងអំពីកិច្ចខ្វល់ខ្វាយគ្រប់យ៉ាង ក្នុងពិធីបុណ្យបូជាសពនេះ ថ្វាយជាព្រះរាជកុសល ចំពោះសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត និងសម្តេចព្រះប្រមុខរដ្ឋ សូមព្រះអង្គមានព្រះសុខភាពបរិបូណ៌ មាន ព្រះជន្មយឺនយូរ ប្រកបដោយតេជៈបារមី ឈ្នះអស់មារសត្រូវគ្រប់ ទិសទី ដើម្បីបានជាម្លប់ដ៏ត្រជាក់ នៃពុទ្ធសាសនិក និង ប្រជាពលករ ក្នុងកម្ពុជរដ្ឋទាំងមូលរៀងទៅ ។

មួយចំណែកទៀត សូមថ្វាយព្រះរាជកុសលចំពោះសម្តេចព្រះវរកនិដ្ឋា វិស្សោភ័ណ ទ្រង់ ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក-អ្នកពុទ្ធបរិស័ទទាំងឡាយ សូមទ្រង់បានប្រកប និងបានប្រកបដោយ ពុទ្ធពរ ៤ ប្រការ គឺ : អាយុ , វណ្ណ , សុខ , ពល កុំបីអាក់ខានឡើយ ។

សូមថ្វាយព្រះពរ សូមចំរើនពរ

# សុន្ទរកថា

សហជីវិន គុយ-ពៅ អនុរដ្ឋលេខាធិការ
ក្រសួងធម្មការ និង សាសនសិក្សាធិការ

សូមព្រះរាជទានក្រាបបង្គំទូល អ្នកអង្គម្ចាស់ព្រះរាជតំណាង នៃ សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ជ្រាប ។

ក្នុងនាមរាជរដ្ឋាភិបាល និង ក្នុងនាមក្រសួងធម្មការ និង សាសនសិក្សាធិការ ព្រមទាំងក្នុងនាមពុទ្ធបរិស័ទទាំងអស់ ដែលបានមកជួបជុំក្នុងពិធីបូជាសព ព្រះតេជព្រះគុណព្រះមហាវិរវង្សាចារ្យ ហ៊ំង-សាឌុម ជាគណៈថ្នាក់ទី ៣ នេះ, ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយនូវសេចក្ដីគោរពស្វាមីភក្ដិយ៉ាងជ្រាលជ្រៅបំផុត ចំពោះព្រះអង្គ ព្រះរាជតំណាង ដែលស្ដេចយាងមក ជាព្រះរាជាធិបតីខ្ពង់ខ្ពស់ក្នុងពិធីនេះ ។

ព្រះរាជវត្តមាននៃព្រះអង្គ ព្រះរាជតំណាង „ សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង " នៅពេលនេះ, មិនត្រឹមតែញ៉ាំងពិធីបុណ្យឲ្យថ្កើងរុងរឿងយ៉ាងគ្រឹកគ្រេងប៉ុណ្ណោះទេ, ថែមទាំងជាសក្ខីភាពមួយប្រសើរបំផុត ចំពោះព្រះពុទ្ធសាសនា ដែលបង្ហាញថាបានទទួលសេចក្ដីឧបត្ថម្ភយ៉ាងសកម្ម និងយ៉ាងមេត្តាប្រោសប្រណីបំផុត អំពីសំ-

ណាក់ព្រះរាជបល្ល័ង្ក តាំងពីបុរាណកាលមក ។

សូមទ្រង់ព្រះមេត្តាប្រោស

ព្រះសពព្រះមហាវីរវង្សវាចារ្យ ហ៊ិង-សា ឌុម នេះ ធ្លាប់បានទទួល ឧបត្ថម្ភពិសេស ពីសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង តាំងតែកាលគង់ព្រះជន្មនៅ រហូតដល់អនិច្ចធម្ម ចាកលោកនេះទៅ, លុះដល់វេលារំលាយព្រះសពទៀត សម្តេចជាអម្ចាស់ទ្រង់សព្វព្រះរាជហឫទ័យ ចាត់ព្រះអង្គព្រះរាជតំណាង ស្តេចយាងមកជាព្រះរាជាធិបតីទៀត ។

សូមទ្រង់ព្រះមេត្តាប្រោស

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជានុញ្ញាត ដើម្បីថ្វាយក្នុងពេលនេះ នូវអំណរព្រះគុណ -អំណរគុណចំពោះសម្តេច ទ្រង់ ឯកឧត្តម និង សមាជីវិន -សហជីវិនទាំងអស់ ដែលទ្រង់ស្តេចយាងនិងអញ្ជើញមករួមក្នុងពិធីបុណ្យ ដែលជាការគោរព ជាចុងក្រោយបំផុតចំពោះព្រះសពនេះ និង ជាការបានអនុមោទនា យកកុសលមគ្គផលផង ជាការហែហមព្រះរាជដំណើរ និងញុំាងពិធីបុណ្យនេះ ឲ្យបានរុងរឿងផង ។

ឱកាសនេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំបាទ សូមព្រះរាជានុញ្ញាត សូមអនុញ្ញាតថ្វាយរាប់រៀបអំពីព្រះជីវប្រវត្តិ និង អំពីកិត្តិគុណនៃព្រះសពដែលលោកបានបំពេញមកតាំងពីមានព្រះជន្មនៅឡើយ ។

ព្រះតេជព្រះគុណព្រះមហាវីរវង្សវាចារ្យគិរិស្សរោ ហ៊ិង-សា ឌុម

ប្រសូតពីថ្ងៃ ច័ន្ទ ៨ កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៤៤៧ គ.ស. ១៩០៤ នៅសង្កាត់កំពង់ចាស់ ស្រុកឧដុង្គ ខែត្រកំពង់ស្ពឺ ។ បិតានាម សៀង មាតានាម អ៊ុច ជាអ្នកតំណពូជពង្ស អំពីឧកញ៉ារាជមន្ត្រីនាម ស៊ុំ និងឧកញ៉ាសុមេធាសិរីនាម សួស្តិ៍ ជាមន្ត្រីជាន់ខ្ពស់សម័យរាជវាំងឧដុង្គមានជ័យ ។ កាលពីអាយុ ៧ ឆ្នាំ កុមារ ប៉ាង-សាឌុម បានចូលទៅរៀនអក្សរខ្មែរ ក្នុងសំណាក់ព្រះវិនយរក្ខិត ប៉ាត ចៅអធិការវត្តព្រះសុគន្ធមានបុណ្យ (ឧដុង្គ) ។ លុះដល់ជន្មាយុបាន ១៤ ឆ្នាំ បានចូលបួសជាសាមណេរ ដោយមានព្រះវិមលធម្មព្រះនាម ម៉ា ជាឧបជ្ឈាយ៍ ហើយនៅសិក្សាធម្មវិន័យ ក្នុងទីនោះអស់ពេល ២ ឆ្នាំ រួចហើយសាមណេរ ប៉ាង-សាឌុម ក៏លាលោកគ្រូឧបជ្ឈាយ៍ មកបន្តការសិក្សាអក្ខរបាលី នៅក្នុងសំណាក់ព្រះញាណវិរិយៈព្រះនាម ឡុង ចៅអធិការវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។ លុះព្រះជន្មគម្រប់ ២១ ឆ្នាំ ក៏បានបំពេញឧបសម្បទ ជាភិក្ខុ ដោយមានព្រះញាណវិរិយៈ ឡុង ជាឧបជ្ឈាយ៍ មានព្រះគន្ធរេ ជាន់ ជាឧបសម្បទាចារ្យ ។ ព្រះជន្ម ២៤ ឆ្នាំ លោកបានប្រឡងប្រជែងជាប់ចូលរៀននៅសាលាបាលីជាន់ខ្ពស់អស់រយៈ ៤ ឆ្នាំ ក៏ប្រឡងជាប់សញ្ញាប័ត្រចេញពីសាលានេះ ។

ចំពោះកិច្ចការ ដែលព្រះសពបានបំពេញមក គឺ :

- បានធ្វើជាអាចារ្យបង្រៀនសាលាបាលីរង នៅវត្តទួលមណីរាម តាំងពីមានព្រះជន្ម ១៨ ឆ្នាំ ។

- បានធ្វើជាសមាជិកក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ តាំងពី គ.ស ១៩៣៧ រហូតមកដល់ពេលសុគត ។

- បានធ្វើអធិការគ្រូសាលាបាលីរងក្នុងនាទីខេត្រកំពតនិងតាកែវ ពី គ.ស. ១៩៤៣ ។

- បានធ្វើជាសមាជិកគណៈមេប្រយោគ ប្រឡងសញ្ញាប័ត្រៈផ្សេងៗ ក្នុងពុទ្ធិកសិក្សាតាំងពី គ.ស. ១៩៤២ ។

- បានចូលជាសមាជិកគណៈកម្មការវប្បធម៌ សម្រាប់ប្រែពាក្យបារាំងមកជាខ្មែរ និងបង្កើតពាក្យថ្មី តាំងពី គ.ស. ១៩៤៦ ។

- បានរួមជាសមាជិកគណៈប្រតិភូខ្មែរ ទៅប្រជុំធ្វើឆដ្ឋសង្គាយនា នៅប្រទេសភូមា កាល គ.ស. ១៩៥៦ ។

- ជាសមាជិកក្រុមជំនុំតែងសៀវភៅធម្មវិន័យពី គ.ស.១៩៤៨ ។

- ជាសមាជិកគណៈកម្មការរៀបចំកម្មវិធីសិក្សា សាលាបាលីជាន់ខ្ពស់ ពី គ.ស. ១៩៥១ ។

- ជាអនុប្រធានគណៈប្រតិភូខ្មែរ រួមប្រជុំសន្និសីទលើកទី ៦ នៃពុទ្ធិកសមាគមពិភពលោក ដែលធ្វើនៅក្រុងភ្នំពេញពី គ.ស.១៩៦១ ។

- ជាសមាជិកទីប្រឹក្សា នៃមន្ទីរសង្ឃពេទ្យព្រះកុសុមៈ ។

– ជាសមាជិកទីប្រឹក្សាផ្នែកសាសនា នៃចលនាកាយឫទ្ធិ សម្ដេចព្រះមហាក្សត្រិយានី ពី គ.ស. ១៩៥៧ ។

និងជាសមាជិកនៃសមាគមខាងពុទ្ធសាសនា ពុគណ កម្មការផ្សេងៗ ក្នុងការបកប្រែភាសាបាលី បោះពុម្ពផ្សាយធម៌អាថ៌ និងការកសាងនានា ជាច្រើនទៀត ។

បំណែកគុណសម្បត្តិពិសេសរបស់ព្រះសពអង្គនេះគឺ លោកមានឥរិយាបថសុភាពរាបសា ជាទីរាប់អាននៃមនុស្សទូទៅឥតរើសមុខ ជាទីគោរពរាប់អាននៃសិស្សគណ ព្រមទាំងឧបាសក-ឧបាសិកាទាំងអស់ ដែលធ្លាប់បានមកប្រស្រ័យជាមួយលោក ៗ មិនតែប៉ុណ្ណោះសោត លោកមានប្រាជ្ញាវាងវៃរៀនសូត្រឆាប់ចេះចាំ ហើយប៉ិនប៉ាវបង្ហាត់បង្រៀនដល់អ្នកដទៃថែមទៀត ។ ព្រះសពបានទទួលគ្រឿងឥស្សរិយយសទី អស្សបុទ្ធិមុនីសោភារណ៍ ជាសក្ខីភាពផង ៗ សន្ដានចិត្តលោកតែងជាប់ជំពាក់ក្នុងការកសាងសប្បុរិសធម៌គ្រប់បែបយ៉ាង ព្រមទាំងឧបត្ថម្ភព្រះពុទ្ធសាសនា គ្មានវេលាក្ដួចក្ដាំងថ្ងៃណា ៗ រីឯបច្ច័យទាំងឡាយ ដែលទាយកការ បានបវារណាចំពោះព្រះអង្គលោក, លោកតែងយកទៅបំណាយក្នុងកិច្ចការសង្គ្រោះ និង ឧបត្ថម្ភដល់មនុស្សជាតិជានិច្ច មានផ្នែកវប្បធម៌ និង សង្គមកិច្ចជាដើម ឧទាហរណ៍គឺ លោកបានចែងមុនអនិច្ចធម្ម ធ្វើជាបណ្ដាំជាលាយលក្ខណ៍អក្សរ បែងចែកនូវបច្ច័យដែលមានទាំងអស់

៣៧.៤១២៛០០ ឲ្យទៅជាការឧបត្ថម្ភកសាងការស្ថាបនាផ្សេងៗ ក្នុងពុទ្ធសីមា និងអង្គការសង្គ្រោះដទៃទៀត ដូចតទៅនេះគឺ :

១ ឧបត្ថម្ភសាលាពុទ្ធិកបឋមសិក្សាវត្តសាលាគូ (ឧដុង្គ) ២៧.៩០០៛០០

២– ជីកស្រះខាងត្បូងវត្តសុគន្ធមានបុណ្យ (ឧដុង្គ) ៤៧.៩០០៛០០

៣– ឧបត្ថម្ភបណ្ណាល័យវត្តទួទមណីកម . . . . ៤១.២៥០៛០០

៤– ជួយដល់ក្រុមកាកបាទក្រហមខ្មែរ . . . . ១៣.៧៥០៛០០

៥– ជំនួយចំពោះបរិយត្តិ ក្នុងពុទ្ធសាសនា . . . ២០.០០០៛ ០

៦– ជួយគិលានសង្គ្រោះ-កុមារសង្គ្រោះ . . . . ២០.០០០៛០០

៧– កសាងឈាបនដ្ឋានអនាម័យ . . . . . . ២០.០០០៛០០

៨– ជួយក្នុងការកសាងវិហារថ្មី វត្តទួទពណីកម .. ២០.០០០៛០០

៩– ជួយសាលាពុទ្ធិកបឋមសិក្សា វត្តទួទមណីកម ១៤៧.៨៨៩៛០០

១០– សម្រាប់ធ្វើទក្ខិណានុប្បទាន . . . . . ៣៦.៥២៣៛០០

សូមទ្រង់ព្រះមេត្តាប្រោស

តាំងអស់នេះ ជាព្រះសកម្មភាពយ៉ាងចម្លែក ដែលគួរកត់សំគាល់ និង ពុំអាចបំភ្លេចបាន របស់ព្រះសព ។

តពីនេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំបាទសូមព្រះរាជឱកាស សូមឱកាស ថ្វាយជាអវសាន ចំពោះទៅកាន់ព្រះសពជាទីអាល័យដូចតទៅនេះ :

បពិត្រព្រះសពជាទីគោរព

ព្រះរូបកាយនៃព្រះតេជព្រះគុណ បានបាត់បង់ទៅតាមអនត្តាធម៌ ជាដី ទឹក ភ្លើង ខ្យល់ ទៅហើយ ប៉ុន្តែព្រះនាមគង់នៅជាប់ជានិច្ច ក្នុងសន្តានចិត្តយើងខ្ញុំព្រះករុណា ជាពុទ្ធបរិស័ទគ្រប់ ៗ កាល ៗ យើងខ្ញុំព្រះករុណាពុំភ្លេចទេ នូវកិត្តិគុណពិសេស របស់ព្រះតេជព្រះគុណ កាលគង់ជន្មានៅឡើយ, ព្រះតេជព្រះគុណជាព្រះថេរមួយអង្គ ដែលមានគុណសម្បទ សមត្ថភាព និង វិរិយធម៌ គួរគោរពសរសើរពន់ពេក ៗ សូម្បីតែមានរោគាមកញាំញីព្រះកាយហើយក្តី ព្រះតេជព្រះគុណតែងមានថេរដីកាឡើយ ៗ ថា : « មច្ចុរាជ គេអ្នកមកធ្វើបាបកងកាយយើងដល់ណាទៀត ! ខន្ធ ៥ គឺរូប វេទនា សញ្ញា សង្ខារ និង វិញ្ញាណធ្វើទុក្ខយើងណាស់តែ យើងពុំសុខនឹងអ្នកទេ ! » មិនតែប៉ុណ្ណោះ ពេលណាព្រះរាជគណៈ ក្រុមញាតិ ឬឧបាសក ឧបាសិកាណាមួយ ទៅសាកសួរ ព្រះតេជព្រះគុណតែងតែសម្តែងធម៌ជាប្រៀនប្រដៅ រំលឹកឲ្យស្គាល់នូវអនិច្ចតាធម៌របស់ជីវិតសត្វលោក ជាដរាប ៗ ហេតុនេះហើយបានជានៅពេលដែលព្រះតេជព្រះគុណទទួលអនិច្ចធម្ម គឺទទួលប្រកបដោយភាពស្ងប់ស្ងាត់ជាទីបំផុត នារាត្រីរំលងអធ្រាត្រនៃថ្ងៃ ១៣ កើត ខែមាឃ ត្រូវនឹងថ្ងៃទី ២៣ មករា ១៩៦៧ ក្រោមព្រះរាជូបត្ថម្ភសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ដែលព្រះ

អង្គទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន ព្រះរាជទ្រព្យជាច្រើន ដើម្បីព្យាបាលរោគាពាធនេះ ។ ក្នុងខណៈនេះ យើងខ្ញុំព្រះករុណា សូមឧទ្ទិសកុសលចំពោះវិញ្ញាណក្ខន្ធនៃព្រះសព សូមបានសុគតក្នុងភពថ្មី ប្រកបដោយសុខៈក្សេមក្សាន្តជាតិយ្យាភាព ហើយព្រះកិត្តិនាមព្រះអង្គនៅតែចារឹកយ៉ាងច្បាស់ក្រឡែត ពុំអាចលុបបានក្នុងលោកនេះ ដូចពុទ្ធភាសិតថា ៖

« រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ » ។

សូមទ្រង់ព្រះករុណាប្រោស

នៅទីបំផុតនេះ ទូលព្រះបង្គំជាខ្ញុំ សូមថ្លែងកតញ្ញុតាជាថ្មីម្តងទៀត ថ្វាយចំពោះព្រះអង្គព្រះរាជតំណាង សូមទ្រង់មេត្តាក្រាបបង្គំទូលថ្វាយ សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ដែលទ្រង់សព្វព្រះរាជហឫទ័យ ចាត់ព្រះអង្គមកជាព្រះរាជតំណាង ក្នុងឱកាសបុណ្យឈាបនកិច្ចដ៏ធំធេងនេះ ហើយទូលព្រះបង្គំជាខ្ញុំទាំងឡាយ សូមលំអុតលំឱនកាយបួងសួងចំពោះគុណានុភាពនៃព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងរបស់ក្នុងលោក សូមជួយតាំងការអភិបាល រក្សាព្រះសុខភាពព្រះអង្គឲ្យក្សាន្តនិរាបាធអង្វែង ដើម្បីបានជាម្លប់យ៉ាងត្រជាក់ នៃប្រជាជាតិខ្មែរទូទៅ ។ មួយចំណែកទៀត សូមឲ្យតេជានុភាព និងផលានិសង្សដែលកើតឡើងទាំងប៉ុន្មានក្នុងការកុសលនេះ ផ្សាយថ្វាយចំពោះសម្តេច

ព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ដែលសព្វថ្ងៃ ព្រះអង្គគង់នៅព្យាបាលព្រះរោគ នាប្រទេសបារាំង សូមព្រះអង្គបានសះស្បើយយ៉ាងឆាប់រហ័ស ហើយសូមឲ្យមានព្រះកាយពលបរិបូណ៌ ដើម្បីបានជាម្លប់យ៉ាងសុខចំរើនរបស់ជាតិខ្មែរ ជាអង្វែងតទៅ ។

---

# សេចក្ដីរាយការណ៍អំពីសកម្មភាព នៃពុទ្ធសាសនបណ្ឌិត្យ

ពីថ្ងៃទី ១ ដល់ ៣១ មីនា ឆ្នាំ ១៩៦៧

១– ផ្នែករដ្ឋបាល :

## ក– អំពីច្បាប់របស់បុគ្គលិក :

ក្នុងត្រីមាសទី ១ នេះ គិតពីថ្ងៃទី ១ មករា មកដល់ថ្ងៃទី៣១មីនា បុគ្គលិកក្នុងក្របខ័ណ្ឌ មិនជាប់កិច្ចសន្យា តាំងព្រះសង្ឃនិងគ្រហស្ថ បាន អនុញ្ញាតឲ្យឈប់សម្រាកប្រចាំឆ្នាំ តាមពាក្យសុំច្បាប់ដោយលាយលក្ខណ៍អក្សររបស់សាម៉ីខ្លួនឬព្រោះមានធុរៈ ៗ

## ខ– លិខិតឆ្លើយឆ្លង :

ក្នុងខែមីនានេះ វិជ្ជាល័យពុទ្ធសាសនបណ្ឌិត្យ បានទាក់ទងនិងទទួលលិខិតផ្សេង ៗ ពីគ្រប់អង្គការនានា :

– លិខិតចូលចំនួន ១៤១ ច្បាប់ : ពីលេខបញ្ជី ១៦០ដល់ ៣០១

– លិខិតចេញចំនួន ១៤៤ ច្បាប់: ពីលេខបញ្ជី ១៦០ ដល់ ៤៨.៣

## គ– ផ្នែកទស្សនាវដ្ដីកម្ពុជសុរិយា :

តាមសេចក្ដីសម្រេចនៃការប្រជុំការងាររបស់ក្រសួងពីថ្ងៃទី ២៧ មីនា ១៩៦៧ អ្នកទទួលខុស-ត្រូវខាងការផ្សាយនៃទស្សនាវដ្ដី កម្ពុជសុរិយា ត្រូវប្រគល់ទៅសហ. លី តាមគេង ៗ ដោយត្រូវប្រគេនព្រះមុនីកោសល

ស្ករ-ហាយ ជួយខាងផ្នែកសមិភាព និងជូនសហាធិវិទីពេទ សល់ជួយខាង ចំនៀមទម្លាប់ តាមដីកាអាត់លេខ ៤៨១ ចុះថ្ងៃ ៣១-៣-៦៧ ។

២- ផ្នែកជាងសន្ធារៈ :

ដោយអ្នកអាននិងអ្នកស្រាវជ្រាវចេះតែធ្វើឲ្យបាត់ ឬប្រឡាក់ទឹកខ្នង នៃស្លាកឈ្មោះអ្នកនិពន្ធ ឈ្មោះសៀវភៅនានានៅក្នុង រក្សាទុកឯក-សារនៃបណ្ណាល័យ នាយកដ្ឋានបានឲ្យនាយការិយាល័យគណនេយ្យ និងនាយបណ្ណារក្សរៀបចំធ្វើដែកចំពុះភ្ជាប់ស្លាកតាំងឡាយក្នុងខ្លួន កុំឲ្យអ្នកអានទាញចេញមកក្រៅបាន ។ កិច្ចការនេះធ្វើសព្វគ្រប់បានចំនួន ទូ ៦ ហើយ ។

ក្រៅពីនេះ សៀវភៅដែលចាស់ៗ ឬរហែកគ្របនោះ នាយក-ដ្ឋានអនុញ្ញាតឲ្យបណ្ណាល័យចងគ្របឡើងវិញ បានចប់សព្វគ្រប់ចំនួន ១៩០ ក្បាល តាំងខ្នាតតូច-ធំរួមគ្នា ។

៣- ផ្នែកបោះពុម្ពផ្សាយ :

សៀវភៅដែលបានអនុញ្ញាតបោះពុម្ពផ្សាយពីខែកុម្ភៈ ចំនួន ១២ មុខ ឥឡូវបោះពុម្ពស្រេចបាច់ហើយ យកមកប្រគល់ជូនឃ្លាំងចំនួន ៨ មុខហើយ គឺ គិហិបដិបត្តិ រឿងទុំទាវ ភិក្ខុបាដិមោក្ខបាលី រឿងមួយពាន់មួយយប់ភាគ ១៦ ១៧-១៨-១៩ និង សត្តបរិត្តទ្វាទសបរិត្ត ។

៤- ផ្នែកចំណូល-ចំណាយ :

## ក- ផ្នែកចំណូល :

ពីថ្ងៃទី ១ ដល់ ៣១ មីនានេះ ចំណូលពីការលក់សៀវភៅផ្សេងៗ ឡើងដល់ ៤៤០.៦៧ រៀល បើគិតសរុបពីដើមខែមករាមក ចំណូលមានដល់ ៥៤៨.៤៥៤រៀល ហើយ ។ គិតទៅគ្រាន់តែក្នុងខែមីនានេះ ចំណូលលើសពីខែកុម្ភៈចំនួន ៤៧.៣៤៨រៀល ។

## ខ- ផ្នែកចំណាយ :

ចំណាយខាងផ្គត់ផ្គង់ គិតតាំងពីការបោះពុម្ពទៅក្រសួងធម្មការផង ក្នុងខែមីនាចំនួន ៨៨៣,០០ ។

បើធៀបទៅនឹងចំណាយខែកុម្ភៈ ខែមីនានេះចាយលើសច្រើនជាង ៩៩ រៀល ។

សរុបចំណាយខាងគ្រឿង ១ ត្រីមាសនេះ " ពីថ្ងៃ ១ មករា ដល់ ៣១ មីនា អស់ចំនួន ៤៦៧៩ រៀលហើយ ។ នៅពុំទាន់ឃើញថ្ងៃចំណាយខាងទឹក ដែលត្រូវសងគេសម្រាប់ ១ ត្រីមាសនេះនៅឡើយទេ ។

## ២- ផ្នែកការងារក្នុងការិយាល័យនានា :

## ក- បណ្ណាល័យ

- ចំនួនអ្នកចូលបកអាន ក្នុងខែមីនា មាន ៣០៧ នាក់ ។
- ចំនួនអ្នកខ្ចីសៀវភៅផ្សេង ៗ យកទៅស្រាវជ្រាវអាននៅផ្ទះ ក្នុងខែមីនា ១៤៧ នាក់ ។

សូមបញ្ជាក់ថា ក្នុងខែនេះ មានអ្នកប្រាជ្ញ អ្នកស្រាវជ្រាវ និងអ្នក

សិក្សាបរទេសជាច្រើនរូបបានមកពិនិត្យរៀបចំឯកសារ ជាស្នាដៃនិពន្ធរបស់ខ្លួននៅបណ្ណាល័យ គឺមាននិស្សិតឧត្តមសិក្សា ៦ រូប សាស្ត្រាចារ្យស្រី ៣ រូប អ្នកបរទេសនៃសាលាបច្ចេកទេស ១ រូប និងបព្រជិត ១ រូប ។ ទាំងអស់គ្នានេះជាជាតិសូវៀត ។

ក្នុង ១ ត្រីមាសនេះ បណ្ណាល័យបានទទួលឯកសារជាវស្សនាវដ្តី សារពត៌មានអំពីស្ពានខូតនិងអង្គការនានា បានចំនួន ៦៣ ក្បាល ។

ដើម្បីរក្សាទុកជាឯកសារ ក្រសួងបានអនុញ្ញាតឲ្យការិយាល័យគណនេយ្យជាវសារពត៌មានភាសាជាតិក្នុងប្រទេស ដើម្បីយកបកចងទុកដូចជាខ្មែរឯករាជ្យ មាតុភូមិ សុជីវធម៌ សុវណ្ណភូមិ សុរិយា បន្ថែមទៅលើអ្នកជាតិនិយម ឡឺសង្គម កម្ពុជា ឡាឌូវែលដេប៉ែស្ស៊ី និងភ្នំពេញប្រែស្ស៊ី ព្រឹត្តិប័ត្រសារពត៌មានខ្មែរ និងអេរដ្ឋកិច្ចបាលទាំងខ្មែរទាំងបារាំង ។

## ១_ ការិយាល័យទំនៀមទម្លាប់ :

ក្នុងខែមីនានេះការិយាល័យបានទទួលឯកសារសម្រាប់បញ្ចូលផ្នែកទំនៀមទម្លាប់ចំនួន ៩ រឿង ។ រីឯឯកសារបានទទួលក្នុង ១ ត្រីមាសនេះមាន ៤៥ ឯកសារ ។

## គ_ សកម្មភាពទូទៅ:

ទី ១ - ក្នុងខែមីនានេះ [illegible]

ផ្សាយវប្បធម៌ [illegible]

- សៀវភៅល្បែងប្រជាប្រិយ ចំនួន ៣៥ ក្បាលទៅទីចាត់ការគរុកោសល្យនៃក្រសួងអប់រំជាតិ ដើម្បីផ្សាយដល់គ្រូមកអប់រំវិជ្ជាសិល្បៈ និងទំនៀមទម្លាប់ខ្មែរ

- ទស្សនាវដ្ដីកម្ពុជសុរិយា តាំងពីឆ្នាំចាស់ថ្មី (មិនគ្រប់តាមលេខរៀងទេ) ចំនួន ២១៧ ក្បាល សម្រាប់អគ្គស្នងការដ្ឋាននៃយុវជនរាជសង្គមនិយមខ្មែរ ។

- សៀវភៅធម៌អាថ៌ជូនចំពោះសហជីវិនអនុរដ្ឋលេខាធិការក្រសួងធម្មការចំនួន ៨១៥ ក្បាល (ពីថ្ងៃ ៤ កុម្ភៈ ៤៦៥ ក្បាល និងថ្ងៃ ២៣ មីនា ៣៥០ ក្បាល) សម្រាប់ផ្សាយដល់វត្តនានា ។

ទី ២ - ក្នុងខែមីនានេះ បានប្រជុំការងារចំនួន ៤ លើក „ គឺថ្ងៃទី ១ មីនា ម្ដង និងថ្ងៃទី ២៧ មីនាម្ដង „

ទី ៣ - បានបញ្ជូនសំណុំរឿងបណ្ដឹងចោទប្រកាន់អ្នកនិពន្ធ និងបណ្ណាគារ ដែលលួចបម្លែងឯកសារសៀវភៅជាទ្រព្យសម្បត្តិរាជការចំនួន ១៥ មុខ „លិខិតលេខ ៤៧៩ ចុះថ្ងៃ ២៩ ៣-៦៧ និងលេខ ៤៨៥ ចុះថ្ងៃ ១ ៤ ៦៧ „ ។

ភ្នំពេញ ថ្ងៃទី ៦ មីនា ១៩៦៧

នាយកវិទ្យាប័ន

# ពរសព្ទសាធុការ

ព្រះរាជាណាចក្រកម្ពុជា
លេខ ៨៩

វត្តឧទ្ធមណីរាម ក្រុងភ្នំពេញ

## ក្រសួងសម្ដេចព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ

ថ្ងៃ ៥ ៤ ៦ ឆ្នាំមមីអដ្ឋស័ក ព.ស ២៥០៩

គឺថ្ងៃទី ១៣ ខែមេសា គ.ស. ១៩៦៧

សូមចំរើនពរមកលោកនាយក វិទ្យាល័យពុទ្ធសាសនបណ្ឌិត្យ

សូមជ្រាប ។

អាត្មាភាព បានទទួលកាលពីថ្ងៃ ព្រហស្បតិ៍ ទី ១៣ មេសា ១៩៦៧ នូវលិខិតប្រគេនពររបស់លោក លេខ ៥០៥ ព.ប. ដែលលោកព្រមទាំងសហការីរបស់លោក បានប្រសិទ្ធពរប្រគេនអាត្មាភាព ក្នុងឱកាសចូលឆ្នាំថ្មីនេះ ។

ចំពោះពរសព្ទសាធុការ ដែលលោកប្រសិទ្ធិប្រគេនអាត្មានេះបញ្ជាក់ឲ្យឃើញនូវសមានចិត្តដ៏ស្មោះសរបស់លោក ចំពោះរូបអាត្មាភាព ។

ក្នុងនាមនៃព្រះសង្ឃ ខាងគណៈធម្មយុត្តទាំងមូល និងក្នុងនាមផ្ទាល់នៃអាត្មាភាព សូមប្រសិទ្ធិពរជ័យសិរីមង្គលវិបុលសុខ គ្រប់ប្រការជូនលោកនិងសហការីរបស់លោក ព្រមទាំងគ្រួសារ និងសូមបួងសួងដល់

គុណព្រះរតនត្រ័យនិងវត្ថុសក្តិសិទ្ធិក្នុងលោក ព្រមទាំងទេវតាដែលមាន មហិទ្ធិឫទ្ធិ មានទេវតាឆ្នាំថ្មីនេះជាដើម សូមជួយទ្រទ្រង់លោក និងសហការីរបស់លោក ឲ្យបានប្រកបដោយជោគជ័យ ជាទីបំផុត ក្នុងការបំរើជាតិតទៅ ។

សូមលោកទទួលនូវសេចក្តីរាប់អានដ៏ស្មោះអំពីអាត្មាភាព ។

សម្តេចព្រះសុធម្មាធិបតីសង្ឃនាយក

ព្រះហស្តលេខា លៀង

ទីស្តីការក្រសួងធម្មការ

អគ្គាធិការដ្ឋាន

នៃ

ពុទ្ធិកសិក្សា

ព្រះរាជាណាចក្រកម្ពុជា

ភ្នំពេញ ថ្ងៃទី ៨ មេសា ១៩៦៧

លេខ ៤៩ អ.ព.ស.

ចំរើនពរមកលោកនាយកវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ ។

អាត្មាបានទទួលលិខិតលោក លេខ ៥០៨–ប.ព. ចុះថ្ងៃទី ៧ មេសា ១៩៦៧ ហើយ ។ ក្នុងលិខិតនោះ លោកបានប្រគេនពរជ័យសិរីសួស្តីចំពោះអាត្មា ក្នុងឱកាសចូលឆ្នាំថ្មីនេះ គឺឆ្នាំ មមែនព្វស័ក ព·ស ២៥១០ នេះ ដើម្បីសូមឲ្យអាត្មា មានសុខភាពបរិបូណ៌គ្រប់កាល ។ អាត្មាសូមទទួលពរជ័យ របស់លោកដោយសេចក្តីរីករាយជាទីបំផុត ។

អាត្មាសូមទៀតក្នុងឱកាសដ៏ប្រសើរនេះ ប្រសិទ្ធពុទ្ធពរទាំង ៤ ប្រការ ជូនចំពោះលោក ព្រមទាំងបុគ្គលិកទាំងអស់ ទាំងបព្វជិត-គ្រហស្ថ នៃវិជ្ជាឋាននេះ សូមប្រកបដោយសុខសួស្តីជ័យមង្គលគ្រប់ប្រការ កុំបីឃៀតឃ្លាត ហើយសូមឲ្យវិជ្ជាឋាននៃពុទ្ធសាសនបណ្ឌិត្យ ក្រោមការគ្រប់គ្រងនៃលោក មានសិរីភាពថេរកាលតរៀងទៅ ។

ព្រះហស្តលេខា : ហួត តាត